# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និងវិទ្យាសាស្ត្រសេដ្ឋកិច្ច


## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
# ករណីឃុំប្រាសាទ ស្រុកកំពង់ត្រាបែក
# ខេត្តព្រៃវែង

កម្មសិក្សាពីថ្ងៃទី១៨ ខែ មីនា ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ២០១៩

ឈ្មោះស្ថាប័ន៖ **សាលាឃុំប្រាសាទ ស្រុកកំពង់ត្រាបែក ខេត្តព្រៃវែង**


| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **អ៊ឹង ហ្គេចលី** | បណ្ឌិត **ឈុន ពហុ** |
| **ឡេង វុទ្ធចនា** | |


| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍ | ឆ្នាំចូលសិក្សា ២០១៥ |
| ជំនាន់ទី ០៣ | ឆ្នាំសរសេររបាយការណ៍ ២០១៩ |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **អ៊ឹម ហ្គេចលី** និង **ឡេង ឌួចនា** ជានិស្សិតឆ្នាំទី ៤ ជំនាន់ទី៣ ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសំដែងនូវការដឹងគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកឪពុក និង អ្នកម្តាយជាទីស្រឡាញ់ដែលបានផ្តល់កំណើតព្រមទាំងចិញ្ចឹមបីបាច់ អប់រំទូន្មានប្រៀនប្រដៅ ព្រមទាំងបានឧបត្ថម្ភគ្រប់បែបយ៉ាងដល់កូន មិនថាត្រូវជួបនិងឧបសគ្គបែបណាក៏ដោយ ដើម្បីឲ្យកូនបានសិក្សារៀនសូត្រ និងមានចំណេះដឹងទុកជាទ្រព្យសម្រាប់ពេលអនាគត។
- ឯកឧត្តមសាកលវិទ្យាធិការនៃវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងលោកសាស្ត្រាចារ្យ ដែលបានយកចិត្តទុកដាក់បង្ហាត់បង្រៀន និងផ្តល់បទពិសោធន៍ល្អៗយ៉ាងច្រើនដល់ក្រុមយើងខ្ញុំទាំងពីររយៈពេលកន្លងមក។
- លោកគ្រូសាស្ត្រាចារ្យបណ្ឌិត **ឈុន ពហុ** ដែលបានចំណាយទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការណែនាំ និងផ្តល់យោបល់ល្អៗព្រមទាំង ជួយកែសម្រួលនូវរាល់កំហុស ដូច្នេះទើបធ្វើឲ្យឯកសារស្រាវជ្រាវ ឬកម្មសិក្សាមួយនេះប្រកបទៅដោយរលូន និងទទួលបានភាពជោគជ័យ។
- លោកអ៊ុំ លឹម ផេង ដែលត្រូវជាមេឃុំ ប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែងដែលបានសម្រួលការផ្តល់ជាឯកសារជាច្រើនដែលមានការពាក់ព័ន្ធនិងប្រធានបទ ដូចនេះទើបធ្វើឲ្យការស្រាវជ្រាវនេះទទួលបានភាពជោគជ័យ។

ជាចុងក្រោយនេះ ពួកយើងទាំងពីរសូមប្រសិទ្ធិពរ សិរីមង្គល វិបុលសុខ មហាប្រសើរ និងសម្តែងនូវកតញ្ញូតាធម៌ ជូនដល់លោកឪពុក អ្នកម្តាយ លោកគ្រូ អ្នកគ្រូដែលមានគុណទាំងអស់ សូមជួបប្រទះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានបញ្ចប់ការសិក្សាលើទ្រឹស្តីនៃមុខជំនាញសេដ្ឋកិច្ចអភិវឌ្ឍ អស់រយៈពេលជិតបួនឆ្នាំមកនេះ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរទទួលបានភារកិច្ចពីសាលាចុះកម្មសិក្សាដោយផ្ទាល់ ដើម្បីស្រាវជ្រាវចងក្រងសៀវភៅនេះឡើងក្នុងគោលបំណងចង់ភ្ជាប់នូវចំណេះដឹងផ្នែកទ្រឹស្តីដែលបានសិក្សាកន្លងមកនៅសាលា ទៅនឹងសកម្មភាព ឬការអនុវត្តន៍ជាក់ស្តែងនូវប្រធានបទណាដែលយើងចង់សិក្សា និងនៅតាមកន្លែងណាមួយដែលយើងគិតថាវាត្រូវនិងប្រធានបទរបស់យើង។ ម្យ៉ាងវិញទៀតដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ឯកទេសសេដ្ឋកិច្ចអភិវឌ្ឍន៍ ក្រោមប្រធានបទ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងឃុំប្រាសាទដែលមានការចាប់អារម្មណ៍ពីយើងខ្ញុំទាំងពីរ។

ដោយហេតុ ក្រុមរបស់យើងខ្ញុំដឹងថា ការកសាង ឬការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមទីជនបទ ព្រោះរាជរដ្ឋាភិបាលកម្ពុជាកំពុងតែផ្តោតការយកចិត្តទុកដាក់ ដោយយោងតាមយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលក្នុងអាណត្តិទី៥។ លើសពីនេះទៅទៀត យើងចង់បង្ហាញពីមាន សារៈសំខាន់នៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមទីជនបទក្នុងការជំរុញវិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្ម សេវាកម្ម និងអំពីបញ្ហាប្រឈម និងដំណោះស្រាយមួយចំនួនដែលឃុំបានជួបប្រទះ។

របាយការណ៍នេះក៏សម្រាប់ទុកជាឯកសារមួយដែលបានជំនួយជាស្មារតីចំនួនដល់សាលាឃុំនៅតាទីជនបទ និងនិស្សិតជំនាន់ក្រោយៗដែលចង់ដឹងពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមទីជនបទ។

ដោយរបាយការណ៍មួយនេះគឺជាកម្មសិក្សាស្រាវជ្រាវដំបូងរបស់ក្រុមយើងខ្ញុំ បានជាយើងខ្ញុំជឿជាក់ថា របាយការណ៍មួយនេះពិតជាមានការខ្វះខាត មានកំហុសផ្នែកអក្ខរាវិរុទ្ធ ហើយនៅមានចន្លោះខ្លះពិបាកក្នុងការយល់ ដែលត្រូវបំពេញបន្ថែមទៀតជាមិនខាន ដូច្នេះ យើងខ្ញុំសូមអភ័យទោស និងរង់ចាំទទួលនូវការរិះគន់ ការណែនាំ ក៏ដូចជាការកែសម្រួលក្នុងន័យស្ថាបនាពីសំណាក់ លោកសាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានមកពីគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីបំពេញបន្ថែមនូវរាល់ចំណុចខ្វះខាត់ទាំងអស់ និងទុកជាបទពិសោធន៍សម្រាប់ កម្មសិក្សាស្រាវជ្រាវលើកក្រោយៗទៀត។

# មាតិកា

**ទំព័រ**


បញ្ជីតារាង ........ v

បញ្ជីក្រាហ្វិក ........ vi

បញ្ជីឧបសម្ព័ន្ធ ........ vii


## សេចក្តីផ្តើម


១. លំនាំបញ្ហា ........ ១

២. ចំណោទបញ្ហា ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ៣

៤. ទំហំ និងដែនកំណត់ស្រាវជ្រាវ ........ ៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី ១
## ការរំលឹកទ្រឹស្តី


១.១. និយមន័យ ........ ៦

១.១.១. និយមន័យ ការអភិវឌ្ឍ ........ ៦

១.១.២. ការអភិវឌ្ឍជនបទ ........ ៦

១.១.៣. ហេដ្ឋារចនាសម្ព័ន្ធ ........ ៧

១.១.៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ ........ ៧

១.២.២. ប្រពន្ធ័ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ........ ៨

១.២.៣.អនុវត្តន៍វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ........ ៨

១.២.៤.ប្រាប់ចំណូលនិងកម្រិតជីវភាពរស់នៅ ........ ៨

១.២.៥. ការងារ អប់រំ សុខាភិបាល និងវប្បធម៌ ........ ៨

១.៣. ទស្សនរបស់អ្នកប្រាជ្ញ ........ ៩

១.៣.១.ទ្រឹស្តី Michael P. Todaro ........ ៩
១.៣.២. ទ្រឹស្តី Robert Me Namara ........ ៩
១.៣.៣ ទ្រឹស្តីរបស់លោក Wait Withman Rostow ........ ១០
១.៣.៤. ទ្រឹស្តី Big Push ........ ១១
១.៣.៥. ទ្រឹស្តីរបស់លោក Francios Perrux ........ ១២
១.៤. កត្តាសំខាន់ៗដែលធ្វើឲ្យមានការអភិវឌ្ឍ និងជាបញ្ហាដល់ការអភិវឌ្ឍ ........ ១២
១.៤.១. កត្តាសំខាន់ៗដែលធ្វើឲ្យមានការអភិវឌ្ឍ ........ ១២
១.៤.១.២. កត្តាធនធានមនុស្ស ........ ១៣
១.៤.១.៣. កត្តាមូលធន ........ ១៤
១.៤.១.៤. កត្តារចនាសម្ព័ន្ធ ........ ១៤
១.៤.២. កត្តាដែលជាបញ្ហាដល់ការអភិវឌ្ឍ ........ ១៥
១.៤.២.១. ភាពក្រីក្រ ........ ១៥
១.៤.២.២. អត្រាកំណើនប្រជាជនខ្ពស់ ........ ១៦
១.៤.២.៣. ការអប់រំនៅទាប ........ ១៦
១.៤.២.៤. បញ្ហានិកម្មភាព ........ ១៧
១.៤.២.៥. ការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិតទាប ........ ១៧
១.៤.២.៦. កត្តានយោបាយ ........ ១៧
១.៥. យុទ្ធសាស្ត្រអភិវឌ្ឍរបស់រាជរដ្ឋាភិបាល ........ ១៨
១.៦. មូលដ្ឋានគ្រឹះនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ ........ ១៩
១.៦.១. សាលារៀន ........ ២០
១.៦.២.វិស័យសុខាភិបាល ........ ២០
១.៦.៣.ការពង្រីកធារាសាស្ត្រខ្នាតតូច ........ ២១
១.៦.៤. ការសាងសង់ស្ពាន ........ ២១
១.៦.៥. ការសាងសង់លូ ........ ២២
១.៦.៦. ការជីកប្រឡាយ ........ ២២
១.៦.៧. ការសាងសង់ផ្សារនៅជនបទ ........ ២២

១.៧. ការស្ដាបនាផ្លូវ ..... ២៣
១.៧.១. ការអភិវឌ្ឍផ្លូវលំ ..... ២៣
១.៧.២. ការថែទាំផ្លូវ ..... ២៤
១.៧.២.១. ថែទាំខួប ..... ២៤
១.៧.២.២. ការងារសម្អាត ..... ២៤
១.៧.២.៣. ការងារបំពេញដី រៀបចំតួផ្លូវ ..... ២៥
១.៧.២.៤. ការងារក្រាលគ្រួសក្រហម ..... ២៥
១.៧.២.៥. ការកៀរពង្រាប និងតម្រឹមចិញ្ចើមផ្លូវ ..... ២៦
១.៧.២.៦. ការការពារការហូរច្រោះ ..... ២៦
១.៧.៣. អត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការស្ដាបនាផ្លូវលំជនបទ ..... ២៧
សន្និដ្ឋានជំពូក ..... ២៨

ជំពូកទី២

ស្ថានភាពទូទៅនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅឃុំប្រាសាទ

២.១ ប្រវត្តិ និងទីតាំងភូមិសាស្ត្រ ..... ៣១
២.១.១ ប្រវត្តិឃុំប្រាសាទ ..... ៣១
២.១.២ ទីតាំងភូមិសាស្ត្រ ..... ៣២
២.១.៣ ស្ថានភាពប្រជាជនបច្ចុប្បន្ននៃឃុំប្រាសាទ ..... ៣២
២.២ ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍ ..... ៣២
២.២.១ ចក្ខុវិស័យ ..... ៣២
២.២.២ គោលបំណង និងគោលដៅ ..... ៣៣
២.២.៣. យុទ្ធសាស្ត្រនៃការអភិវឌ្ឍ ..... ៣៤
២.៣. រចនាសម្ព័ន្ធគ្រប់គ្រង និងតួនាទីភារកិច្ចសមាជិកឃុំប្រាសាទ ..... ៣៦
២.៣.១ រចនាសម្ព័ន្ធគ្រប់គ្រងឃុំ ..... ៣៦
២.៣.២ តួនាទី និងភារកិច្ចរបស់សមាជិក ឃុំប្រាសាទ ..... ៣៧
២.៤. ក្របខ័ណ្ឌវិនិយោគ និងគម្រោងវិនិយោគរបស់ឃុំប្រាសាទ ..... ៤០
២.៤.១. ក្របខ័ណ្ឌវិនិយោគ ..... ៤០

២.៤.២. គម្រោងវិនិយោគ ...................................................................... ៤១
២.៤.២.១. ថវិកាវិនិយោគតាមប្រភព ...................................................................... ៤១
២.៤.២.២ គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ ...................................................................... ៤១
២.៤.២.៣ គម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ ...................................................................... ៤២
២.៥. ការប្រព្រឹត្តិទៅនៃដំណើរអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តឃុំប្រាសាទ ......................................................................៤៥
២.៦ សមិទ្ធិផលនៃការអភិវឌ្ឍឃុំប្រាសាទ ...................................................................... ៤៦
២.៧. បញ្ហាដែលជួបប្រទះ និងដំណោះស្រាយ ......................................................................៤៩
២.៧.១. បញ្ហាដែលជួបប្រទះ ......................................................................៤៩
២.៧.២. ដំណោះស្រាយនូវបញ្ហាដែលកើតមានឡើង ...................................................................... ៥២
សេចក្តីសន្និដ្ឋាន ......................................................................៥៤

## ជំពូកទី ៣

## ការវិភាគលើលទ្ធផលនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តឃុំប្រាសាទ

៣.១. សមិទ្ធិផលដែលឃុំប្រាសាទសម្រេចបាន ...................................................................... ៥៧
៣.១.១. ផ្នែកគមនាគមន៍ ...................................................................... ៥៧
៣.១.២. ផ្នែកធារាសាស្ត្រ ...................................................................... ៥៨
៣.១.៣. ផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ......................................................................៥៩
៣.២. គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តមិនទាន់សម្រេច និងគ្មានថវិកាគ្រាំទ្រ .............. ៦៤
៣.៣. បញ្ហាប្រឈមលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងឃុំប្រាសាទ ...................................................................... ៦៦
៣.៤. ដំណោះស្រាយ ...................................................................... ៦៧
៣.៥. វាយតម្លៃ ...................................................................... ៦៩
៣.៥.១. គុណសម្បត្តិ ...................................................................... ៦៩
៣.៥.២. គុណវិបត្តិ ...................................................................... ៧០
សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍......................................................................៧២

# បញ្ជីតារាង

១. តារាង ១.១ ប្រវែងផ្លូវនៅក្នុងឃុំប្រាសាទ.......................................................................... ៥៧
២. តារាង ១.២ បង្ហាញពីចំនួននៃបន្ទប់សាលាដែលបានសាងសង់បន្ថែម.................................៥៩
៣. តារាង ១.៣ ចំនួនគ្រួសារដែលមានប្រើប្រាស់បង្គន់អនាម័យ ............................................ ៦១
៤. តារាង ១.៤ ចំនួនគ្រួសារដែលប្រើប្រាស់ទឹកស្អាត ............................................................៦៣
៥. តារាង ១.៥ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តមិនទាន់សម្រេច និងគ្មានថវិកាគ្រាំទ្រ........................... ៦៤
៦. តារាង ១.៦ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តមិនទាន់សម្រេច និងគ្មានថវិកាគ្រាំទ្រ........................... ៦៥

# បញ្ជីក្រាហ្វិក

១. ក្រាហ្វិក ១.១ បង្ហាញពីចំនួននៃបន្ទប់សាលាដែលបានសាងសង់បន្ថែម ............................ ៦០
២. ក្រាហ្វិក ១.២ ភាគរយគ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេសតាមភូមិក្នុងឃុំប្រាសាទ ......... ៦១
៣. ក្រាហ្វិក ១.៣ ចំនួនគ្រួសារដែលមានបង្គន់ប្រើប្រាស់ ...................................................... ៦២
៤. ក្រាហ្វិក ១.៤ ការប្រើប្រាស់ទឹក ........................................................................................ ៦៣

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១៖ ផែនទីខេត្តព្រៃវែង

ឧបសម្ព័ន្ធទី ២៖ ផែនទីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

ឧបសម្ព័ន្ធទី ៣៖ ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍឃុំ

ឧបសម្ព័ន្ធទី ៤៖ គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលឃុំបានសម្រេច

ឧបសម្ព័ន្ធទី ៥៖ គម្រោង សកម្មភាពវិនិយោគឃុំដែលមិនទាន់មានថវិកាគ្រាំទ្រ

ឧបសម្ព័ន្ធទី ៦៖ បញ្ហាប្រឈមរបស់ឃុំទាក់ទងនិងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា ជាប្រទេសមួយដែលស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍ មានព្រំប្រទល់ខាងកើត និងខាងត្បូងទល់នឹងប្រទេសវៀតណាម ខាងជើងទល់នឹងប្រទេសថៃ និងឡាវ ខាងលិចទល់ និងឈូងសម្រុទថៃ ហើយមានផ្ទៃដីសរុប ១៨១,០៣៥ គ.ម$^2$ ។ ហើយប្រទេសកម្ពុជា ក៏ជាប្រទេសមួយដែលស្ថិតក្នុងចំណោមបណ្តាប្រទេសក្រីក្រនោះដែរ ព្រោះតែសង្គ្រាមក្នុងស្រុកជាងពីរទសវត្សកន្លងមកនេះបានបំផ្លិតបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្សយ៉ាងច្រើន ហើយបានបន្សល់ទុកនូវភាពក្រីក្រដល់ប្រជាជន ជាពិសេសនៅតាមជនបទ។

យើងដឹងហើយថានៅចន្លោះឆ្នាំ ១៩៧៥ ដល់ ១៩៧៩ គឺប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងរបបប្រល័យពូជសាសន៍(ប៉ុលពត) ដែលជាលទ្ធផលចុងក្រោយគឺបានធ្វើឲ្យប្រជាពលរដ្ឋក្នុងស្រុកស្លាប់ជាច្រើននាក់ ដែលសុទ្ធសឹងជាអ្នកបញ្ញវន័ ដូចជា មន្ត្រីរាជការ គ្រូបង្រៀន និងគ្រូពេទ្យជាដើម ហើយលើសពីនេះទៅទៀតបានធ្វើឲ្យពួកគេទទួលរងទុកវេទនា ភាពសោកសៅ និងមានការបំផ្លិចបំផ្លាញគ្រប់យ៉ាង ការបាត់បង់មូលធន ធនធានមនុស្ស កត្តាពលកម្ម ដែលជាកត្តាដ៏សំខាន់ក្នុងការអភិវឌ្ឍ។

ផ្ទុយទៅវិញ បន្ទាប់ពីប្រទេសកម្ពុជាបានរួចផុតពីរបបប្រល័យពូជសាសន៍ នៅថ្ងៃទី ៧ មករា ឆ្នាំ១៩៧៩ បានធ្វើឲ្យប្រទេសកម្ពុជាមានការផ្លាស់ប្តូរមុខមាត់របស់ខ្លួនសារជាថ្មី ជាពិសេសក្រោយការបោះជាតិឆ្នាំ ១៩៩៣ ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិបានធ្វើឲ្យប្រទេសកម្ពុជាមានការផ្លាស់ប្តូរ វិស័យសេដ្ឋកិច្ច និងនយោបាយ រួមនិងវិស័យផ្សេងៗទៀតដូចជា វិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ទេសចរណ៍ និងគមនាគមន៍។ ម្យ៉ាងវិញទៀត រដ្ឋាភិបាលក៏បានផ្តោតសំខាន់ទៅលើការសហការជាមួយ អង្គការ សមាគមន៍ ភ្នាក់ងារជាតិ និងអន្តរជាតិនានា ក្នុងគោលបំណងដើម្បីអភិវឌ្ឍជនបទកម្ពុជាយើងឲ្យមានភាពរីកចម្រើនខ្លាំង ដើម្បីឲ្យអ្នករស់នៅជនបទមានឪកាសបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ដែលធ្វើឲ្យការបែងចែកមូលធនកាន់តែមានប្រសិទ្ធិភាពថែមទៀត រវាងអ្នករស់នៅទីក្រុង និងជន បទ ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ ហើយនឹងរក្សានិរន្តភាព ឲ្យអស់ពីលទ្ធភាពដែលខ្លួនមាន។

លើសពីនេះទៅទៀតរដ្ឋាភិបាលក៏យកចិត្តទុកដាក់យ៉ាងខ្លាំងទៅការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រោះវាជាមធ្យោបាយដ៏សំខាន់សម្រាប់សម្រួលដល់ជីវភាព របស់ប្រជាជនចាប់ពីទីក្រុងរហូតដល់ជនបទដាច់ស្រយាល ដូចជា ផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ វត្តអារាម ប្រព័ន្ធ

ស្រោចស្រព ទំនប់ ព្រែក ស្ទឹង អូរ ប្រឡាយទឹក អគ្គិសនី និងទឹកស្អាត ។ល។ នៅពេលដែលស្ថេរភាពនយោបាយល្អ និងមានការអភិវឌ្ឍបែបនេះហើយ ដែលអំណោយផលបរិស្ថានវិនិយោគបានទាក់ទាញវិនិយោគិនយ៉ាងច្រើនមកបណ្តាក់ទុននានា ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលជាច្រើន និងដៃគូអភិវឌ្ឍបានជួយស្តារទាំងនៅទីក្រុង និងជនបទមានលក្ខណៈងាយស្រួលដែលរិតតែជួយជម្រុញឲ្យសេដ្ឋកិច្ចកម្ពុជាកាន់តែមានការរីកចម្រើនឡើងៗ។ ទទឹមនឹងនេះរាជរដ្ឋាភិបាលលោកបានចំណាយលើការវិនិយោគសាធារណៈទៅលើបណ្តាក្រសួង ជាពិសេសក្រសួងជនបទ ដែលក្នុងនោះមានមន្ទីរអភិវឌ្ឍជនបទនៅតាមបណ្តាលខេត្តទូទាំងប្រទេស ដែលការអភិវឌ្ឍន៍ទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ។

យ៉ាងណាមិញ មកដល់ពេលបច្ចុប្បន្ន ប្រទេសកម្ពុជានូវតែមានតម្រូវការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាខ្លាំង និងជាច្រើនកន្លែងទៀត ជាពិសេសនៅតាមទីជនបទ។ ហើយខេត្តព្រៃវែង ក៏ដូចគ្នាដែរ គឺគម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តមួយចំនួនគឺបានសម្រេចអស់ហើយ ប៉ុន្តែនៅមានមួយចំនួន ទាមទរឲ្យមានការកសាងបន្ថែម ការកែលម្អ ក៏ដូចជាការថែរក្សាការពារផងដែរ ជាក់ស្តែងគឺនៅក្នុងឃុំប្រាសាទ។ និងក្រុមប្រឹក្សារដ្ឋបាលឃុំប្រាសាទបានដាក់ចេញនូវគម្រោងអភិវឌ្ឍផ្សេងៗទៀតជាច្រើន ដូចជា ផ្លូវ សាលារៀន ប្រព័ន្ធធានាសាស្ត្រ ប្រព័ន្ធលូរ និងបណ្តុះបណ្តាលយុវជន និងយុវនារីឲ្យមានចំណេះដឹង ដើម្បីចូលរួមក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចសមូលដ្ឋាន និងលើកម្ពស់ជីវភាពប្រជាជននៅក្នុងឃុំផងដែរ។

## ២. ចំណោទបញ្ហា

យ៉ាងណាមិញ បើទោះបីជានៅទីជនបទមានការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័រូបវន្តពិតប្រាកដមែន ប៉ុន្តែការអភិវឌ្ឍគឺបានតែមួយផ្នែកតូចតែប៉ុណ្ណោះ ដូចនេះវានៅតែជាបញ្ហាដែលទាមទារឲ្យផ្នែកដែលពាក់ពន្ធ័ទាំងអស់ ជាពិសេសក្រសួងអភិវឌ្ឍជនបទយកចិត្តទុកដាក់បន្ថែមទៀតលើការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័រូបវន្ត តាមទីជនបទព្រោះវាជាចំណុចដ៏សំខាន់មួយក្នុងការឈានទៅរកការអភិវឌ្ឍវិស័យឧស្សាហាកម្ម កសិកម្ម និងសេវាកម្ម។ តើហេតុអ្វីបានជាចាំបាច់មានការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័រូបវន្តជនបទ? និងតើដំណោះស្រាយយ៉ាងដូចម្តេច ឬផែនការបែបណាដែលមានប្រសិទ្ធភាពចំពោះការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័រូបវន្តជនបទ? សំណួរដែលបានលើកឡើងខាងលើនេះនិងពន្យល់បកស្រាយក្រោមប្រធានបទ "**ការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័រូបវន្តជនបទ**" ករណីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដែលជាកិច្ចការស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរនាក់។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ មានគោលបំណងចង់បង្ហាញពីសារៈសំខាន់ ក៏ដូចជាតួនាទីអំពីហេដ្ឋារចនាសម្ពន្ធ័រូបវន្តក្នុងការអភិវឌ្ឍជនបទ។ លើកពីនេះទៅទៀតក្រុមយើងខ្ញុំចង់ស្វែងរកបន្ថែមនូវវិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាជាក់ស្តែង ដែលពាក់ពន្ធ័នឹងការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័រូបវន្ត័ជនបទ។ ម្យ៉ាងវិញទៀត យើងខ្ញុំក៏ចង់សិក្សាបន្ថែមទៀតអំពីស្ថានភាពនៃគម្រោងការអភិវឌ្ឍរបស់ឃុំ ក៏ដូចជាសមិទ្ធិផលដែលបានមកពីគម្រោងផងដែរ។

បន្ទាប់មកទៀតក្រុមយើងខ្ញុំនឹងធ្វើសេចក្តីសន្និដ្ឋានអំពីលទ្ធផលដែលបានរកឃើញ រួមទាំងធ្វើការវិភាគ និងបកស្រាយលើសមិទ្ធិភាព បញ្ហាប្រឈម និងដំណោះស្រាយ។ ជាចុងបញ្ចប់ យើងនឹងផ្តល់ជាអនុសាសន៍ចំពោះការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័រូបវន្ត័នៅក្នុងឃុំប្រាសាទ។

## ៤. ទំហំ និងដែនកំណត់ស្រាវជ្រាវ

នៅក្នុងរបាយការណ៍កម្មសិក្សាមួយនេះ ដោយប្រទេសកម្ពុជាខេត្តនីមួយៗមានទំហំដីធំដូចនេះក្រុមយើងខ្ញុំបានជ្រើសរើសយកកំណត់ទំហំ និងដែនកំណត់ត្រឹមឃុំមួយនៅទីជនបទដែលមានឈ្មោះថា **ឃុំប្រាសាទ** ដែលក្នុងឃុំនេះមានចំនួន ៩ភូមិតូចៗទៀត ហើយឃុំនេះដែរគឺស្ថិតនៅក្នុងស្រុកកំពង់ត្របែកខេត្តព្រៃវែង។ ហើយការសិក្សាស្រាវជ្រាវនេះដែរគឺផ្តោតសំខាន់ទាក់ទងទៅនឹងប្រធានបទ "**ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ**" ករណីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែងចាប់ពី ឆ្នាំ ២០១៥ មកដល់ បច្ចុប្បន្ន និងរយៈពេលនៃការស្រាវជ្រាវគឺចាប់ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៩។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការចងក្រងកិច្ចការស្រាវជ្រាវកម្មសិក្សាមួយនេះឡើង ក្រុងយើងខ្ញុំបានចុះដល់កន្លែងផ្ទាល់នៃមូលដ្ឋានឃុំប្រាសាទ និងដោយពឹងផ្អែកលើឯកសារមួយចំនួនដែលមានតម្កល់នៅសាលាឃុំ ដែលពាក់ពន្ធ័នឹងប្រធានបទ។ ហើយក្រុមយើងបានបែងចែកប្រភពទិន្នន័យដែលក្រុមយើងបានប្រើប្រាស់ជាពីរប្រភេទៈ

**ទិន្នន័យចម្បង**

- ជាប្រភេទទិន្ន័យដែលបានមកពីការចុះទៅយកដោយផ្ទាល់នៅសាលាឃុំប្រាសាទ
- ព័ត៌មានដែលបានមកពីការសួរនាំពីលោកអ៊ុំមេឃុំ
- ប្រមូលព័ត៌មានតាមរយៈការចុះសម្ភាសន៍ប្រជាជនដែលរស់នៅក្នុងមូលដ្ឋានផ្ទាស់

**ទិន្នន័យបន្ទាប់បន្សំ**

ជាប្រភេទទិន្នន័យដែលបានមកពីឯកសារផ្សេងៗដូចជា៖

- សៀវភៅ និងឯកសារដែលទាក់ទងនិងការអភិវឌ្ឍ និងការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័រូបវន្ត័
- ប្រមូលបានតាមរយៈការអនុញ្ញាត និងអនុគ្រោះរបស់មេឃុំ មេភូមិ សមាជិកឃុំដទៃទៀត នូវការផ្តល់ជាឯកសាររបាយការណ៍ឃុំដែលពាក់ពន្ធ័នឹងប្រធានបទ
- ឯកសារដែលបានចងក្រងកន្លងមករបស់សិស្សច្បង, ឯកសារនៅក្នុងបណ្ណាល័យសេដ្ឋកិច្ច នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងតាមបណ្ណាល័យផ្សេងទៀតមួយចំនួន
- ឯកសារទីស្តីការគណៈរដ្ឋមន្ត្រី, យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា ចតុកោណទី២.ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត័, មុំទី១. ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍
- អត្ថបទដកស្រង់ចេញពីគេហទំព័រអ៊ីនធឺណេតមួយចំនួន។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះ គឺពិតជាមានសារៈសំខាន់ណាស់ ចំពោះក្រុមយើងខ្ញុំ ក៏ដូចជាសិស្សនិស្សិតជំនាន់ក្រោយ ហើយសារៈសំខាន់ទាំងនោះមានដូចជា៖

- ❖ ជាឯកសារសម្រាប់ការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់ក្រុមខ្ញុំ។ ក្នុងការចុះកម្មសិក្សាស្រាវជ្រាវនេះបានធ្វើឲ្យក្រុមយើងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើន ជាមួយនឹងការអនុវត្តន៍ផ្ទាល់នៃកិច្ចការងារហេដ្ឋារចនាសម្ពន្ធ័ឃុំប្រាសាទ។
- ❖ របាយការណ៍នេះទុកជាវត្ថុតាងនៃការចុះកម្មសិក្សាស្រាវជ្រាវរបស់ឃុំ និងទុកជាឯកសារយោងសម្រាប់ការសិក្សាស្រាវជ្រាវរបស់សិស្សនិស្សិតជំនាន់ក្រោយ ក្នុងការបង្កើនចំណេះដឹងផងដែរ
- ❖ ជាឯកសារ ឬជាសៀវភៅជំនួយស្មារតីដល់អ្នកដែលមានភារកិច្ចក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត័ជនបទ។
- ❖ ផ្តល់ជូននូវដំណោះស្រាយមួយចំនួនដែលទាក់ទងនិងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត័ក្នុងឃុំប្រាសាទ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃរបាយការណ៍កម្មសិក្សានេះ ចែកចេញជា ៥ផ្នែក និង ៣ជំពូក ដូចខាងក្រោម៖

- ➢ សេចក្តីផ្តើម

- ជំពូកទី ១ រួមមានដូចជា និយមន័យនៃពាក្យគន្លឹះដែលទាក់ទងនឹងប្រធានបទ, ទិសដៅនៃការអភិវឌ្ឍជនបទ, ទ្រឹស្តីអ្នកប្រាជ្ញ, កត្តាសំខាន់ៗដែលធ្វើឲ្យមានការអភិវឌ្ឍ និងជាបញ្ហាដល់ការអភិវឌ្ឍ, យុទ្ធសាស្ត្រអភិវឌ្ឍរបស់រាជរដ្ឋាភិបាល, មូលដ្ឋានគ្រឹះនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ, ការស្ថាបនាផ្លូវជនបទ និងសន្និដ្ឋានជំពូក។
- ជំពូកទី ២ ប្រវិត្តនិងទីតាំងនៃឃុំប្រាសាទ រួមជាមួយនិងស្ថាភាពទូទៅនៃឃុំ, រចនាសម្ព័ន្ធគ្រប់គ្រង និង ភារកិច្ចសមាជិកឃុំប្រាសាទ, ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍ, ក្របខណ្ឌវិនិយោគ និងគម្រោងវិនិយោគរបស់ឃុំប្រាសាទ, ការប្រព្រឹត្តិទៅនៃដំណើរអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តឃុំប្រាសាទ, បញ្ហាប្រឈម និងដំណោះស្រាយ និងសន្និដ្ឋានជំពូក។
- ជំពូកទី ៣ គឺបានបកស្រាយអំពី សមទ្ធិផលដែលឃុំសម្រេចបានលើហេដ្ឋរចនាសម្ព័ន្ធ, គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមិនទាន់សម្រេច និងគ្មានថវិកាគ្រាំទ្រ, បញ្ហាប្រឈម, ដំណោះស្រាយ និង វាយតំម្លៃ។
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី ១
# ការរំលឹកទ្រឹស្តី

# ជំពូកទី ១
# ការរំលឹកទ្រឹស្តី

## ១.១. និយមន័យ

### ១.១.១. និយមន័យ ការអភិវឌ្ឍ

ការអភិវឌ្ឍតាមបែបសម័យទំនើប យល់ឃើញថាការអភិវឌ្ឍជាការធ្វើឲ្យប្រសើរឡើងនូវគុណភាពជីវិត និងជីវភាពរបស់ប្រជាជនដូចជា លទ្ធភាព ទទួលបានការអប់រំ ខ្យល់ស្អាត ទឹកស្អាត ការគាំពារសុខភាព ឪកាសការងារ លទ្ធភាពទទួលបាន និងគ្មានការគំរាមគំហែងផ្នែកឧក្រិដ្ឋកម្ម។[1]

ពាក្យអភិវឌ្ឍមានអត្ថន័យផ្សេងៗគ្នាទៅតាមន័យ និងទស្សនៈរបស់អ្នកប្រាជ្ញ ដែលបានរកឃើញ និងផ្លាស់ប្តូរអត្ថន័យទៅតាមការវិវត្តពីសម័យកាលមួយទៅ សម័យកាលមួយទៀតដោយមានលក្ខណៈប្រហាក់ប្រហែលគ្នាដែរ ប៉ុន្តែរក្សានូវទិសដៅតែមួយ ។ ដោយយោងតាមអក្សរសិល្ប៍ខ្មែរ ផ្អែកលើវចនានុក្រមដែលបានចងក្រងឡើងដោយសម្តេចសង្ឃ ជួន ណាត ពាក្យ "អភិវឌ្ឍន៍" មានន័យថាសេក្តីចំរើនក្រៃលែង ការលូតលាស់ចំរើនឡើង។ [2]

### ១.១.២. ការអភិវឌ្ឍជនបទ

ការអភិវឌ្ឍជនបទ គឺជាយុទ្ធសាស្ត្រមួយដែលរៀបចំឡើងដើម្បីលើកស្ទួយនៃកម្រិតជីវភាពរស់នៅ ខាងផ្នែកសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រជាពលរដ្ឋក្រីក្រនៅតាមតំបន់ក្រៅពីទីក្រុង។ អត្ថន័យមួយទៀត គឺជាសកម្មភាពមួយឬចម្រុះដែលមានទិសដៅលើកស្ទួយដល់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ។

ការអភិវឌ្ឍជនបទ គឺសំដៅលើការប្រែក្លាយពីទីជនបទទៅជាទីប្រជុំជន និងធ្វើឲ្យមានគម្លាតនៃការរស់នៅរវាងទីក្រុង និងជនបទមានកម្រិតទាបបំផុត តាមរយៈការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធជនបទ ការជួសជុល ការស្តារ និងថែទាំធ្វើយ៉ាងណាជួយលើកទឹកចិត្តដល់ប្រជាជន ដើម្បីជាឪកាសនៃការបង្កើនប្រាក់ចំណូលក្នុងគ្រួសារនៅតំបន់ជនបទ ក៏ដូចជាចូលរួមចំណែកជាមួយរដ្ឋាភិបាលក្នុងការកសាងសេដ្ឋកិច្ចជាតិ។ [3]

[1] សៀវភៅ សេដ្ឋកិច្ចអភិវឌ្ឍន៍ រៀបរៀងដោយបណ្ឌិត ជ្រឹង ហៃ និងបណ្ឌិត ទិន ហេង, បោះពុម្ពនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧, ទំព័រទី៤

[2] ជួនណាត វចនានុក្រមខ្មែរ ភាគទី១ ទី២ ភ្នំពេញ ពុទ្ធសាសនបណ្ឌិត១៩៦៧ ទំព័រ១៦៦៦

[3] មេរៀនក្នុងមុខវិជ្ជា អភិវឌ្ឍន៍ជនបទ របស់សាស្ត្រាចារ្យបណ្ឌិត ឈុន ពហុ ឆ្នាំសិក្សា ២០១៧ ២០១៨

### ១.១.៣. ហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធ គឺជាមធ្យោបាយ និងទំនាក់ទំនងផលិតកម្មដែលជាមូលដ្ឋាននៃសង្គម ដូចជា ផ្លូវ ស្ពាន ព្រែក ព្រលានយន្តហោះ រោងចក្រអគ្គិសនី។ [4]

ហេដ្ឋារចនាសម្ព័ន្ធ គឺជាពាក្យបច្ចេកទេសមួយ ដែលប្រើសម្រាប់រៀបរាប់អំពីមធ្យោបាយ ក៏ដូចជាគ្រឿងប្រដាប់សម្រាប់ ផ្គត់ផ្គង់ជីវភាពរស់នៅសម័យទំនើប របស់មនុស្សយើង។ ក្នុងនោះមានដូចជា បណ្តាញទឹក, គេហដ្ឋាន, ផ្លូវថ្នល់, សាលារៀន, មន្ទីរពេទ្យ, ព្រលានយន្តហោះ, អាគាររដ្ឋាភិបាល និងពាណិជ្ជកម្ម, ស្ពាន, ផ្លូវដែក ។ល។ ហើយហេដ្ឋារចនាសម្ព័ន្ធមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយស្តង់ដានៃការរស់នៅ និងចំនួនប្រជាជនដ៏ច្រើនលើសលប់។ គ្រប់ពេលចំនួនប្រជាជនកើនទ្វេ រចនាសម្ព័ន្ធ ក៏ត្រូវការកើនឡើងទ្វេដងដូចគ្នាដែរ ឬអាចលើសពីនេះ។ ប្រសិនបើប្រទេសនោះជាប្រទេសក្រីក្រ ហើយមានចំនួនប្រជាជនខ្ពស់ រដ្ឋាភិបាលនឹងមិនអាចផ្តល់នូវតម្រូវការ នៃរចនាសម្ព័ន្ធគ្រប់គ្រាន់នោះទេ។ ដូចនេះស្តង់ដានៃការរស់និងមានការធ្លាក់ចុះ ហើយអាចមានហានិភ័យខ្ពស់ជាងនេះ។ [5]

ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គឺសំដៅទៅលើហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានជាតម្រូវការរបស់សេដ្ឋកិច្ច ដើម្បីដំណើរការ និងរស់នៅដូចជា បណ្តាញគមនាគមន៍ ជាដើម។ [6]

### ១.១.៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ

ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធជនបទ ត្រូវបានគេមើលឃើញថាវាជាមធ្យោបាយដើម្បីធ្វើឲ្យប្រសើរឡើងនូវដំណើរការទំនិញ និងសេវាកម្មរបស់ប្រជាពលរដ្ឋនៅក្នុងការប្រកបរបរចិញ្ចឹមជីវិត ហើយវាក៏ជាមធ្យោបាយមួយដើម្បីកាត់បន្ថយភាពក្រីក្រដែរ។ ទន្ទឹមនឹងនេះដែរ លំនាំនៃការទទួលខុសត្រូវ និងសិទ្ធិអំណាច គឺពិតសំខាន់ណាស់សម្រាប់ការធ្វើការសម្រេចចិត្តក្នុងតំបន់ និងការអភិវឌ្ឍអភិបាលកិច្ចល្អ។ ហើយការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទនេះ គឺជាកត្តាគន្លឹះក្នុងការបង្កើនអានុភាពយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។ ម្យ៉ាងវិញទៀត ការទទួលខុសត្រូវសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅជនបទ នឹងត្រូវបានគេយកចិត្តទុកដាក់កាន់តែខ្លាំងឡើង នៅក្នុងការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់តំបន់។ នេះគឺជាការបង្ហាញពីឱកាសដ៏ល្អបំផុតដើម្បី

[4] ដកស្រង់ចេញពីសៀវភៅ សន្ទានុក្រមពាក្យថ្មី(សាស្ត្រាចារ្យ ទូច គឹមស្រ៊ាង សមាក្រុមប្រឹក្សា)

[5] https:/km.m.wikipedia.org/wiki/ហេដ្ឋារចនាសម្ព័ន្ធ

[6] Khmerdict.wordpress.com

បង្កើនការពឹងផ្អែកលើធនធានក្នុងស្រុកលើការខិតខំរបស់ប្រជាជន ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងភាពក្រីក្រ និងដើម្បីបង្កើតការងារក្នុងស្រុក។ [7]

## ១.២. ទិសដៅនៃការអភិវឌ្ឍជនបទ

### ១.២.១. រចនាសម្ព័ន្ធសេដ្ឋកិច្ចជនបទ

បញ្ជាក់ពីសក្តានុពលនៃតំបន់ជនបទ និងកាត់បន្ថយបាននូវសមាមាត្រផលិតផលកសិកម្ម និងបង្កើតបាននូវសមាមាត្រឧស្សាហកម្មជនបទ កំណត់បានទិសដៅអភិវឌ្ឍន៍លើកស្ទួយជីវភាពគ្រួសារ និងបញ្ជាក់ពីកំណើនវិស័យផ្សេងៗក្នុងទីជនបទ។

### ១.២.២. ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

ប្រព័ន្ធនេះ គឺជាមូលដ្ឋានចម្បាងមួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទតាមរយៈប្រព័ន្ធគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី ប្រព័ន្ធទឹកស្អាត ផ្ទះសំបែង ទំនាក់ទំនងពត៌មាន និងមជ្ឈមណ្ឌលវប្បធម៌ សុខមាលភាពសង្គមផ្សេងៗ។ ទិសដៅអភិវឌ្ឍន៍ហេដ្ឋារចនសម្ព័ន្ធតាមទិសដៅ ឧស្សាហូបនីយកម្មទំនើបភាវូបនីកម្ម។ រវាងទីក្រុង និងជនបទក្នុងការងារផលិតផល និងការងារចរាចរណ៍ទំនិញកសិផល។

### ១.២.៣.អនុវត្តន៍វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

អនុវត្តន៍ប្រព័ន្ធសមស្របតាមពូជរដូវស្រូវ ពូជដំណាំ ពូជសត្វ និងអនុវត្តន៍ប្រព័ន្ធមធ្យោបាយពលកម្មសមស្របដោយប្រើបច្ចេកវិទ្យា និងវិទ្យាសាស្ត្រការពារ និងប្រើប្រាស់ (ធនធានដីធ្លី) បរិស្ថានគ្រប់គ្រងសង្គម។

### ១.២.៤.ប្រាក់ចំណូលនិងកម្រិតជីវភាពរស់នៅ

លើកកម្ពស់ប្រាក់ចំណូលតាមរយៈប្រភពចំណូលពីមុខរបរកសិកម្ម (On Farm) និងប្រភពចំណូលពីមុនរបរក្រៅកសិដ្ឋាន(Off Farm) ឬមុខរបរមិនមែនកសិកម្ម (Non Farm) ដោយបង្កើនរដូវដាំដុះបង្កើនបរិមាណ និងប្រភេទសត្វចិញ្ចឹមផ្សេងទៀត បង្កើនប្រព័ន្ធវារីវប្បកម្ម និងបង្កើនវប្បកម្មជនបទ។

### ១.២.៥. ការងារ អប់រំ សុខាភិបាល និងវប្បធម៌

អភិវឌ្ឍន៍វិស័យអប់រំឲ្យខ្លាំងក្លានៅតាមជនបទ និងពង្រីកបណ្តាញសុខាភិបាលគ្រប់ជ្រុងជ្រោយនៅទីជនបទ។ មានពង្រឹង និងការពង្រីកបណ្តាញវប្បធម៌នៅទីជនបទតមរយៈវិទ្យុផ្សាយ

[7] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា គំរោងកែលំអហេដ្ឋារចនាសម្ព័ន្ធដើម្បីអភិវឌ្ឍន៍ជនបទ របស់និស្សិត ឈិន ប៊ុនណារ៉ាណិច ឆ្នាំ ២០១៤ ទំព័រទី៧

សំឡេង សកម្មភាពសិល្បៈ សារព័ត៌មាន និងកីឡា។ ដើម្បីលើកកម្ពស់ចំណេះដឹងរបស់កសិករបង្ក រលក្ខណៈឲ្យពួកគាត់កាន់តែមានភាពងាយស្រួលស្រូបយកគុណធម៌ថ្លៃថ្នូរ និងសីលធម៌រស់នៅស្អាតស្អំ។ [8]

## ១.៣. ទស្សនរបស់អ្នកប្រាជ្ញ

### ១.៣.១.ទ្រឹស្តី Michael P. Todaro

ការអភិវឌ្ឍអាចកើតឡើង និងប្រកបដោយចីរភាព វាត្រូវចាប់ផ្តើមពីតំបន់ជនបទ ជាពិសេសនៅក្នុងវិស័យកសិកម្ម។ នេះជាទ្រឹស្តីរបស់លោក Michael P. Todaro ដែលលោកបានលើកឡើងថា ប្រជាជាតិមួយអាចទៅដល់ការអភិវឌ្ឍយ៉ាងហោចណាស់មានកត្តាចំនួនបីយ៉ាងដូចខាងក្រោម៖

ក.ការពន្លឿនអត្រាកំណើនតាមរយៈការធ្វើកំណែទំរង់ថ្លៃស្ថាប័ន និងបច្ចេកវិទ្យាដែលត្រូវបានរៀបចំឡើងដើម្បីបង្កើនផលិតភាពសម្រាប់កសិករតូចតាច។

ខ.បង្កើនតំរូវការក្នុងស្រុកសម្រាប់ផលិតផលកសិកម្ម ដែលមានប្រភពមកពីយុទ្ធសាស្ត្រអភិវឌ្ឍការងារតំបន់ជាយក្រុង។

គ.សកម្មភាពអភិវឌ្ឍជនបទដើម្បីពង្រីកកម្លាំងពលកម្មមិនមែនកសិកម្ម និងវិស័យដទៃផ្សេងៗទៀតដែលគាំទ្រដោយផ្ទាល់ឬប្រយោលពីសហគមន៍កសិកម្ម។[9]

### ១.៣.២. ទ្រឹស្តី Robert Me Namara

លោក Robert Me Namara បានពន្យល់ថា ការអភិវឌ្ឍគឺជាការផ្តល់នូវសេចក្តីត្រូវការរបស់មនុស្សជាមូលដ្ឋានពិសេសអ្នកទីទាល់ក្រ។ សេចក្តីត្រូវការជាមូលដ្ឋានរបស់មនុស្សរួមមានចំណីអាហារ អាហារូបត្ថម្ភគ្រប់គ្រាន់ ជៀសវាងនូវការទទួលទានមិនគ្រប់គ្រាន់ដែលនាំឲ្យមានឥទ្ធិពលដល់ការរស់នៅប្រចាំថ្ងៃ។ ទីជំរក សំលៀកបំពាក់ គឺសម្រាប់ការពារជីវិត និងសម្រាប់ទប់ទល់និងអាកាសធាតុ និងបរិស្ថានផ្សេងៗ។ សេវាកម្មសាធារណៈសមស្របបំរើដល់ការអប់រំទឹកស្អាត និងការថែទាំសុខភាពដែលផ្តល់ផលប្រយោជន៍ច្រើនដល់មនុស្សជាតិគ្រប់ៗគ្នា និងសមាជិកក្នុងតំបន់អភិវឌ្ឍរបស់ពួកគេ។

[8] សារណាបញ្ចប់ការសិក្សា ការសិក្សាអំពីកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ, របស់និស្សិត យិន ឡូត ឆ្នាំ២០១៦ ទំព័រទី៨

[9] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា គំរោងកែលំអហេដ្ឋារចនាសម្ព័ន្ធជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ របស់និស្សិត យិន សុភា, ឈាក ពិសិដ្ឋ, ហាក់ បុប្ផាវ័ត្ត ឆ្នាំ ២០០៦ ទំព័រទី៧

សរុបសេចក្តីមកការអភិវឌ្ឍសំដៅទៅលើការកែលម្អជីវភាពរស់នៅ រួមមានប្រាក់ចំណូល សកម្មភាពផលិតកម្ម ការអប់រំ អាហារូបត្ថម្ភ សុខភាព ជំរក និងសេវាកម្មរស់នៅយូរអង្វែងព្រម ជាមួយសុខមាលភាពនៃសង្គមផ្សេងៗ។ រីឯកត្តាដែលជះឥទ្ធិពលដល់ការកែលម្អកម្រិតសុខមាល ភាពគឺមិនត្រឹមតែគិតពីប្រាក់ចំណូលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវរាប់បញ្ចូលទាំងសន្តិសុខក្នុងការ ផ្គត់ផ្គង់ស្បៀង ផ្តល់ការអប់រំតាមតម្រូវការផ្តល់សេវាសុខភាពបានគ្រប់គ្រាន់ ទឹកស្អាត ផ្លូវលំ ឥណ ទាន និងផ្នែកផ្សេងៗទៀតដែលចាំបាច់។[10]

**១.៣.៣ ទ្រឹស្តីរបស់លោក Wait Withman Rostow**

លោក **Wait Withman Rostow** បានវែកញែកដំណាក់កាលសំខាន់ៗរបស់រចនាសម្ព័ន្ធនៅ ក្នុងការអភិវឌ្ឍជាដំណាក់កាល ដោយលោកបានអះអាងថាគ្រប់ប្រជាជាតិអាចឈានដល់កម្រិត អភិវឌ្ឍ ប្រសិនបើគេដើរតាមគន្លងប្រទេសអភិវឌ្ឍ ហើយរក្សាលក្ខណៈក្នុងការជានាឲ្យមាន កំណើនសេដ្ឋកិច្ចបានយូរអង្វែង។

ទ្រឹស្តីនេះបានចែកចេញជាប្រាំដំណាក់កាលផ្សេងៗគ្នានៃការអភិវឌ្ឍៈ

- សង្គមប្រពៃណីៈ គឺជាសង្គមដែលគ្មានកំណើនទាស់តែសោះ ហើយការផលិតធ្វើ ឡើងតែរៀងៗខ្លួន ដូច្នេះផលដែលទទួលបានមានកម្រិតទាប។ ប្រជាជនយករបរ កសិករជាវិស័យចម្បងក្នុងការផលិត ហើយពួកគេគ្មានគំនិតក្នុងការផ្លាស់ប្តូរអ្វីទាំង អស់គឺបណ្តោយតាមយថាកម្ម។
- លក្ខណៈដែលធ្វើឲ្យមានការអភិវឌ្ឍៈ វានឹងទៅដល់ការរួមបញ្ចូលឥទ្ធិពលពិត ប្រាកដ ដែលធ្វើឲ្យមានផលចំណេញសង្គម ហើយការផ្លាស់ប្តូរនេះត្រូវបានដាក់ ចេញមានដូចជា ការពង្រីកហេដ្ឋារចនាសម្ព័ន្ធ ការធ្វើឲ្យមានការកើនឡើងនូវបច្ចេក វិទ្យា និងការធ្វើឲ្យប្រជាជនមានភាពម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ ព្រមទាំងធ្វើឲ្យ កើនឡើងនៃសន្សំ និងវិនិយោគ។
- ដំណាក់កាលនៃការកើនឡើងនៃការអភិវឌ្ឍៈ រួមមានវិស័យអាទិភាពនៃសេដ្ឋកិច្ច បានចាប់កំណើត និងរីកធំធាត់ជាលំដាប់ កំណើនសេដ្ឋកិច្ចក្លាយជាបញ្ហាសាមញ្ញ អាចរក្សាបានដោយស្វ័យប្រវត្តិនូវស្ថេរភាពដល់សេដ្ឋកិច្ច។ ប្រសិនបើប្រទេសណា មានលក្ខណៈដូចខាងលើ ប្រទេសនោះត្រូវបានគេចាត់ថាជាឧស្សាហកម្មថ្មីដោយ

[10] សារណាបញ្ចប់ការសិក្សា ការសិក្សាអំពីកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ, របស់និស្សិត យិន ឡូត ឆ្នាំ២០១៦ ទំព័រទី៥

ពឹងផ្អែកលើភាពខ្លាំងក្លានៃអត្រាវិនិយោគ អាទិភាពនៃនយោបាយ ស្ថាប័នដែលនាំឲ្យមានការរំកិលនៃកំណើនសេដ្ឋកិច្ច និងការបង្កើតនូវឧស្សាហកម្មសំខាន់ៗដើម្បីជាការផ្លាស់ប្តូរ។

- ដំណាក់កាលទុំ៖ ការអភិវឌ្ឍបានចូលទៅគ្រប់ច្រកល្ហកនៅទូទាំងប្រទេស ជាពិសេស គឺ វិស័យថ្មីៗនៃផលិតកម្មនៃការលេចឡើងជារចនាសម្ព័ន្ធនៃការផលិតបានចេញ ជាវិស័យកសិកម្ម និងឧស្សាហកម្ម។ ការអភិវឌ្ឍចេះតែឈានទៅមុខ ឧស្សាហកម្មដែលមានវិស័យចំណាស់ត្រូវបានផ្លាស់ប្តូរចេញឲ្យវាមានភាពកាន់តែទំនើបថែមទៀត ឬវិស័យឧស្សាហកម្មថ្មី។
- ដំណាក់កាលនៃបម្រើបម្រាស់នៃទ្រង់ទ្រាយធំ៖ ការផលិតទំនិញ និងសេវាកម្មក្នុងគោលបំណងប្រើប្រាស់ចុងក្រោយ ត្រូវបានធ្វើនៅក្នុងវិស័យឧស្សាហកម្មនៃការផលិតទំនិញ។ ដោយសារតែប្រាក់ចំណូលរបស់ប្រជាជនមានការរីកចម្រើន បានអនុញ្ញាតឲ្យមានការប្រើប្រាស់ក្នុងទ្រង់ទ្រាយធំនៃទំនិញ ដែលមានភាពចាំបាច់។ នៅក្នុងចំណុចនេះគឺគេអាចនិយាយបានថា ការអភិវឌ្ឍកំពុងចាប់ផ្តើមដំណើរការខ្លាំងព្រោះថាត្រង់ចំណុចកើនឡើងធ្វើឲ្យ៖
  - សេចក្តីត្រូវការជាមូលដ្ឋានត្រូវបានគេដោះស្រាយជាស្ថាពរ
  - មានការរីកចម្រើនលើវិស័យសុខុមាលភាពក្នុងសង្គម
  - អំណាចសេដ្ឋកិច្ចត្រូវបានពង្រីក

លោក **Wait Withman Rostow** បានយកចិត្តទុកដាក់ខ្លាំងលើការរីកសាយភាយនៃគ្រឿងយន្តដែលមានតម្លៃថោក ដែលធ្វើឲ្យមានឥទ្ធិពលជីវិតនៃសង្គម ការបែងចែកប្រាក់ចំណូលថ្មី ការបង្កើតប្រព័ន្ធគម្រោងទុកនៃសង្គម។[11]

### ១.៣.៤. ទ្រឹស្តី Big Push

អ្នកដែលបង្កើតទ្រឹស្តីនេះឡើងគឺលោក Paul Rosenstein-Rodan នៅក្នុងឆ្នាំ ១៩៤៣ បន្ទាប់មកនៅឆ្នាំ ១៩៨៩ លោក Murphy និង Robert W. Vishny បានយកម៉ូដែលសេដ្ឋកិច្ចនេះមកវិភាគនៅក្នុងទ្រឹស្តីល្បែង (Game Theory) ទៀតផង។

Big Push គឺជាទ្រឹស្តីដែលបង្ហាញអំពីកត្តាដែលធ្វើឲ្យប្រទេសនីមួយៗមានកំណើនសេដ្ឋកិច្ចតាមរយៈការបង្កើននូវវិនិយោគឲ្យកាន់តែច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអប់រំ រួមផ្សំ

[11] Rostow's stage of Growthដកស្រង់ចេញពីសៀវភៅ Michael P.TodaraEconomic Development, Eight Edition

នឹងការវិនិយោគជាលក្ខណៈឯកជន វានឹងអាចធ្វើឲ្យកើនឡើងនូវផលិតភាពក្នុងការផលិតទំនិញ និងសេវា។

ហើយទ្រឹស្តី Big Push នេះក៏ជាទ្រឹស្តីមួយនៅក្នុងសេដ្ឋកិច្ចអភិវឌ្ឍ ឬសេដ្ឋកិច្ចទីផ្សារសេរី ដែលនិងផ្តោតសំខាន់ទៅលើការសម្រេចចិត្តរបស់សហគ្រាស ឬក្រុមហ៊ុនមុននឹងធ្វើអ្វីមួយ ឬក៏មិនធ្វើវាមិនអាស្រ័យលើការសម្រេចចិត្តរបស់សហគ្រាស ឬក្រុមហ៊ុនផ្សេងទេ។ នៅពេលដែលសហគ្រាស ឬក្រុមហ៊ុនទាំងនោះរំពឹងទុកនឹងទទួលបានផលចំណេញពួកគេនឹងធ្វើសកម្មភាពអាជីវកម្ម និងឧស្សាហកម្មរបស់ពួកគេ។ [12]

### **១.៣.៥. ទ្រឹស្តីរបស់លោក Francios Perrux**

លោកបានឲ្យនិយមន័យនៃការអភិវឌ្ឍ គឺជាការចូលរួមផ្សំនៃការផ្លាស់ប្តូរគំនិត និងសង្គមរបស់ប្រជាជនមួយក្រុមដែលការផ្សំនោះផ្តល់មកវិញកំណើនផ្ទួនៗ និងភាពស្ថិតស្ថេរនៃផលិតផលសរុបពិតរបស់ពួកគេ។ ដូច្នេះហើយការអភិវឌ្ឍជាដំណើរការពហុមាត្រដ្ឋានដែលតម្រូវឲ្យមានការផ្លាស់ប្តូរទាំងបរិមាណ និងគុណភាព។ ការអភិវឌ្ឍសង្គម គឺធ្វើយ៉ាងណាឲ្យមានការរីកចំរើនលឿនលើវិស័យជាច្រើនដូចជា នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌។ ជាពិសេសធ្វើឲ្យមានយុត្តិធម៌ក្នុងសង្គមទាំងមូលទៀតផង និងលុបបំបាត់អំពើពុករលួយ កាត់បន្ថយបាននូវភាពក្រីក្រ និងការពារបរិស្ថាន។

ការអភិវឌ្ឍជនបទ ជាការផ្លាស់ប្តូរ ក៏ដូចជាការប្រែក្លាយពីទីជនបទឲ្យទៅជាទីប្រជុំជន និងធ្វើឲ្យគម្លាតកាន់តែតិចទៅរវាងអ្នកដែលរស់នៅទីក្រុង និងអ្នកដែលរស់នៅតំបន់ជនបទ ការកសាង ក៏ដូចជាការជួសជុល និងការកែលំអនូវបណ្តាហេដ្ឋារចនាសម្ព័ន្ធជនបទដែលជាការលើកស្ទួយ និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ដែលរស់នៅតំបន់ជនបទជៀសវាងការធ្វើចំណាក់ស្រុកពីជនបទមកទីក្រុងក្នុងលក្ខណៈច្រើន និងនាំឲ្យមានបញ្ហាជាច្រើនក្នុងសង្គមដែលមានដូចជា តំបន់ជនបទខ្វះកម្លាំងកសិកម្ម ទីក្រុងមានមនុស្សច្រើនកកកុញធ្វើឲ្យអ្នកគ្មានការងារធ្វើកើនឡើងកាន់តែខ្លាំង ដែលអាចនាំទៅរកបញ្ហាសង្គមផ្សេងៗ។[13]

## **១.៤. កត្តាសំខាន់ៗដែលធ្វើឲ្យមានការអភិវឌ្ឍ និងឧបសគ្គដល់ការអភិវឌ្ឍ**

### **១.៤.១. កត្តាសំខាន់ៗដែលធ្វើឲ្យមានការអភិវឌ្ឍ**

[12] មេរៀនក្នុងមុខវិជ្ជា កំណើនសេដ្ឋកិច្ច របស់សាស្ត្រាចារ្យ ហាស់ វង់ដារ៉ា ឆ្នាំសិក្សា ២០១៧ ២០១៨, ទំព័រទី ៥៩

[13] Prof. Dr. DUY CHANDINA, Economic Development, Academic year 2013-2014, page 6

បើយោងតាមការសិក្សាស្រាវជ្រាវទៅលើទស្សនៈវិទូជាច្រើនយើងឃើញថា តួនាទីពលកម្ម និងមូលធនជាស្នូលដែលជម្រុញឲ្យមានការអភិវឌ្ឍ។ ក៏ប៉ុន្តែក្រៅពីកត្តាទាំងពីរខាងលើនេះដំបូង គេចាប់អារម្មណ៍ទៅលើកត្តាធនធានធម្មជាតិ ដែលជាកត្តាសំខាន់តែមួយក្នុងការអភិវឌ្ឍដោយផ្អែក លើពេលវេលានិងការរកឃើញថ្មីៗដ៏ទៃទៀតដូចជាកត្តារចនាសម្ព័ន្ធជាដើម។

**១.៤.១.១. កត្តាធនធានធម្មជាតិ**

ធនធានធម្មជាតិមានប្រភពមកពីបួនកន្លែងនៅលើសកលលោកយើងនេះគឺ នៅលើដី នៅលើអាកាស ក្រោមដី និងក្នុងទឹក។ ធនធានធម្មជាតិទាំងនេះត្រូវបានគេចាត់ទុកជាវត្ថុដ៏មានតម្លៃបំផុតនៅលើលោកនេះ ដោយសារតែធនធានធម្មជាតិត្រូវបានគេយកមកកែច្នៃដើម្បីផលិតនូវផលិតផលសម្រេចនានា ដើម្បីផ្គត់ផ្គង់ការរស់របស់មនុស្សផង និងដើម្បីអភិវឌ្ឍលើគ្រប់វិស័យរបស់ស្ថាប័នប្រទេសផង។ ធនធានធម្មជាតិក៏មានតួនាទីយ៉ាងសំខាន់ផងដែរសម្រាប់ការអភិវឌ្ឍ ក៏ដូចជាការកែប្រែមុខមាត់នៃបណ្តាប្រទេសដែលជាសមាជិកអង្គការ OPEC ( Organization of Petroleum Exporting Countries) ឲ្យក្លាយពីប្រទេស កំពុងអភិវឌ្ឍបានដោយប្រើប្រាស់នូវធនធានប្រេងដែលបានបូមពីធម្មជាតិនេះឯង ដែលប្រទេសទាំងនោះរួមមានដូចជា ប្រទេសប្រុយណេ អារ៉ាប់ប៊ីសាអ៊ូឌីត វេណេស្វូអេឡា និងប្រទេសអ៊ីរ៉ាក់ជាដើម។

**១.៤.១.២. កត្តាធនធានមនុស្ស**

កត្តាធនធានមនុស្ស ជាកត្តាមួយក្នុងការអភិវឌ្ឍស្ថិតក្នុងគោលបំណងដើម្បីមនុស្ស និងសង្គមមនុស្ស។ ម្យ៉ាងទៀតមានមនុស្សមានគំនិតច្រើនក្នុងការអភិវឌ្ឍន៍ មានមនុស្សគឺមានតម្រូវការ។ ដូចនេះមនុស្សច្រើន នាំឲ្យមានតម្រូវការច្រើន ហើយផលិតកម្មដើម្បីបំពេញសេចក្តីត្រូវការរបស់មនុស្សក៏ច្រើនដែរ។ អ្វីដែលសំខាន់ជាងនេះទៅទៀតគឺ មនុស្សជាកម្លាំងពលកម្មដែលជាកត្តាផលិតកម្មក្នុងវិស័យផលិតកម្ម មិនថាវិស័យកសិកម្ម ឧស្សាហកម្ម ឬសេវាកម្មឡើយ គឺចូលរួមគ្រប់សកម្មភាពផលិត ដែលជាកត្តាសំខាន់មួយក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច។

ចំពោះកត្តាមនុស្សនេះ មានការសិក្សានិងសំណួរដែលមានការចោទឡើងជាច្រើនអំពីកត្តាពលកម្មក្នុងការអភិវឌ្ឍន៍។ កម្រិតសម្តតភាពពលកម្មពោលគឺ ធនធានមនុស្សតែងតែមានភាពខុសប្លែកពីគ្នារវាងបណ្តាប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍ។ តាមទ្រឹស្តីរបស់លោក គាត់យល់ថាដំបូងពលកម្មរបស់មនុស្សដែលធ្វើឡើង ឬផលិតអ្វីមួយកើតឡើង គឺក្នុងគោលបំណងត្រឹមតែបំពេញសេចក្តីត្រូវការសម្រាប់ជីវិតប៉ុណ្ណោះ ពោលគឺធ្វើពលកម្មដើម្បីចិញ្ចឹមជីវិតខ្លួនឯងដោយគ្មានផលកម្រៃពីអ្នកដទៃឡើយ ដែលវាមានន័យថាទាញយកផលប្រយោជន៍ពីធម្មជាតិទៅតាម

លទ្ធភាពដែលខ្លួនអាចធ្វើបាន។ លុះក្រោយមកដោយមានការវិវត្តន៍ទាំងផ្នែកខួរក្បាល និងបច្ចេកវិទ្យាបានធ្វើឲ្យមនុស្សភាគច្រើនបង្វែរទិសពីការចិញ្ចឹមជីវិតដោយធម្មជាតិងាកទៅរកការកែច្នៃ និងបង្កើតការប្រើនូវកម្លាំងពលកម្មតូចតាចឲ្យទៅជាការប្រើកម្លាំងពលកម្ម ដែលមានជំនាញច្បាស់លាស់ និងមានគុណភាព។

**១.៤.១.៣. កត្តាមូលធន**

នៅក្នុងដំណើរការអភិវឌ្ឍ ក្រៅពីប្រភពធនធានធម្មជាតិ និងកត្តាមនុស្សយោងនូវមានកត្តាមូលធនមួយទៀត ដែលកត្តានេះឯងក៏មានសារៈសំខាន់ដែរ ដោយមូលធនគឺជាប្រភពដែលនាំឲ្យមានឧបករណ៍ទំនើបៗដោយអាចបង្កើតកត្តាផលិតកម្មឲ្យកាន់តែខ្លាំងបន្ថែមទៀត នប្រកបដោយគុណភាពល្អថែមទៀតផង។ ហើយកត្តាមូលធនក៏ជាប្រភពចាំបាច់មួយសម្រាប់ការចាប់ផ្តើមអភិវឌ្ឍន៍ផងដែរ ដោយសារតែមូលធនត្រូវបានគេចាត់ទុកថាឧបករណ៍ស្នូលសម្រាប់ចរាចរណ៍ដោះដូរទំនិញនានាដែលទាំងនេះ ហើយទើបមូលធនបានក្លាយជាប្រភពនៃតម្រូវការចាំបាច់មួយសម្រាប់មនុស្ស ប្រភពនៃតម្រូវការនេះបាននាំឲ្យមានលក្ខខណ្ឌដោះដូរមួយគឺថា មានចំណូលទើបមានការបញ្ចេញនូវកម្លាំងពលកម្មរបស់មនុស្សដើម្បីអភិវឌ្ឍន៍ ឬកែប្រែអ្វីមួយនៅក្នុងសង្គម។

ចំពោះការកើនឡើងនៃមូលធនចេញជាលទ្ធផលនេះ គឺនៅពេលដែលសមាមាត្រនៃចំណូលបច្ចុប្បន្នត្រូវបានសន្សំ និងវិនិយោគដើម្បីធ្វើឲ្យកើនឡើងនូវទិន្នផល និងប្រាក់ចំណូលនៅពេលអនាគត។ រោងចក្រថ្មីៗ គ្រឿងម៉ាស៊ីន សម្ភារៈបរិក្ខា និងវត្ថុធាតុដើមបង្កើតនូវស្តុកមូលធនរូបវន្តនៃជាតិមួយ ( សរុបតម្លៃជាក់ស្តែងនៃការផលិតភាពមូលធន ទំនិញរូបវន្តទាំងអស់) ហើយការកើនឡើងនៃមូលធន នឹងធ្វើឲ្យមានលទ្ធភាពពង្រីកទិន្នផលដើម្បីសម្រេចគោលបំណង។ ការវិនិយោគផ្ទាល់ដែលឲ្យផលនេះ គឺត្រូវបានបន្ថែមដោយការវិនិយោគទៅលើអ្វីដែលត្រូវបានគេស្គាល់នៅក្នុងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមដូចជា ផ្លូវថ្នល់ អគ្គិសនី ទឹកស្អាត ការទាក់ទងនឹងការសម្របសម្រួលគ្នាក្នុងសកម្មភាពសមាហរណកម្មសេដ្ឋកិច្ច។

**១.៤.១.៤. កត្តារចនាសម្ព័ន្ធ**

ក្រៅពីកត្តាទាំងបីខាងលើ កត្តារចនាសម្ព័ន្ធជាផ្នែកមួយសំខាន់ដែរក្នុងការកំណត់ទិសដៅ និងខ្សែបន្ទាត់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ក៏ដូចជាប្រទេសជាតិផងដែរ។ រចនាសម្ព័ន្ធនយោបាយ ស្ថេរភាពសង្គម និងលទ្ធប្រជាធិបតេយ្យជាកូនសោរដ៏សំខាន់ព្រោះថាបើកាលណាប្រទេសជាតិមួយពោរពេញទៅដោយស្ថេរភាពសង្គម និងនយោបាយ នោះការអភិវឌ្ឍនឹងមានកំណើនយ៉ាងឆាប់រហ័សជាក់ជាពុំខាន។

កត្តាទាំងនេះហើយដែលជម្រុញឲ្យដល់ដំណើរការអភិវឌ្ឍន៍ ប៉ុន្តែការអភិវឌ្ឍជាទូទៅពុំអាចធ្វើឲ្យមានភាពស្មើភាពនៅគ្រប់ទីកន្លែងឡើយ ហើយជាពិសេសការអភិវឌ្ឍនៅបណ្តាប្រទេសតតិយលោក ឬប្រទេសកំពុងអភិវឌ្ឍតែម្តង គឺដោយសារភាពក្រីក្រ និងកំណើនប្រជាជនហួសហេតុព្រមជាមួយការអប់រំនៅមានកម្រិតទាបក្នុងប្រទេសទាំងនោះ។[14]

### ១.៤.២. កត្តាដែលជាបញ្ហាដល់ការអភិវឌ្ឍ

ការធ្វើឲ្យរាំងស្ទះដល់កិច្ចដំណើរការរីកចម្រើននៅលើហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច ឬស្ថាប័ននៃប្រទេសណាមួយនីមួយៗ មានន័យថាជាការរំខានដល់កិច្ចដំណើរការអភិវឌ្ឍន៍នៃប្រទេសនោះ។

តើមានឧបសគ្គអ្វីខ្លះដែលរាំងស្ទះដល់ការអភិវឌ្ឍ?

#### ១.៤.២.១. ភាពក្រីក្រ

ភាពក្រីក្រ ត្រូវបានគេចាត់ថាជាអ្នកបំផ្លិចបំផ្លាញបរិស្ថានដ៏ធ្ងន់ធ្ងរបំផុត នៅលើលោកយើងនេះ។ ហើយភាពក្រីក្រទាំងនេះ ត្រូវបានគេចាត់ទុកជា អ្នកធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍន៍ផងដែរ ដោយសារតែភាពក្រីក្រ ឬហៅថាក្រស្ទើរដាច់ពោះ នោះបានធ្វើឲ្យពួកគេចំណាយធនធានដ៏មានតម្លៃដែលពួកគេមានដូចជា ព្រៃឈើ បរិស្ថានធ្វើជាថ្នូរដោះដូរនឹងចំណីអាហារមួយចំអែតតែប៉ុណ្ណោះ ជាក់ស្តែងដូចជាតំបន់ Sao Pulo របស់ប្រទេសប្រេស៊ីល ទីនោះត្រូវបានគេចាត់ទុកថាជាតំបន់ដែលទទួលរងការបំពុលបរិស្ថានខ្លាំងខ្លាបំផុត និងជាកន្លែងមួយពិបាកក្នុងការអភិវឌ្ឍន៍ដែរ ដើម្បីរស់ពួកគេសុខចិត្តកាប់បំផ្លាញធនធានធម្មជាតិដ៏មានតម្លៃរបស់ពួកគេ ដូចជាឈើល្អៗមួយចំនួនដើម្បីយកមកធ្វើជាអុសសម្រាប់ចម្អិនអាហារតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតបើផ្អែកលើទ្រឹស្តីរបស់ពួក Classic ថាភាពក្រីក្រជាកត្តាមួយធ្វើឲ្យមានការសន្សំទាប ការសន្សំទាបនោះធ្វើឲ្យមានការវិនិយោគទាបដែរ (ការវិនិយោគលើសម្ភារៈ និងមិនមែនសម្ភារៈ) ព្រោះសន្សំជាប្រភពនៃការវិនិយោគ កង្វះវិនិយោគធ្វើឲ្យមានផលិតកម្មទាប ធ្វើឲ្យប្រាក់ចំណូលទាប។ ចំណែកពួក Keynes យល់ថានៅពេលដែលក្រធ្វើឲ្យមានតម្រូវការទាបដែលនាំឲ្យមានទីផ្សារតូច ធ្វើឲ្យកង្វះការវិនិយោគនាំឲ្យផលិតកម្មទាប ចុងបញ្ចប់ធ្វើឲ្យប្រាក់ចំណូលទាប។ បញ្ហាប្រាក់សន្សំ ការវិនិយោគ និងមូលធនគឺជា

[14] និស្សិត ហាម ខេមរិទ្ធ, របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា, ប្រធានបទ៖ ការអភិវឌ្ឍផ្លូវលំជនបទ(សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១០) ទំព័រទី ៩

បញ្ហាដែលរាំងស្ទះដល់ការអភិវឌ្ឍ បញ្ហាទាំងនេះគឺតែងតែកើតមានឡើងចំពោះតំបន់ដែលក្រីក្រទាំងអស់។

### ១.៤.២.២. អត្រាកំណើនប្រជាជនខ្ពស់

យោងតាមការអង្កេតរបស់សេដ្ឋកិច្ចវិទូជាច្រើនបានឲ្យដឹងថា នៅក្នុងប្រទេសតតិយលោក អត្រាកំណើនប្រជាជនមានការកើនឡើងលឿនជាងពីរដង ច្រើនជាងប្រទេសអភិវឌ្ឍន៍ដែលកត្តានេះបានធ្វើឲ្យមានការរាំងស្ទះដល់ការអភិវឌ្ឍន៍ក្នុងប្រទេសក៏ដូចជាតំបន់ដែរ។ មូលហេតុនៃការកើនឡើងលឿននេះ បណ្តាលមកពីការប្រកាន់ទំនៀមទំលាប់ដ៏ចាស់គម្រិលរបស់ប្រទេសតតិយលោកមួយចំនួនដូចជាមនុស្សមានអាយុក្រោមដប់ប្រាំបីឆ្នាំ ចាស់ទុំមានការគិតគូររៀបអាពាហ៍ពិពាហ៍ទាំងវ័យក្មេងខ្ចី។ ការធ្វើដូចនេះវាមានលក្ខណៈផ្ទុយយ៉ាងស្រលះទៅនឹងប្រទេសមួយចំនួនដែលកំពុងអភិវឌ្ឍដែលកាត់បន្ថយអត្រាកំណើតប្រជាជន។

កំណើនប្រជាជនខ្ពស់អាចជះឥទ្ធិពលដល់ការសន្សំ និងការវិនិយោគចំពោះគ្រួសារដែលមានសមាជិកច្រើន គេមិនសូវមានការសន្សំប៉ុន្មានទេ ដោយសារតែចំណូលដែលបានរកបានត្រូវបានបែងចែកលើការចំណាយផ្សេងៗជាច្រើន ដែលធ្វើឲ្យការសន្សំមានតិចតួច ឬក៏គ្មានតែម្តង។

ការជះឥទ្ធិពលលើផលិតភាពកើត នៅពេលដែលមានចំនួនប្រជាជនមានការកើនឡើងខ្លាំង គេចាំបាច់ត្រូវទាក់ទាញវិស័យវិនិយោគឲ្យមានការកើនឡើងផងដែរ ដើម្បីឲ្យមានកំណើតផលិតភាព បើពុំដូច្នេះទេ ប្រជាពលរដ្ឋមួយចំនួននឹងអត់ការងារធ្វើជាមិនខាន។

កំណើនប្រជាជនអាចប៉ះពាល់ដល់ទីក្រុង នៅពេលដែលមានកំណើនប្រជាជនខ្លាំងវាក៏ជះឥទ្ធិពលដល់អាក្រក់ដល់ទីក្រុងដោយមានមនុស្សកកកុញនៅទីក្រុង និងមានបញ្ហាជាច្រើនកើតឡើងដូចជា អំពើឆក់ប្លន់ ពេស្យាចារ និងការរស់នៅដោយគ្មានជាសុខភាព ខ្វះអនាម័យ និងបរិស្ថានកង្វក់ជាដើម។

### ១.៤.២.៣. ការអប់រំនៅទាប

នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសតតិយលោកភាគច្រើនអត្រាអនក្ខរជនមានចំនួនច្រើន ដែលជាពិសេសនៅតាមតំបន់ជនបទ ចំណែកឯនៅទីក្រុងវិញអត្រាអនក្ខរជនមានចំនួនតិចតួច នេះអាចបញ្ជាក់ថាវិស័យអប់រំនៅក្នុងប្រទេសមិនទាន់ជ្រួតជ្រាបបានគ្រប់ទីកន្លែងនៅឡើយ ដែលធ្វើឲ្យអ្នកមានជំនាញផ្នែកបច្ចេកវិទ្យានៅមានកម្រិតទាប ឬជួនកាលគ្មាន ជាលទ្ធផលធ្វើឲ្យមានការពិបាកក្នុងការអភិវឌ្ឍប្រទេស។

ប្រទេសកំពុងអភិវឌ្ឍមួយចំនួន នៅមិនទាន់មានលទ្ធភាពផ្តល់សេវាសាធារណៈដោយឥតគិតថ្លៃដល់កុមារដែលគ្រប់អាយុចូលរៀននៅឡើយទេ ហើយកុមារមួយចំនួនគ្មានពេលវេលាដើម្បីក្រេបជញ្ជក់ និងទទួលបាននូវចំណេះដឹងផ្សេងៗដោយសារតែគ្រួសារពួកគេគឺមានជីវភាពក្រលំបាកខ្លាំងពេក។

**១.៤.២.៤. បញ្ហានិគមូបនីយកម្ម/និគមភាព**

**១.៤.២.៤. បញ្ហានិកម្មភាព**

បញ្ហានេះកើតមានច្រើននៅបណ្តាប្រទេសកំពុងអភិវឌ្ឍ ភាគច្រើនប្រទេសទាំងនេះមនុស្សធ្វើចំណាក់ស្រុកដើម្បីរកការងារធ្វើនៅទីក្រុង ដែលធ្វើឲ្យទីក្រុងមានមនុស្សច្រើនកុះករ ការចំណាក់ស្រុកមកទីក្រុង គឺបណ្តាលមកពីនិកម្មភាពនៅទីក្រុងមានកម្រិតទាប និងនៅជនបទពុំសូវមានការងារធ្វើ។ ការអភិវឌ្ឍរវាងទីក្រុង និងជនបទគ្មានភាពស្មើគ្នា និងអន្តោប្រវេសន៍នៃជនបរទេសជាដើមដែលធ្វើឲ្យបញ្ហានិកម្មភាពកើតមានកាន់តែច្រើន។

ឧទាហរណ៍៖ នៅទីក្រុងភ្នំពេញសព្វថ្ងៃ មានប្រជាជនចំណាក់ស្រុកពីបណ្តាខេត្តក្រុងនៅទូទាំងប្រទេសយ៉ាងច្រើនមករស់នៅបណ្តោះអាសន្នដើម្បីរកការងារធ្វើ ដោយសារតែនៅតាមតំបន់ទីជនបទគ្មានដីធ្លីគ្រប់គ្រាន់សម្រាប់ធ្វើកសិកម្មផលដំណាំតម្លៃខ្ពស់។

ចំពោះដំណោះស្រាយបញ្ហាទាំងនេះគឺ រដ្ឋាភិបាលគួរតែធ្វើការអភិវឌ្ឍន៍ឲ្យមានសមភាពរវាងទីក្រុង និងជនបទដើម្បីជួយកាត់បន្ថយការចំណាក់ស្រុក។

**១.៤.២.៥. ការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិតទាប**

បច្ចេកវិទ្យាជាកត្តាក៏មួយដ៏សំខាន់ដែលអាចជួយជម្រុញដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេស ក៏ដូចជានៅទូទាំងសកលលោកផងដែរ។ បច្ចេកវិទ្យានាំមកនូវការចំណាយដើមទុនតិចតែទទួលបានផលច្រើន។ ប៉ុន្តែពេលខ្លះប្រទេសមួយដែលកំពុងអភិវឌ្ឍផ្នែកបច្ចេកវិទ្យានេះ ហើយវានាំមកនូវផលវិបាកជាច្រើនដែលមានដូចជា មិនអាចវាយលុកទៅទីផ្សារក្រៅប្រទេស ( ដោយសារតែផលិតផលទាំងនោះមានគុណភាពទាប ការចំណាយលើដំណើរការផលិតខ្ពស់)។ ទាំងនេះក៏ដោយសារតែការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិតទាប។

**១.៤.២.៦. កត្តានយោបាយ**

កត្តាស្ថេរភាពនយោបាយ ជាទំនុកចិត្តដ៏សំខាន់ និងខ្លាំងក្លាបំផុតដែលជួយជម្រុញឲ្យមាននូវកំណើនវិនិយោគក្នុងប្រទេស និងជាកត្តាចាំបាច់បំផុតដែលមនុស្សជាតិលើលោកត្រូវការដែលមិនអាចខ្វះបាន។ នៅពេលដែលប្រទេសមួយមានស្ថេរភាពនយោបាយនោះ ធ្វើឲ្យកើតមានវិបត្តិ

យ៉ាងច្រើនក្នុងសង្គម មានដូចជា អំពើហឹង្សា ការព្រាត់ប្រាស់គ្រួសារ អយុត្តិធម៌ក្នុងសង្គម និងការបាត់បង់សីលធម៌ក្នុងសង្គមជាដើម។ [15]

## ១.៥. យុទ្ធសាស្ត្រអភិវឌ្ឍរបស់រាជរដ្ឋាភិបាល

ស្របជាមួយគ្នានេះដែរចំពោះយុទ្ធសាស្ត្រនៃការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៣ នៃរដ្ឋសភា និយាយអំពីយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលកម្ពុជាដែលបានលើឡើងថា៖

បណ្តាញគមនាគមន៍មានតួនាទីជាសសៃឈាមសំរាប់តភ្ជាប់ច្រកល្ហក នៃព្រះរាជាណាចក្រកម្ពុជាឲ្យក្លាយទៅជាសរីរាង្គកាយសេដ្ឋកិច្ចមួយ ដែលធានាបាននូវសមាហរណកម្មផ្ទៃក្នុងខ្លួនឯងផង និងសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាជារូបវន្តទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោកផង។ លើសពីនេះទៀត សំរាប់ស្ថានភាពសេដ្ឋកិច្ចកម្ពុជាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅមានតួនាទីដ៏សំខាន់ជា " ក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ច" និងជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតមួយសំរាប់កាត់បន្ថយភាពក្រីក្រ និងទុក្ខលំបាកវេទនារបស់ប្រជាជន។ នៅលើមូលដ្ឋាននៃទស្សនៈវិជ្ជានេះរាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាពខ្ពស់ទៅលើការស្តារ និងកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនគ្រប់រូបភាព រួមមានថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងអាកាសយានដ្ឋានដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេស ទាំងទីក្រុង ទីប្រជុំជន និងតំបន់ជនបទឆ្ងាយដាច់ស្រយាលមានស្ថេរភាព មានសុវត្ថិភាព មានប្រសិទ្ធភាពសេដ្ឋកិច្ច និងមានតម្លៃទាបក្នុងទិសដៅសម្រួលដល់ការធ្វើពាណិជ្ជកម្ម ជម្រុញវិស័យទេសចរណ៍ ការអភិវឌ្ឍជនបទ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់ និងក្នុងសកលលោក ពិសេសគឺបម្រើដល់កិច្ចការពារជាតិថែមទៀត។ ក្នុងនេះអាទិភាពខ្ពស់ នឹងត្រូវបានផ្តោតទៅលើការបន្តកសាងផ្លូវជនបទជាមួយ នឹងការពង្រឹងវិធានការថែទាំផ្លូវថ្នល់ ដើម្បីរក្សាស្ថេរភាពនៃការដឹកជញ្ជូននិងការធ្វើដំណើរ។

រាជរដ្ឋាភិបាល នឹងខិតខំពុះពារបន្តកិច្ចការស្តារ និងអភិវឌ្ឍបណ្តាញផ្លូវដែក និងជម្រុញការប្រើប្រាស់ផ្លូវដែកសម្រាប់ដឹកជញ្ជូនធុនធ្ងន់។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងផងដែរទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ដូចជា គមនាគមន៍ដឹកជញ្ជូនគ្រប់រូបភាព រួមមានថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រ និងផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ។

[15] និស្សិត ហាម ខេមរិន្ទ, របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា, ប្រធានបទ៖ ការអភិវឌ្ឍន៍ផ្លូវលំជនបទ(សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១០) ទំព័រទី៧

វិស័យអាកាសចរណ៍ស៊ីវិល នឹងត្រូវបានលើកកម្ពស់ថែមទៀតក្នុងទិសដៅធានាឲ្យសេវាអាកាចរណ៍ស៊ីវិល អាចចូលរួមយ៉ាងសកម្មក្នុងការលើកស្ទួយកំណើនសេដ្ឋកិច្ចជាតិ ជាពិសេសគឺវិស័យទេសចរណ៍ជាតិ។[16]

## ១.៦. មូលដ្ឋានគ្រឹះនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ

ហេដ្ឋារចនាសម្ព័ន្ធ គឺជាសេវាសាធារណៈដ៏ធំមួយដែលរួមមាន ផ្លូវ ស្ពាន លូ សាលារៀន មន្ទីរពេទ្យ ប្រព័ន្ធទឹក អគ្គិសនី ផ្សារ...។ល។ នៅក្នុងលក្ខខណ្ឌដើម្បីបង្កើតនូវសេវាទាំងនោះគឺ ត្រូវការនូវថវិការបស់រាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនទៀតដែលមានគោលបំណងក្នុងការសាងសង់ និងស្តារនូវហេដ្ឋារចនាស័ម្ពន្ធនៅតំបន់ដាច់ស្រយាល។

ហេដ្ឋារចនាសម្ព័ន្ធ គឺប្រៀបដូចសសៃឈាមដ៏សំខាន់មួយ និងជាច្រកទ្វាររបស់ប្រជាកសិករសម្រាប់បើកអោយមានទំនាក់ទំនងផ្នែកសេដ្ឋកិច្ច និងវិស័យផ្សេងៗទៀត មិនត្រឹមតែប៉ុណ្ណោះវាថែមទាំងនិងអាចជួយដល់ការទាក់ទាញនូវប្រយោជន៍ច្រើន ដល់តំបន់គោលដៅនោះផងដែរ។

ហេដ្ឋារចនាសម្ព័ន្ធបានផ្តល់សារៈសំខាន់ណាស់ចំពោះសហាគមន៍ ពីព្រោះប្រជារាស្ត្រក្នុងសហាគមន៍ត្រូវការធ្វើដំណើរ អប់រំ សុខភាព ទឹកស្អាត និងការប្រកបអាជីវកម្ម ដើម្បីសម្រួលដល់ជីវភាព និងផលប្រយោជន៍ផ្ទាល់របស់សហាគមន៍ទាំងមូល។ មិនតែប៉ុណ្ណោះហេដ្ឋារចនាសម្ព័ន្ធក៏ផ្តល់សេវាទំនាក់ទំនងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ទីផ្សារ និងសេវាកម្មផ្សេងៗទៀត ដើម្បីអភិវឌ្ឍន៍សហាគមន៍អោយរីកចំម្រើនឿនលឿន។ កាលណាសហាគមន៍យើងមានការរីកចម្រើន ហើយយើងទាំងអស់គ្នាដែលរស់នៅក្នុងសហាគមន៍ ក៏មានជីវភាពសុខស្រួលដែរ។ ម្យ៉ាងវិញទៀតហេដ្ឋារចនាសម្ព័ន្ធក៏ជាបញ្ហាមួយឈានមុខក្នុងការកាត់បន្ថយភាពក្រីក្រ និងជួយក្នុងការអភិវឌ្ឍន៍ប្រទេសជាតិដែលរាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់។

ការរីកចម្រើនវិស័យសេដ្ឋកិច្ចជនបទ ទាមទារនូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធជនបទឲ្យបានល្អជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋមានទំនាក់ទំនងសហាគមន៍នៅតាមស្រុកស្រែចំការ។ ការកសាងផ្លូវពីទីប្រជុំជន គឺបញ្ហាសំខាន់ណាស់ក្នុងការអភិវឌ្ឍជនបទ ព្រោះផ្លូវប្រៀបដូចជា សសៃឈាមនៅក្នុងខ្លួនមនុស្សយើង ផ្លូវល្អធ្វើឲ្យមានចរាចរទៅមកបានលឿនចំណាយ

[16] ទីស្តីការគណៈរដ្ឋមន្ត្រី, យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា ចតុកោណទី២.ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, មុំទី១. ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍, ឆ្នាំ ២០០៩, ទំព័រទី ៣៦

ចរិការតិច ការដឹកជញ្ជូនផលិតផលកសិកម្មបានដល់ទីផ្សារ អាចមានទំនាក់ទំនងឆាប់រហ័ស និងជួយសម្រួលដល់សេវាសង្គមនានា សំដៅដល់ការលើកកម្ពស់ប្រជាជន ក្នុងការរកចំណូល និងលើកកម្ពស់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជនក្រីក្រនៅជនបទ។ ការអភិវឌ្ឍសហគមន៍ និងកំណែទម្រង់សេវាសាធារណៈនៅជនបទបានល្អ នោះនិងធ្វើឲ្យមានការទាក់ទាញវិនិយោគទុនក្នុងស្រុកនឹងក្រៅស្រុក ជម្រុញវិស័យទេសចរណ៍ទៅរមណីយដ្ឋាន ឬប្រាសាទបុរាណ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និងក្នុងពិភពលោក ជាពិសេសគឺធ្វើឲ្យកំណើនសេដ្ឋកិច្ច ដែលជាទិសដៅយ៉ាងសំខាន់ក្នុងការអភិវឌ្ឍជនបទ។

យោងតាមបទពិសោធន៍នៃការសិក្សាផ្លូវលំរបស់បណ្តាប្រទេសអភិវឌ្ឍមួយចំនួន នៅក្នុងទ្វីបអាស៊ី អាហ្វ្រិក និងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនលើពិភពលោក និងឆ្លងកាត់តាមការ ធ្វើសហប្រតិបត្តិការជួសជុល និងថែទាំផ្លូវលំរបស់អង្គការនានាមួយចំនួនកំពុងអភិវឌ្ឍសព្វថ្ងៃ ជាពិសេសអង្គការពលកម្មអន្តរជាតិ (I L O) ដែលមានសកម្មភាពមមារញឹកនិងបទពិសោធន៍ខ្ពស់ បានបង្ហាញឲ្យឃើញបាននូវគោលការណ៍ជាយុទ្ធសាស្ត្រ សម្រាប់ធ្វើប្រតិបត្តិការជួសជុល និងថែទាំឲ្យមានប្រសិទ្ធភាពដែលផ្តោតសំខាន់កត្តាថែទាំ។

### ១.៦.១. សាលារៀន

សាលារៀន គឺជាថ្នាក់បណ្តុះបណ្តាលនូវធនធានមនុស្សដោយផ្តល់នូវចំណេះដឹងផ្សេងៗ លុបបំបាត់នូវអនក្ខរកម្មតាមរយៈការអប់រំទូន្មាន និងការបណ្តុះបណ្តាលនូវមនសិការជាតិមាតុភូមិដល់ពួកគេ ព្រោះពួកគេនឹងក្លាយទៅជាសសរទ្រុងសម្រាប់ប្រទេសជាតិទៅថ្ងៃក្រោយ។ ការបណ្តុះបណ្តាលធនធានមនុស្សតាំងពីវ័យកុមារត្រូវឲ្យមានប្រសិទ្ធភាពខ្ពស់ ព្រោះបច្ចុប្បន្នរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើកុមារដែលជាទំពាំងស្នងឬស្សី។

### ១.៦.២.វិស័យសុខាភិបាល

ដោយសារតែការខ្វះខាតនូវមជ្ឈមណ្ឌលសុខភាពនៅជនបទ និង ខ្វះខាតនូវការអប់រំអំពីសុខភាព និង អនាម័យបានធ្វើឲ្យប្រជាពលរដ្ឋទាំងនោះបានឆ្លងនូវជម្ងឺផ្សេងៗយ៉ាងងាយ និងជាហេតុធ្វើអោយកម្រិតជីវភាពរបស់ពួកគេបានធ្លាក់ចុះផងដែរ។ ការដោះស្រាយនូវបញ្ហាសុខាភិបាល គឺជាការកែលម្អផ្នែកហេដ្ឋារចនាសម្ព័ន្ធមួយដែល ព្រោះបញ្ហានេះអាចចូលរួមចំណែកផ្តល់នូវសេវាកម្មសុខភាព និងជាអ្នកចូលរួមលើកស្ទួយជីវភាព និងជួយឲ្យមានកំណើនសេដ្ឋកិច្ច។

### ១.៦.៣.ការពង្រីកធារាសាស្ត្រខ្នាតតូច

ប្រព័ន្ធធារាសាស្ត្រចែកចេញជាបី គឺប្រព័ន្ធធារាសាស្ត្រខ្នាតធំ ប្រព័ន្ធធារាសាស្ត្រខ្នាតមធ្យម និងប្រព័ន្ធធារាសាស្ត្រខ្នាតតូច។ ការស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ដែលជាផ្នែកមួយនៃការអភិវឌ្ឍជនបទចម្រុះមួយនៃការទទួលខុសត្រូវរបស់ក្រសួងអភិវឌ្ឍជនបទដែរ។ ដើម្បីធ្វើការអនុវត្តន៍គម្រោងទាំងនេះសមាគមជនបទចាំបាច់ត្រូវចូលរួមចំណែកក្នុងការចំណាយខ្លះៗ។ កិច្ចដំណើរការនេះ និងថែទាំដោយសហគមន៍ មូលដ្ឋានត្រូវបានលើកទឹកចិត្ត និងបានជម្រុញយ៉ាងខ្លាំងដោយក្រសួងអភិវឌ្ឍជនបទ។ ដើម្បីឲ្យមានប្រសិទ្ធភាពក្នុងការបែងចែក និងប្រើប្រាស់ទឹកស្រោចស្រព កិច្ចដំណើរការនិងថែទាំត្រូវបានបែងចែកដោយអ្នកភូមិតាមរយៈការចូលរួមក្នុងក្រុម និងសហគមន៍អ្នកប្រើប្រាស់។ ក្រសួងអភិវឌ្ឍន៍ជនបទ បានធ្វើការលើកឡើងនូវផែនការអភិវឌ្ឍន៍ ដើម្បីស្តារនិងសាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ដោយធ្វើទំនាក់ទំនងជាមួយភ្នាក់ងារអន្តរជាតិ និងស្ថាប័នមានសមត្ថកិច្ចផ្សេងៗ ក្នុងគោលបំណងបង្កើតនិងកែលម្អ ផលិតកម្មស្បៀងជាលក្ខណៈគ្រួសាររបស់ប្រជាពលរដ្ឋនៅជនបទ។

បច្ចុប្បន្ននេះ ធារាសាស្ត្រខ្នាតតូចត្រូវទទួលរងនូវការជួសជុល និងស្តារឡើងវិញដើម្បីបំពេញតម្រូវការរបស់ប្រជាជន។ ការស្តារ និងជួសជុលនេះត្រូវធ្វើឡើងដោយមានការផ្តល់ថវិកាពីរដ្ឋាភិបាល និងអង្គការផ្សេងៗ ទៀតដែលពាក់ព័ន្ធ និងការចូលរួមនូវទុនបដិភាគរបស់ប្រជាជនផងដែរ ហើយព្រមទាំងកម្លាំងពលកម្មពីប្រជាពលរដ្ឋ។ ហើយការអភិវឌ្ឍធារាសាស្ត្រខ្នាតតូចគឺបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដូចជា ផ្តល់ទឹកដើម្បីបង្កបង្កើនផលដំណាំផ្សេងៗ ជាពិសេសដំណាំស្រូវ, ធ្វើឲ្យកសិករទទួលបាននូវទិន្នផលខ្ពស់, ធានាបាននូវសុវត្ថិភាពស្បៀងសម្រាប់កសិករ, កសិករមានជីវភាពប្រសើរជាងមុន, អន្តរាគមន៍ក្នុងពេលមានគ្រោះរាំងស្ងួត និងរំដោះទឹកចេញពេលមានគ្រោះទឹកជំនន់។

### ១.៦.៤. ការសាងសង់ស្ពាន

ស្ពានជាផ្នែកមួយនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានសារៈសំខាន់ក្នុងការធ្វើដំណើរឆ្លងកាត់ ទន្លេ ព្រែក ស្ទឹង និងអូរ។ ស្ពានធ្វើអោយមានភាពងាយស្រួល ក្នុងការដឹកផលិតផលកសិកម្មរបស់ប្រជាពលរដ្ឋ ដោយមានចាំបាច់ប្រើប្រាស់ទូក ហើយការប្រើប្រាស់ទូកអាចឲ្យទំនិញមានការខូចខាតច្រើន ព្រោះការដឹកជញ្ជូនមានការលំបាកទាំងការលើកទុកលើកដាក់។

ជាការពិតណាស់ ការធ្វើផ្លូវត្រូវតែធ្វើយ៉ាងណាឲ្យខ្ពស់ជាងដីស្រែ ដើម្បីធានាសុវត្ថិភាពរបស់ផ្លូវ ហើយដើម្បីតភ្ជាប់ពីផ្លូវមួយទៅផ្លូវមួយទៀត ដោយឆ្លងកាត់ស្ទឹង ឬព្រែក ចាំបាច់ត្រូវតែ

សាងសង់ស្ពាន ព្រោះស្ពាន និងផ្លូវនេះត្រូវដើរទទឹមគ្នាជានិច្ច។ ម្យ៉ាងទៀត ស្ពានដែលមានស្រាប់តាំងពីយូរយាណាស់មកហើយនោះ ក៏ទទួលនូវការជួសជុល សាងសង់ជាថ្មី ដើម្បីងាយស្រួលក្នុងការធ្វើដំណើរ និងការដឹកជញ្ជូនទំនិញរបស់ប្រជាពលរដ្ឋ។

**១.៦.៥. ការសាងសង់លូ**

ការសាងសង់លូនៅតាមផ្លូវ គឺដើម្បីចៀសវាងនូវការលិចទឹក ជាពិសេសនៅតំបន់វាលស្រែ។ ដោយសារកត្តាទាំងនេះហើយ ដែលជម្រុញឲ្យមានការកសាងផ្លូវត្រូវបំពាក់ប្រព័ន្ធលូ ទើបបង្កលក្ខណៈងាយស្រួល និងចលនាទឹកកុំឲ្យលិចលង់ដំណាំស្រូវ និងដំណាំផ្សេងៗទៀតនៅរដូវវស្សាជាដើម។

**១.៦.៦. ការជីកប្រឡាយ**

ដោយសារតែប្រជាជនភាគច្រើនជាកសិករ ប្រកបរបរកសិកម្មនិងធ្វើស្រែចម្ការ ដូចនេះទឹកមានសារៈសំខាន់ណាស់សម្រាប់ពួកគេកក្នុងការស្រោចស្រពនៅដំណាំរបស់ពួកគេ។ ដែលដំណាំទាំងនោះត្រូវការចាំបាច់នូវការជីកប្រឡាយ ធ្វើជាអាងស្តុបទឹកទុកបញ្ចូលទៅក្នុងស្រែរបស់ពួកគេនៅពេលដែលមានការខ្វះខាត។

ប្រឡាយជាភ្នាក់ងារមួយក្នុងការផ្គត់ផ្គង់ទឹកមួយដ៏សំខាន់បំផុត។ ដូចនេះហើយយើងត្រូវការប្រឡាយ នាំទឹកមកកាន់លូដើម្បីបង្ហូរចូលក្នុងស្រែចំការរបស់ប្រជាពលរដ្ឋ។ ប្រឡាយមេត្រូវបានជីកបន្តពីប្រភពទឹកនានាដូចជា ស្ទឹង ព្រែក ឬទ្វារទឹក ដើម្បីងាយស្រួលបញ្ចូលទឹកក្នុងប្រឡាយរងជាច្រើនទៀត។ នៅករដូវប្រាំងក៏ដូចជារដូវវស្សាដែល គឺប្រឡាយមានតួនាទីសំរាប់ការផ្តល់ទឹកដើម្បីស្រោចស្រព ដីស្រែចំការ និងជួយឲ្យប្រជាពលរដ្ឋអាចធ្វើប្រពលវប្បកម្មដំណាំស្រូវ និងដំណាំផ្សេងៗជាច្រើនទៀត។

**១.៦.៧. ការសាងសង់ផ្សារនៅជនបទ**

ផ្សារនៅជនបទជាកន្លែងប្រកបមុខរបរ លក់ដូរផលិតផលកសិកម្ម និងផលិតផលផ្សេងៗទៀត។ ទីផ្សារជាហេដ្ឋារចនាសម្ព័ន្ធមួយដែលជួយសម្រួលជីវភាពប្រចាំថ្ងៃ និងទំនាក់ទំនងរវាងអ្នកលក់និងអ្នកទិញ។ ក្រសួងអភិវឌ្ឍន៍ជនបទបានខិតខំរកវិធានការដើម្បីសាងសង់ផ្សារនៅទីជនបទដើម្បីឲ្យមានការជៀសវាងការធ្វើដំណើរឆ្ងាយរបស់ប្រជាពលរដ្ឋទៅតាមតំបន់ដាច់ស្រយាលមកទីប្រជុំជន។

ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជនបទ ដើម្បីធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសេវាកម្មរបស់ប្រជាជននៅជនបទ និងធ្វើឲ្យមានភាពងាយស្រួលដល់ការដឹកជញ្ជូនផលិត

ផលនៅជនបទ ទៅកាន់ទីផ្សារ ជាពិសេសការសាងសង់ជាជំហានៗ នូវផ្លូវមានគុណភាពខ្ពស់ ដែលធានាដល់ការប្រើប្រាស់បានរយៈពេលវែង។[17]

## ១.៧. ការស្ថាបនាផ្លូវ

### ១.៧.១. ការអភិវឌ្ឍផ្លូវលំ

ផ្លូវលំ ត្រូវបានគេចាត់ទុកជាធាតុមួយដ៏សំខាន់ដែលបម្រើដល់តម្រូវការរបស់ប្រជាពលរដ្ឋតំបន់ជនបទសម្រាប់ធ្វើដំណើរ និងដូចជាធ្វើទំនាក់ទំនងរាល់សកម្មភាពសេដ្ឋកិច្ចប្រចាំថ្ងៃ។ ក្រៅពីបម្រើដល់សេចក្តីត្រូវការចាំបាច់ផ្សេងៗ ពួកគេអាចដំណើរទៅកាន់បរិក្ខារសេដ្ឋកិច្ច សង្គម សេវាកម្ម និងកាលានុវត្តន៍ភាពផ្សេងៗ។

ហេតុអ្វីបានជារាជរដ្ឋាភិបាលយកការអភិវឌ្ឍផ្លូវលំជនបទ ជាវិស័យអាទិភាព?

បើក្រឡេកមើលការអភិវឌ្ឍនៅទីជនបទវិញ គឺគេត្រូវការនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសផ្លូវលំជនបទ ដែលជាអ្នកភ្ជាប់តំបន់ជនបទឲ្យខិតមកជិតទីប្រជុំជនដើម្បីប្រជាពលរដ្ឋមានសកម្មភាពសេដ្ឋកិច្ចរបស់ពួកគាត់ដូចជា ដឹករាល់ភោគផលដែលពួកគាត់ផលិតបានមកកាន់ទីផ្សារ និងផ្គត់ផ្គង់សេវាកម្មផ្សេងៗប្រកបដោយប្រសិទ្ធភាព និងចីរភាព។ ក្រៅពីនេះផ្លូវលំបានផ្តល់នូវកម្រិតចំណេញអតិបរមាសេដ្ឋកិច្ចលើការវិនិយោគ និងកាត់បន្ថយភាពក្រីក្រក្នុងតំបន់ជនបទ។ ដោយសារតែឃើញ ពីអត្ថប្រយោជន៍ច្រើនយ៉ាងរបស់ផ្លូវលំធ្វើឲ្យរដ្ឋាភិបាលជម្រុញដល់ក្រសួងអភិវឌ្ឍន៍ជនបទ កម្មវិធីសីលាក៏ដូចជាដៃគូអភិវឌ្ឍន៍នានាធ្វើការសាងសង់ ជួសជុលកែលម្អឡើងវិញ ដើម្បីជម្រុញការរីកចម្រើនតំបន់ជនបទជាបន្តទៅទៀត។ ក្រៅពីនេះមានគោលនយោបាយវិមជ្ឈការដោយឃុំជាអ្នករៀបចំនូវគោលនយោបាយ ដើម្បីទាក់ទាញនូវវិនិយោគក្នុងតំបន់ឲ្យបានកាន់តែខ្លាំងថែមទៀត។

ការរីកចម្រើននៃវិស័យសេដ្ឋកិច្ចជនបទនេះ ទាមទារឲ្យមានការរៀបចំហេដ្ឋារចនាសម្ព័ន្ធជនបទឲ្យបានល្អ ជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ ដែលមានទំនាក់ទំនងជាមួយសហគមន៍នៅតាមស្រុកស្រែចំការ។ ហើយការសាងសង់ផ្លូវពីទីប្រជុំជនទៅជនបទ គឺជាបញ្ហាដ៏សំខាន់ក្នុងការអភិវឌ្ឍជនបទ ព្រោះផ្លូវប្រៀបដូចជាសសៃឈាមនៅក្នុងខ្លួនមនុស្សយើង។ ផ្លូវល្អអាចសម្រួលដល់ការធ្វើចរាចរបានលឿន ចំណាយថវិកាតិច ការដឹកជញ្ជូនបានឆាប់រហ័ស លក្ខណៈទាំងនេះបានបង្កឲ្យប្រជាជន មានលទ្ធភាពអាចរកប្រាក់ចំណូលបានល្អប្រសើរជាងមុខ អាច

[17] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា គំរោងកែលំអហេដ្ឋារចនាសម្ព័ន្ធជនបទ របស់និស្សិត នួន ឡាដា ឆ្នាំ ២០០៥ ទំព័រទី៤៧

មានទំនាក់ទំនងឆាប់រហ័សជាមួយទីផ្សារ និងជួយសម្រួលដល់សេវាសង្គមនានាសំដៅលើកកម្ពស់ជីវភាពប្រជាជនក្រីក្រនៅតំបន់ជនបទ ។ ការរំពឹងទុករបស់គម្រោងស្ថិតក្នុងការវាស់វែងមានកម្រិតពេលគឺមានប្រជាពលរដ្ឋកម្ពុជា នៅជនបទដែលមានជីវភាពមធ្យមត្រូវចំណាយពេលប្រហែលពី៦ម៉ោង ទៅ៧ម៉ោងក្នុងមួយថ្ងៃ សម្រាប់ការបំពេញបំណងការធ្វើដំណើរ និងដឹកជញ្ជូនផ្សេងៗរបស់ពួកគាត់។ [18]

### ១.៧.២. ការថែទាំផ្លូវ

#### ១.៧.២.១. ថែទាំខួប

ការថែទាំខួប គឺជាការលើកគុណភាពផ្លូវថ្នល់ឲ្យបានស្មើនិងស្ថានភាពដូចដើម ឲ្យមានរាងដើមឡើងវិញ ក្រោយពេលបានប្រើប្រាស់វាអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ការថែទាំនេះនិងត្រូវកំណត់ថា តើត្រូវធ្វើឡើងនូវពេលណាតាមរបៀបណាដោយទីបញ្ជាការដ្ឋានពីព្រោះការងារនេះវាពាក់ព័ន្ធដល់ការប្រតិបត្តិធំ។ ការថែទាំជារយៈៗនេះធ្វើឡើងកែលម្អផ្លូវថ្នល់ឲ្យមានសកម្មភាពដូចដើម និងត្រូវកៀរឡើងវិញ ហើយប្រសិនបើចាំបាច់លើកកម្ពស់តួថ្នល់ឲ្យបានខ្ពស់ជាងសភាពដីនៅជុំវិញ។ ការថែទាំនេះរួមបញ្ចូលផងដែរនូវការប្តូរស្រទាប់ដីគ្រួសលើផ្លូវថ្នល់ ហើយយើងត្រូវពិនិត្យមើលនូវសំណឹកនិងការរលាត់ដាច់នៃផ្លូវថ្នល់ឲ្យបានល្អិតល្អន់ ដើម្បីកំណត់ឲ្យបាននូវបុព្វហេតុដែលបណ្តាលឲ្យមានការខូចខាតរបស់ផ្លូវថ្នល់។ ចំពោះលូវិញមានការពិបាកជាងស្ពានបន្តិចព្រោះត្រូវការសម្អាតជាប្រចាំដូចជា កំទេចកំទីដីកំណាក ឬវត្ថុដែលនាំឲ្យស្ទះលូ ចាំបាច់ត្រូវសម្អាតយកចេញក្នុងការថែទាំជាប្រចាំ រាល់ពេលអនាគតត្រូវសម្អាតក្បាលនិងកន្ទុយលូផង។ ជញ្ជាំងទប់ក្បាលលូនិងទីមុខក្បាលលូ និងកន្ទុយលូត្រូវជួសជុលឲ្យបានល្អក្នុងកំឡុងពេលថែទាំតាមរបៀបនេះម្តងៗ។ ការងារថែទាំតាមរយៈកាល (ខួប) ត្រូវបានអនុវត្តម្តងម្កាលលើផ្លូវដែលបានខូចខាតជាទ្រង់ទ្រាយធំតាមលក្ខណៈបច្ចេកទេស។

#### ១.៧.២.២. ការងារសម្អាត

- ការឈូសឆាយ (យកដីដែលអន់គុណភាព និងមិនមែនជាតម្រូវការចេញ) លើផ្ទៃផ្លូវចាស់ដើម្បីបង្កើតជាស្រទាប់
- ពិនិត្យជាដំបូងចំណុចដែលស្រុត-ផុង-រិចរិល-គ្រលុកតូច ធំ ដោយគូសឬបាញ់ថ្នាំចំណាំ

[18] និស្សិត ផល វិទូ, របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា, ប្រធានបទ៖ ការកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍផ្លូវលំ(សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១១) ទំព័រទី៥០

- ដោយប្រើពលករមួយចំនួន ឬគ្រឿងយន្ត ជីកកកាយដីខូចគុណភាព យកចេញអោយឆ្ងាយពីតួផ្លូវ
- ការជីកកាយត្រូវពង្រីកផ្ទៃរណ្ដៅអោយធំៗជាងរណ្ដៅដើម ដើម្បីបង្កភាពងាយស្រួលអោយរ៉ូឡូងាយចូលបង្ហាប់បានល្អ។

**១.៧.២.៣. ការងារបំពេញដី រៀបចំតួផ្លូវ**

**ការបំពេញដី គ្រលុករណ្ដៅធំៗ**

- បំពេញដីអោយមានគុណភាពខ្ពស់ទៅក្នុងរណ្ដៅ កន្លែងស្រុត ឬសំបុកមាន់ដោយឲ្យនីវ៉ូបំពេញថ្មី ស្មើនិងនីវ៉ូផ្លូវចាស់។
- កិនបង្ហាប់ដីបំពេញ តាមស្រទាប់នីមួយៗ (កម្រិតត្រឹម២០ស.ម សម្រាប់១ស្រទាប់) ដោយស្រោចទឹក ពេលបង្ហាប់នោះក្នុងកម្រិតសំណើមល្អបំផុត។

**ការបន្ថែមដីស និងភ្ជួរ ឈូស ផ្ដុំតួផ្លូវ**

- ភ្ជួរ ឬជ្រួយ គ្រលប់ដីក្រាសតួផ្លូវចាស់អោយបានសព្វល្អ។
- ផ្សើមទឹកក្នុងកម្រិតសមស្របមួយ ដែលផ្ដល់ដោយរថយន្តស្រោចទឹកមួយចំនួន (ជៀសវាងការប្រើទុយយោបាញ់)។
- ការកៀរភ្ជួរជ្រួយត្រូវអនុវត្តពាក់កណ្ដាលទ្រូងផ្លូវម្ដង និងដើម្បីទុកឲ្យការធ្វើចរាចរ និងដឹកជញ្ជូនរបស់ប្រជាពលរដ្ឋបានស្រួល។
- ឈូសពង្រាបកៀរផ្ដុំជាលក្ខណៈប្រអប់ផ្លូវ ឲ្យមានជម្រាលខ្នងអណ្ដើក។
- បំពេញបន្ថែមដីសត្រង់ផ្នែកដែលពិនិត្យឃើញថា មានភាពទាបជាងទឹក អតិបរមានៅរដូវវស្សា (ពិនិត្យ តាមប្លង់) ឬ ស្រុតខ្លាំងខុសពីនីវ៉ូ ផ្លូវចាស់។
- ពង្រាយដីសនិងកៀរពង្រាបអោយផ្ទៃដីផ្លូវ មានភាពស្មើល្អដោយជ្រួយច្របល់ជាមួយដីចាស់រួចស្រោចទឹកកិនបង្ហាប់។
- ឈូសពង្រាបកៀរផ្ដុំជាលក្ខណៈប្រអប់ផ្លូវម្ដងទៀត ឲ្យមានជម្រាលខ្នងអណ្ដើក ៥% ទៅ៧% ក្រោយ ពេលបង្ហាប់រួចដើម្បីងាយស្រួលរំដោះទឹកហូរលើខ្នងផ្លូវបានស្រួលល្អ។

**១.៧.២.៤. ការងារក្រាលក្រួសក្រហម**

- ក្រាលក្រួសក្រហមត្រូវបានត្រួតពិនិត្យអំពីគុណភាព។
- ក្រាលក្រួសក្រហមត្រូវតាមកម្រាស់កំណត់ក្នុងបទដ្ឋានគម្រោង។

- ការស្រោចទឹកផ្សើមក្រួសក្រហម ពេលបង្ហាប់ក្នុងកម្រិតសំណើមល្អបំផុត ការងារត្រូវអនុវត្តតាមការណែនាំរបស់រដ្ឋមន្ត្រីប្រចាំការដ្ឋាន។
- គុណភាពនៃការបង្ហាប់ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស។

**១.៧.២.៥. ការកៀរពង្រាប និងតម្រឹមចិញ្ចើមផ្លូវ**

- គឺត្រូវតែបំពេញល្បាយគ្រួសក្រហម ត្រូវបន្ថែមត្រង់ផ្នែកណាមួយដែលពិនិត្យឃើញថាមានភាពផតនៅឡើយ។
- ឈូសចិតតម្រឹមចិញ្ចើមផ្លូវ ឲ្យរត់ត្រង់បន្ទាត់។

**១.៧.២.៦. ការការពារការហូរច្រោះ**

- ដាំស្មៅ តាមជើងទេរចំណោតរបស់ផ្លូវ។
- ដាំកូនឈើ អមសងខាងផ្លូវ ( មិនត្រូវដាំលើជើងទេរផ្លូវទេ)។
- ការស្រោចទឹក ថែទាំជាប្រចាំ។

**១.៧.២.៧. ការងារសំណង់សិល្បការ**

**ការងារសាងសង់លូ**

- រៀបចំការងារសុវត្ថិភាព ( ផ្លូវវាង របងការពារ ផ្លាកសញ្ញា)។
- កំណត់ទីតាំងសំណង់ ដើម្បីជីករណ្តៅគ្រឹះ អោយជ្រៅជាងជម្រៅប្រឡាយ ឬអូរ។
- សម្អាតរណ្តៅគ្រឹះ និងបង្ហាប់បាតរណ្តៅអោយបានស្មើ។
- តម្រៀបថ្ម ( ៤x៦ ) ក្រមាស់ ៣០ស.ម រួចដាក់ខ្សាច់គ្រើមកៀរអោយស្មើនិងក្បាលថ្ម (៤x៦) បង្ហាប់ឲ្យបានល្អ។
- ចាក់បាយអរស្ងួត ស្រោចទឹក និងបុកបង្ហាប់។
- ចាក់បេតុងដែកកម្រាល់ ១០ស.ម សម្រាប់កម្រាលលូ ( លាយតាមបទដ្ឋានបច្ចេកទេ) សម្រាប់ការងារចាក់បេតុងដែក កម្រាលមុខ ក្រោយ ស្លាបសងខាង។
- រៀបចំចងដែក (កំណត់តាមប្លង់បច្ចេកទេស) និងតម្លើងក្តារពុម្ព (កម្រាស់ ៣០ស.ម)។
- ថ្ម ( ១x២) ត្រូវតែស្អាត និងខ្សាច់ប្រភេទគ្រើមគ្មានធូលី គ្មានល្បាយដីឥដ្ឋ ទឹកថ្លាល្អ (គ្មានជាតិកំបោរ អំបិល)។
- កម្រិតល្បាយ (១x២) ស្មើនឹង ០.៩ម៣ ស៊ីម៉ង់ត៍ ៤៣០គីឡូ ទឹក២០០លីត្រ ដែក៩០គីឡូ។
- ការងាររៀបចំដាក់លូ ត្រូវស្អាតមិនប៉ោងប្រេះ និងត្រូវដាក់ឲ្យត្រង់ល្អ មុខតំណត្រូវផ្សារអោយជិតល្អដោយបាយអរ។

**ការងារសម្អាត ស្ពាន សំណង់ដោះទឹកនានា**

អ្នកប្រចាំការដ្ឋាន ឬអ្នកម៉ៅការត្រូវអនុវត្តការងារនេះដូចខាងក្រោមៈ

- សម្អាតលូ ផ្នែកខាងមុខ ខាងក្រោយ កាយដីល្បាប់ភក់ចេញពីបាតលូ។
- បំពេញដី និងបង្ហាប់ឲ្យណែនជុំវិញសំណង់លូ បើមានការហូរច្រោះបាត់បង់ដី។
- ប្រឡាយត្រូវកាយប្រមូលសំរាមពីបាត-កាប់កូនរុក្ខជាតិតូចៗចេញពីតួប្រឡាយ ឬមាត់ប្រឡាយ
- ចំពោះក្បាលស្ពានច្រើនមានការស្រុតដី ត្រូវបំពេញដីអោយបានស្មើ នីវ៉ូកម្រាលស្ពាន។
- ការថែទាំស្ពានបេតុង និងស្ពានបេឡេត៍ ស្ពានដែកអ៊ី និងមានលម្អិតជាបន្ថែមទៀត។

**ការងារគ្រប់គ្រង និងថែទាំបន្ត**

ក្រោយពីបញ្ចប់សុពលភាព អាជ្ញាធរមូលដ្ឋានត្រូវរៀបចំៈ

- រៀបចំនូវយន្តការជាយុទ្ធសាស្ត្រ សម្រប់ការងារប្រតិបត្តិ និងថែទាំជាប្រចាំដោយធ្វើយ៉ាងណារក្សាឲ្យបាននូវនិរន្តភាពនៃការប្រើប្រាស់ផ្លូវ។
- បង្គោលសុវត្ថិភាព និងស្លាកសញ្ញាចរាចរគ្រប់ប្រភេទ។[19]

**១.៧.៣. អត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការស្ថាបនាផ្លូវលំជនបទ**

ហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្លូវលំនេះ មានតម្លៃខ្លាំងណាស់សម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ដែលវាបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនមានដូចខាងក្រោម:

- ការធ្វើសមាហរណកម្មរវាងទីរួមខេត្ត ទីរួមស្រុក និងភូមិឃុំ
- តភ្ជាប់ទំនាក់ទំនងពីតំបន់មួយទៅតំបន់មួយទៀត ដោយមានការកាត់បន្ថយពេលវេលាក្នុងការធ្វើដំណើរ ចំណេញថវិការ ហើយមានសុវត្ថិភាព
- ធ្វើឲ្យគម្លាតពីទីក្រុងខិតជិតទីជនបទ ដោយការធ្វើដំណើរបានលឿនឆាប់រហ័ស
- លើកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនរស់នៅតាមដងផ្លូវមានភាពប្រសើរឡើង
- ប្រជាជនបានយល់ដឹងអំពីសក្តានុពលភាព និងអត្ថប្រយោជន៍របស់ផ្លូវលំជនបទបានកាន់តែច្រើនជាងមុន
- ធ្វើឲ្យមានការផ្តល់សេវាកម្មគ្រប់ប្រភេទ ដែលចូលរួមបម្រើដល់ការអភិវឌ្ឍន៍

[19] បទដ្ឋានណែនាំសម្រាប់អនុវត្តន៍ការងារថែទាំតាមរយៈការ(ខួប), ក្រសួងអភិវឌ្ឍជនបទ, ឆ្នាំ២០១២ ទំព័រទី ៣

- ងាយស្រួលដឹកទំនិញ ឬផលិតផលដែលកសិករផលិតបានទៅកាន់ទីផ្សារមានភាពលឿន
- ចំណាយពេលវេលាតិចក្នុងការធ្វើដំណើរដោយសារផ្លូវល្អនៅគ្រប់ទីកន្លែង
- កាត់បន្ថយថ្លៃដឹកជញ្ជូននៃផលិតផលទៅកាន់ទីផ្សារ ព្រោះតម្លៃថោកជាងមុន
- ជួយទប់ស្កាត់នូវកំណើនប្រជាជនក្នុងទីក្រុង គឺដោយសារការហូរចូលនូវកម្លាំងពលកម្មពីទីជន បទដើម្បីស្វែងរកការងារធ្វើ មានការថយចុះ
- ជួយជម្រុញកំណើនសេដ្ឋកិច្ចនៅតាមជនបទឲ្យកាន់តែមានភាពប្រសើរឡើង ក៏ដូចជាសេដ្ឋកិច្ចជាតិផងដែរ
- ផ្តល់ឱកាសដល់អ្នកវិនិយោគទុន ក្នុងការបណ្តាក់ទុនវិនិយោគអភិវឌ្ឍន៍លើវិស័យកសិកម្ម កសិឧស្សាហាកម្ម និងវិស័យដទៃទៀតមានការកើនឡើង
- ផ្តល់ឱកាសដល់ស្ត្រីក្នុងការបង្កើតមុខរបររកប្រាក់ចំណូលបន្ថែម និងដើម្បីលើកកំពស់ជីវភាពបានថែមមួយកម្រិតទៀត
- លើកទឹកចិត្តដល់អង្គការអន្តរជាតិមានលទ្ធភាព បានមកដល់អ្នកដែលរស់នៅទីជនបទ
- កាត់បន្ថយការធ្វើចំណាក់ស្រុកទៅក្រៅប្រទេសដោយខុសច្បាប់ ដែលប្រឈមនឹងបញ្ហាគ្រោះថ្នាក់ផ្សេងៗ
- ធ្វើឲ្យសេដ្ឋកិច្ចនៅទីជនបទមានការរីកចម្រើនឡើងបន្ថែមមួយកម្រិតទៀត
- បង្កលក្ខណៈងាយស្រួលឲ្យប្រជាកសិករ ក៏ដូចជាប្រជាពលរដ្ឋមាកគំនិតច្នៃប្រឌិតក្នុងការផលិតនូវផលិតផលកសិកម្ម ឬសិប្បកម្មផ្សេងៗទៀត ដើម្បីដឹកជញ្ជូនទៅកាន់ទីផ្សារក្នុងការជួយឲ្យសេដ្ឋកិច្ចគ្រួសារកាន់តែមានភាពប្រសើរឡើង
- ជួយឲ្យប្រជាពលរដ្ឋមានការងារធ្វើ ស្របតាមទិសដៅភូមិមួយផលិតផលមួយ។[20]

## សន្និដ្ឋានជំពូក

យោងតាមការលើកឡើងនូវទ្រឹស្តីដែលមាន និយមន័យ ទស្សនទាន និងទ្រឹស្តីរបស់អ្នកប្រាជ្ញមួយចំនួនដែលទាក់ទងទៅនិងការអភិវឌ្ឍន៍ជនបទ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលជាកត្តាដល់សំខាន់ក្នុងការរីកចម្រើនលើការអភិវឌ្ឍន៍ជនបទ ដូចជាយុទ្ធសាស្ត្រ ដំណាក់កាលនៃការអភិវឌ្ឍជាដើម។ ឧទាហរណ៍: ដូចជាទ្រឹស្ត្រីរបស់លោក Big Push ដែលបានបង្ហាញថាកត្តាដែលធ្វើឲ្យប្រទេសនីមួយៗមានកំណើនសេដ្ឋកិច្ចគឺ តាមរយៈការបង្កើននូវការវិនិយោគឲ្យ

[20] និស្សិត ផល វិទូ, របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា, ប្រធានបទ៖ ការកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍផ្លូវលំ(សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១១) ទំព័រទី៤០

កាន់តែច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអប់រំ រួមផ្សំនិងការវិនិយោគជលក្ខណៈឯកជន វាអាចនិងធ្វើឲ្យកើនឡើងនូវផលិតភាពក្នុងការផលិតទំនិញ និងសេវាកម្ម។ ក្រៅពីនេះទៅទៀត ជំពូកទី១នេះ ក៏បានលើកឡើងនូវទ្រឹស្តីផ្សេងៗជាច្រើនដែលទាក់ទង់ទៅនឹងប្រធានបទដែលអាច ជាប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចផងដែរ។

# ជំពូកទី២
# ស្ថានភាពទូទៅនៃការអភិវឌ្ឍ
# ហេដ្ឋារចនា
# សម្ព័ន្ធនៅឃុំប្រាសាទ

ជំពូកទី២

ស្ថានភាពទូទៅនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅឃុំប្រាសាទ

## ២.១ ប្រវត្តិ និងទីតាំងភូមិសាស្ត្រ

### ២.១.១ ប្រវត្តិឃុំប្រាសាទ

ការពីសម័យបុរាណ ប្រហែលអំឡុងឆ្នាំ ៥២០ ទឹកដីដែលគេស្គាល់ថាជាស្រុកកំពង់ត្របែក សព្វថ្ងៃ មានវត្តតែ២ប៉ុណ្ណោះគឺ វត្តប្រាសាទ និងវត្តព្រៃវៀរ។ វត្តប្រាសាទត្រូវបានអ្នកស្រុកជំនាន់នោះទទួលស្គាល់ថាជាទីសក្ការបូជាដ៏សក្តិសិទ្ធបំផុត ជាពិសេសមានប្រាសាទបុរាណធំមួយក្នុងបរិវេនវត្តនេះ ដែលមានវត្ថុបុរាណមានតម្លៃជាច្រើនទៀតផង (ដោយសារគេឃើញមានកំទេចកំទីផ្ទាំងថ្ម គ្រឹះប្រាសាទយ៉ាងធំ និងជីកឃើញរបស់របរមានតម្លៃជាច្រើននៅក្រោមដីដូចជារទេះ មាស ពាង .....)។ ម្យ៉ាងវិញទៀត ប្រាសាទនេះកាលសម័យនោះ ពុំសូវមានអ្នកហ៊ានចូលប្រាសាទនោះទេ ព្រោះមានព្រៃក្រាស់ព័ទ្ធជុំវិញ ដែលក្រោយមកត្រូវបានគេត្រាយអស់ក្នុងសម័យខ្មែរក្រហម (ពុលពត)។ បន្ទាប់មកវត្តនេះមានភាពល្បីល្បាញ និងមានបារមីខ្លាំងពូកែជាទីបំផុត ដែលកាលសម័យនោះ កាលណាអ្នកស្រុកខ្វះខាតរបស់របរប្រើប្រាស់(ពេលមានពិធីបុណ្យ ការផ្សេងៗ) អាចសុំខ្ចីពីក្នុងវត្តបាន ដោយគ្រាន់តែអុសធូបបន់ស្រន់សុំខ្ចីពីប្រាសាទនោះ លុះស្អែកឡើងអាចយកសង្រែកមករែកចាន ឆ្នាំងដែលតម្រៀបគរក្នុងប្រាសាទជាការស្រេច។ ជាក់ស្តែង លោកយាយដែលផ្តល់បទសម្ភាសន៍បានបន្តទៀតថា លោកយាយធ្លាប់បានរៀនព្រះធម៌នៅទីនោះ និងធ្លាប់បានឃើញពាងបុរាណដែលបានថានោះមែន ដែលពាងនោះមានមាត់តូចអាចត្រឹមលូលដៃចូលប៉ុណ្ណោះ។ ក្នុងពាងនោះដដែល សុទ្ធតែរបរពេញ ប៉ុន្តែលោកយាយបានបញ្ជាក់ថា ដោយសារមនុស្សមានចិត្តមិនទៀងត្រង់ កាលណាសម្លឹងក្នុងពាងដំបូងឃើញមាស តែសម្លឹងយូៗទៅឃើញដង្កូវ ឬពស់ទៅវិញ ដូចនេះមិនមានអ្នកណាហ៊ានប្រថុយយកនោះទេ។ ដូចករណីដែលល្បីតៗគ្នាថា មានលោកតាម្នាក់ដែលនៅក្បែរនោះ គាត់ត្រូវបានប្រាប់ឲ្យទៅយកវត្ថុសំខាន់មួយនៅក្រោមដើមពោធិ៍នៅទិសនិរតីនៃវត្តដដែលនេះ (មាននៅដល់សព្វថ្ងៃ) លោកតានោះត្រូវតម្រូវឲ្យទៅយកនៅថ្ងៃត្រង់ តែបម្រាមហាមដើបមើលទៅលើ ប៉ុន្តែគាត់មិនប្រយ័ត្នក៏បានល្មើសបម្រាម ទីបំផុតក៏តក់ស្លុតរត់មកផ្ទះហើយធ្លាក់ខ្លួនឈឺរហូតដល់ស្លាប់។ នៅមានរឿងរ៉ាវជាច្រើនទៀត ដែលបានបញ្ជាក់ពីជំនឿបារមីសក្តិសិទ្ធនៃវត្តនេះ ដែលវាបានធ្វើឲ្យប្រជាជននៅទីនោះជឿជាក់ និងគោរពបូជាយ៉ាងខ្ជាប់ខ្ជួន ថែម

ទាំងមូលមតិជ្រើសយកឈ្មោះវត្តជាតំណាងនៃឃុំទាំងមូល។ ហេតុដូច្នេះហើយ ទើបបានជាឃុំនេះជាប់ឈ្មោះជា ឃុំប្រាសាទ រហូតមកដល់បច្ចុប្បន្ននេះ។[21]

### ២.១.២ ទីតាំងភូមិសាស្ត្រ

ឃុំប្រាសាទ ជាឃុំមួយក្នុងចំណោមឃុំទាំង១៣នៃស្រុកកំពង់ត្របែក ហើយឃុំប្រាសាទមានក្រុមប្រឹក្សាឃុំចំនួន ០៩ រូប ហើយចែកចេញជា ០៩ ភូមិគឺភូមិប្រាសាទ ភូមិចំបក់ ភូមិអំពិល ភូមិពាន់វត្ត ភូមិជ្រលង ភូមិដូនទង់ ភូមិបី ភូមិភ្លង់ និងភូមិថ្កូវ។ ឃុំនេះស្ថិតនៅ៧ គ.ម ពីសាលាស្រុកកំពង់ត្របែក ឆ្ពោះទៅទិសខាងកើត ជាប់នឹងផ្លូវជាតិលេខ ១ ដែលព្រំប្រទល់ខាងត្បូងជាប់នឹង ឃុំប្រធាតុ និងឃុំអន្សោង ខាងជើងជាប់នឹង ឃុំគោខ្ចក និងកន្សោមអក ខាងលិចជាប់នឹង ឃុំកំពង់ត្របែក ខាងកើតជាប់នឹងឃុំព្រៃឈរ ។

ឃុំប្រាសាទមានផ្ទៃដីសរុបចំនួន ២៩.០៨០ គីឡូម៉ែតការេ ក្នុងនោះដែរផ្ទៃដីបង្កបង្កើនផលសរុបចំនួន ២,៩១៨ ហិកតា ទិន្នន័យស្រូវគិតជាមធ្យមក្នុងមួយហិកតា ២.៣ តោន ។[22]

### ២.១.៣ ស្ថានភាពប្រជាជនបច្ចុប្បន្ននៃឃុំប្រាសាទ

ឃុំប្រាសាទមានប្រជាពលរដ្ឋសរុបចំនួន ២,៨៥១ គ្រួសារ ស្មើនឹង ១៣,៣២៧ នាក់ ក្នុងនោះមានស្រីចំនួន ៦,៩០៤ នាក់ ។ ចំនួនប្រជាជនដែលមានអាយុចាប់ពី ០ ដល់ ១៧ឆ្នាំ មាន ៣៦.៧១% ដែលត្រូវនឹង៤៨៩២នាក់ នឹងប្រជាជនពេញវ័យអាយុ១៨ឆ្នាំឡើងទៅ មានរហូតទៅដល់៥៦.៣៥% ដែលត្រូវនិង ៧៥១០នាក់ ហើយចំពោះមនុស្សចាស់មានប្រហែល៦.៩៤% ដែលត្រូវនិង ៩២៥នាក់ប៉ុណ្ណោះ។ ភាគច្រើនប្រជាជននៅក្នុងឃុំនេះ (៧៥%)ប្រកបមុខរបរធ្វើស្រែ ចំណែកឯខ្លះទៀត(២៤%)ប្រកបរបរក្នុងផ្នែកសេវាកម្ម និង(១%)ប្រកបរបរក្នុងផ្នែកសិប្បកម្ម។ចំនួនប្រជាជនចំណាក់ស្រុកសរុប ១៩១០ នាក់ ក្នុងនោះមានស្រីចំនួន ១,០៨២ នាក់ ។ អត្រាកំណើនប្រជាជនជាមធ្យមក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ(២០១២-២០១៦) មានអត្រាចំនួន ១.៦៦% ។[23]

## ២.២ ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍ

### ២.២.១ ចក្ខុវិស័យ

[21] និស្សិត គង់ សេកលីម និង ទូច សេរីព័រ, របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា, ការជំរុញលើកស្ទួយសេដ្ឋកិច្ចជនបទករណីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១៨) ទំព័រទី ៣៧

[22] ដកស្រង់ចេញពីឯកសារដើម កម្មវិធីវិនិយោគបីឆ្នាំរំកិល ( ២០១៩-២០២១) ឃុំប្រាសាទ

[23] ដកស្រង់ចេញពីឯកសារដើម កម្មវិធីវិនិយោគបីឆ្នាំរំកិល ( ២០១៩-២០២១) ឃុំប្រាសាទ

នៅក្នុងអាណត្តិទី៤ របស់ក្រុមប្រឹក្សាឃុំប្រាសាទនេះ បានយកចិត្តទុកដាក់លើការអភិវឌ្ឍមូលដ្ឋានលើកកំពស់ជីវភាពអភិបាលកិច្ចល្អ ប្រកបដោយនិរន្តរភាព ធានាបាននូវគុណភាពជីវិត និងលើកកំពស់ជីវភាពប្រជាពលរដ្ឋកាន់តែល្អប្រសើរ តាមរយៈការសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត ការកែលម្អគុណភាពអប់រំ សេវាសុខាភិបាល ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មចម្រុះ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបង្កើនការយកចិត្តទុកដាក់សន្តិសុខសណ្តាប់ធ្នាប់សង្គមជូនបងប្អូនប្រជាពលរដ្ឋ។ ម្យ៉ាងទៀត ដើម្បីធានាបាននូវសន្តិសុខស្បៀង និងមានប្រាក់ចំណូលកើនឡើង រដ្ឋបាលឃុំត្រូវយកចិត្តទុកដាក់កសាងហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធប្រពលវប្បកម្មចម្រុះ កសិកម្ម គុណភាពសេវាសុខាភិបាល ការអប់រំ សង្គមកិច្ច វប្បធម៌ យេនឌ័រ និងចូលរួមថែរក្សាការពារធនធានធម្មជាតិ និងបរិស្ថាន ដែលជាពិសេសបង្កើនការយកចិត្តទុកដាក់ការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយគុណភាព រហ័សទាន់ចិត្ត និងធានាបានសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនិង ធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋទទួលបាននៅនូវសុខមាលភាព ចំណូលកើនឡើង មានប្រព័ន្ធគមនាគមន៍ ធារាសាស្ត្រ ហើយរស់នៅក្នុងបរិស្ថានដល់ល្អ និងប្រកបដោយសុខសន្តិភាព។

### ២.២.២ គោលបំណង និងគោលដៅ

ចំពោះគោលបំណង និងគោលដៅរបស់ឃុំ គឺផ្តោតសំខាន់ទៅលើផ្នែក៤ សំខាន់ៗគឺៈ

#### ក. ផ្នែកសេដ្ឋកិច្ច

គោលបំណងសំខាន់គឺ ប្រជាពលរដ្ឋមានផ្លូវល្អសម្រាប់ធ្វើដំណើរ និងដឹកជញ្ជូនផលិតផល មានទឹកស្រោចស្រពដីកសិកម្មគ្រប់គ្រាន់ ទិន្នន័យស្រូវកើនឡើងធានាបានសន្តិសុខស្បៀង និងយល់ដឹងពីបច្ចេកទេសកសិកម្ម បច្ចេកទេសចិញ្ចឹមសត្វ ដើម្បីបង្កើនប្រាក់ចំណូល។ ដោយក្នុងនោះគេឃើញមាន ការជួសជុលផ្លូវលំដែលខូចខាត រៀបចំប្រព័ន្ធធារាសាស្ត្រដើម្បីអោយប្រពលរដ្ឋប្រើប្រាស់ និងបង្កើនទិន្នផលស្រូវ ការចិញ្ចឹមសត្វ ដើម្បីប្រាក់ចំណូល។

#### ខ. ផ្នែកសង្គមកិច្ច

ដែលនៅក្នុងផ្នែកសង្គមនិច្ចគឺមានគោលបំណងចំនួន ៤ទៀតគឺ វិស័យអប់រំដែលធ្វើឲ្យប្រជាពលរដ្ឋមានចំណេះដឹង និងសមត្ថភាព រួមចំណែកយ៉ាងសំខាន់ក្នុងការងារសង្គម។ និងគោលបំណងមួយទៀតគឺវិស័យសុខាភិបាលដែលប្រជាពលរដ្ឋមានសុខភាពល្អ យល់ដឹងពីសុខភាពអនាម័យ ជាពិសេសអត្រាមរណៈភាពមាតា និងទារកត្រូវបានលុបបំបាត់។ គោលបំណងមួយទៀតគឺវិស័យសង្គមកិច្ចនិងបង្កើនប្រសិទ្ធិភាព ការផ្តល់សេវាសុខាភិបាល ដើម្បីរក្សាសុខមាលភាពប្រជា

ពលរដ្ឋ និងបង្កើនការយកចិត្តទុកដាក់ក្រុមជនងាយរងគ្រោះ កុមារកំព្រា ជនពិការ ស្ត្រីមេម៉ាយ និងការរំលោភបំពានផ្សេងៗ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ គោលបំណងចុងក្រោយគឺវិស័យយេនឌ័រដែលនិងកាត់បន្ថយអំពើ ហិង្សាក្នុងគ្រួសារ និងការមើលងាយទៅលើស្ត្រីទន់ខ្សោយ។

**គ. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនិងការប្រែប្រួលអាកាសធាតុ**

ចំពោះគោលបំណងវិស័យធនធានធម្មជាតិ បរិស្ថាន គឺប្រជាពលរដ្ឋមានការយល់ដឹងពីបំរែបំរួលអាកាសធាតុ ការការពារបរិស្ថាន កាត់បន្ថយជាតិពុល ដើម្បីបង្កើនត្រីធម្មជាតិ និងជីវចម្រុះ។ រីឯគោលបំណងវិស័យបន្សាំនិងការប្រែប្រួលអាកាសធាតុគឺ ប្រជាជនដែលរងគ្រោះមហន្តរាយទទួលបានសេវាសង្គ្រោះបន្ទាន់និងការឆ្លើយតប ភ្លាមៗ និងបន្សាំ ទៅនឹងអាកាសធាតុ។

**ឃ. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

គោលបំណងសំខាន់នៃវិស័យរដ្ឋបាល គឺធ្វើយ៉ាងណាឲ្យមានការបង្កើនការបម្រើសេវាសាធារណៈ ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ភូមិ ឃុំ ឲ្យបានកាន់តែមានប្រសិទ្ធិភាព។ នឹងគោលបំណងសំខាន់សម្រាប់វិស័យសន្តិសុខសណ្តាប់ធ្នាប់សាធារណៈទាំងមូល គឺប្រជាពលរដ្ឋរស់នៅប្រកបដោយសុវត្ថិភាព និងភាពសុខសាន្តនៅក្នុងសង្គម។[24]

### ២.២.៣. យុទ្ធសាស្ត្រនៃការអភិវឌ្ឍ

**ក. ផ្នែកសេដ្ឋកិច្ច**

ចំពោះយុទ្ធសាស្ត្រនៃការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចមានជាច្រើនទៀត ដែលក្នុងនោះមានដូចជា ការជួសជុលផ្លូវលំក្រាលខ្សាច់ក្រហម, ផ្លូវលំដីស, ថែទាំផ្លូវក្រាលខ្សាច់, បង្កើតគណៈកម្មការថែទាំផ្លូវ ព្រោះដើម្បីបង្កភាពកាន់តែមានភាពងាយស្រួលដល់ប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ ក្នុងការធ្វើដំណើរ និងជាពិសេសគឺប្រជាជនដែលរស់នៅទីនោះអាចប្រកបមុខរបរបានដោយងាយស្រួលដែរ ព្រោះដោយសារផ្លូវមានភាពងាយស្រួលក្នុងការធ្វើដំណើរ ដែលធ្វើមានមនុស្សច្រើនឆ្លងកាត់។

ម្យ៉ាងវិញទៀតគឺការដាក់លូកាត់ផ្លូវ, ស្ពារប្រឡាយស្រោចស្រព និងផ្តល់ម៉ាស៊ីនបូមទឹក ដើម្បីជួយសម្រួលដល់ប្រជាជនក្នុងការកាត់បន្ថយចំណាយក្នុងការជួលម៉ាស៊ីនបូមទឹក។

យុទ្ធសាស្ត្រដែលសំខាន់មួយទៀតគឺការបណ្តុះបណ្តាលបច្ចេកទេសដាំដំណាំនិងចិញ្ចឹមសត្វ, ប្រើប្រាស់ជីគីមីនិងថ្នាំសម្លាប់សត្វល្អិត និងផលិតជីកំប៉ុស្តិ៍, ផ្តល់គ្រាប់ពូជទិន្នផលខ្ពស់ និងសាង

[24] ដកស្រង់ចេញពីឯកសារដើម (ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ២០១៧ ដល់២០២១ ឃុំប្រាសាទ)

សងឡជីវឧស្ម័ន ដើម្បីឲ្យប្រជាជនដែលប្រកបរបរកសិកម្មកាន់តែមានចំណេះដឹង និងយកចំណេះដឹងទាំងអស់នោះទៅអនុវត្តន៍ដូចនេះពួកគេនិងទទួលបានផលច្រើនជាងមុន ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគេឲ្យមានភាពកាន់តែងាយស្រួល។

**ខ.ផ្នែកសង្គមកិច្ច**

យុទ្ធសាស្ត្រចំពោះផ្នែកសង្គមកិច្ចគឺបើកថ្នាក់មត្តេយ្យសហគមន៍, ផ្តល់សម្ភារៈថ្នាក់មត្តេយ្យ និងគ្រូបង្រៀន, ជម្រុញឪពុក ម្តាយឲ្យនាំកូនចូលរៀន និងផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ ដើម្បីឲ្យពួកគេមានទុនក្នុងការបន្តនូវចំណេះដឹងទៅថ្ងៃអនាគត។

សង់បង្គន់អនាម័យតាមខ្ទងផ្ទះ ឬសាលារៀន, ផ្សព្វផ្សាយពីសុខភាពអនាម័យ, ផ្សព្វផ្សាយពីសុខភាពបន្តពូជ, ផ្សព្វផ្សាយពីការបរិភោគទឹកមានសុវត្ថិភាព, ផ្សព្វផ្សាយពីសារៈប្រយោជន៍ការពិនិត្យផ្ទៃពោះ ឬសុខភាពនៅមណ្ឌលសុខភាព ពីព្រោះយើងដឹងហើយថាសុខភាពគឺពិតជាសំខាន់ជាងគេ ហើយនៅពេលដែលប្រជាពលរដ្ឋមានសុខភាពល្អ ដូចនេះពួកគេអាចមានកម្លាំងគ្រប់គ្រាន់ក្នុងការប្រកបមុខរបរ ឬធ្វើកិច្ចការអ្វីមួយ ដើម្បីផ្គត់ផ្គង់ខ្លួនរបស់ពួកគេ ក៏ដូចជាក្រុមគ្រួសាររបស់ពួកគេជាដើម។

ផ្សព្វផ្សាយពីច្បាប់ចរាចរណ៍ផ្លូវគោកជៀសវាងគ្រោះថ្នាក់ផ្សេងៗ, ផ្សព្វផ្សាយពីច្បាប់ស្តីពីការជួញដូរស្រ្តី និងកុមារ, ផ្សព្វផ្សាយពីល្បិចកលឆបោករបស់ជនល្មើស និងផ្សព្វផ្សាយពីច្បាប់សិទ្ធមនុស្សដើម្បីលើកកម្ពស់ និងផ្តល់ចំណេះដឹងទាំងនេះទៅដល់ប្រជាពលរដ្ឋឲ្យយល់កាន់តែច្បាស់អំពីច្បាប់ទាំងអស់នេះ ។

**គ. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនិងការប្រែប្រួលអាកាសធាតុ**

ផ្សព្វផ្សាយច្បាប់ជលផល និងពង្រឹងសកម្មភាពសហគមន៍នេសាទ, ផ្តល់ពូជត្រីធម្មជាតិ និង ស្តារបឹងធម្មជាតិឡើងវិញ និងផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងវិធីត្រៀមបង្ការគ្រោះមហន្តរាយនៃការប្រែប្រួលអាកាសធាតុ។

**ឃ. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

- ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាន
- បណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ស្ត្រី
- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពី ច្បាប់និងខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យដីធ្លី
- ជម្រុញអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព

- ផ្សព្វផ្សាយសកម្មភាពក្រុមប្រជាការពារ។[25]

## ២.៣. រចនាសម្ព័ន្ធគ្រប់គ្រង និងតួនាទីភារកិច្ចសមាជិកឃុំប្រាសាទ

### ២.៣.១ រចនាសម្ព័ន្ធគ្រប់គ្រងឃុំ






[25] ដកស្រង់ចេញពីឯកសារដើម ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ២០១៧ ដល់ ២០២១ ឃុំប្រាសាទ

### ២.៣.២ តួនាទី និងភារកិច្ចរបស់សមាជិក ឃុំប្រាសាទ

**ក. ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងធ្វើការអធិបតីនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់, ធានាថា ក្រុមប្រឹក្សាឃុំ សង្កាត់បានប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ, ធានាថា កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានធ្វើឡើងស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំសង្កាត់ និងរក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

**ខ. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានតួនាទីដូចជាធានាថាក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាចតួនាទី និងមុខងារដូចមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ, ចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់និង ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ។

**គ. មេឃុំ ចៅសង្កាត់**

ចំពោះមេឃុំ ចៅសង្កាត់ គឺធានាថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្ត, រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមព្រឹក្សាឃុំ សង្កាត់, ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការងារថវិកាហរិញ្ញវត្ថុ និងការអនុវត្តអំណាចតួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់, បំពេញភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឲ្យ និងផ្ទេរសិទ្ធដល់ជំទប់ ចៅសង្កាត់រងតាមឋានុក្រមពេលខ្លួនអវត្តមាន។

**ឃ. ជំទប់ទី១ ចៅសង្កាត់រងទី១**

ជំទប់ទី១ ចៅសង្កាត់រងទី១ គឺទទួលជួយមេឃុំចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហរិញ្ញវត្ថុ, បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន និងបំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

**ង. ជំទប់ទី២ ចៅសង្កាត់រងទី២**

ជំទប់ទី២ ចៅសង្កាត់រងទី២ មានតួនាទីជួយមេឃុំ ចៅសង្កាត់លើការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ, បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទីក្នុងករណីដែលមេឃុំ ចៅសង្កាត់ និងជំទប់ទី១ ចៅសង្កាត់រងទី១ អវត្តមាន និងបំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

**ច. គណៈកម្មធិការនានា**

គណៈកម្មធិការនានា គឺជាអ្នកដែលផ្តល់យោបល់ និងជួយការងារជាក់លាក់មួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដូចជាការកសាងផែនការ និងថវិកា, រាយការណ៍អំពីការអភិវឌ្ឍការងារប្រចាំខែរបស់ខ្លួន និងផ្តល់យោបល់ពីវិធានការត្រូវអនុវត្តដែលពាក់ព័ន្ធទៅនឹងការងារទាំងអស់ជាសមត្ថកិច្ចរបស់ខ្លួន។

**ឆ. ស្មៀនឃុំ សង្កាត់**

ថ្វីត្បិតតែស្មៀនឃុំ សង្កាត់ជាបុគ្គលិកស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋបាលស៊ីវិលរបស់ក្រសួងមហាផ្ទៃក៏ពិតមែន ប៉ុន្តែក្នុងការអនុវត្តការងារស្មៀនឃុំ និងសង្កាត់ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់ជាអ្នកជួយក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ជំទប់ ចៅសង្កាត់រង និងគណៈកម្មាធិការនានា បំពេញតួនាទី និងមុខងារស្របទៅតាមតម្រូវការផ្នែកច្បាប់, បំពេញការងាររដ្ឋបាល, ធានាថាសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្របទៅនឹងល័ក្ខខ័ណ្ឌច្បាប់, ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងការអនុវត្តកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ឃុំ សង្កាត់, ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណៈកម្មាធិការលើកលែងតែការទទួលការអនុញ្ញាតឲ្យអវត្តមានជាមុនពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំឲ្យមានក្តារខៀនព័ត៌មានមួយ ឬច្រើនកន្លែង ដើម្បីបិទផ្សាយសេចក្តីជូនដំណឹង សេចក្តីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ សម្រាប់ឲ្យសាធារណៈជនទូទៅបានដឹងព័ត៌មាន។

**ជ. បុគ្គលិកឃុំ សង្កាត់**

មាត្រា២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ចែងថា " ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌរដ្ឋ ដើម្បីជួយកិច្ចការរបស់ខ្លួនតាមសេចក្តីត្រូវការ និងការចាំបាច់នៃការងារ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តយការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់"។

បែបបទនៃការជ្រើសរើសបុគ្គលិកឃុំ សង្កាត់មានបរិយាយនៅក្នុងសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់។

**ឈ. មេភូមិ និងជំនួយការមេភូមិ**

ឈ.១ មេភូមិ

ចំពោះមេភូមិទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន, តំណាងឲ្យប្រជាពលរដ្ឋទាំងអស់ក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់, បង្កើនការពិគ្រោះយោបល់ ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់, នឹងត្រូវធានាផ្តល់ព័ត៌មានជាឯកសារសាធារណៈដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន។ ហើយឯកសារព័ត៌មានទាំងនោះអាចរួមមានព័ត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់ , ត្រូវទទួលត្រូវអនុវត្តកិច្ចការដែលបានប្រគល់ឲ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។និងចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ សង្កាត់នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួនមានជាអាទិ៍៖

- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីតម្រូវការ និងផលប្រយោជន៍របស់ភូមិ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីរបៀបបង្កើន និងកសាងសមត្ថភាព និងធនធានរបស់ភូមិ
- ផ្តល់យោបល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់អំពី៖
    - តម្រូវការ និងអាទិភាពរបស់ភូមិ ដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
    - ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន
    - ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួននីមួយ។

**បញ្ញាត់៖**

- ➢ មេភូមិមិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬការផ្ទេរអំណាច ឬការចាត់ចែងដទៃទៀតក្នុងនាមភូមិបានឡើយ។
- ➢ មេភូមិពុំមានសិទ្ធិអំណាចសម្រេចបញ្ហាណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុម ប្រឹក្សាឃុំ សង្កាត់ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ ឬសង្កាត់ស្របតាម ប្រកាសរបស់ក្រសួងមហាផ្ទៃបានឡើយ។

- ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចផ្ទេរអំណាចដល់បុគ្គល ឬគណៈកម្មាធិការ ឬអង្គការ ណាមួយនៅក្នុងភូមិបានឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុង ប្រកាសរបស់ក្រសួងមហាផ្ទៃ។

ឈ.២.ជំនួយការមេភូមិ

- **អនុប្រធានភូមិ** ទទួលការងារជំនួសមេភូមិក្នុងពេលដែលមេភូមិអវត្តមាន ដោយមានមូលហេតុច្បាស់លាស់ ដូចជាមានជំងឺ ឬមានបេសកម្មចេញក្រៅឃុំ សង្កាត់របស់ខ្លួនលើសពី១ថ្ងៃ។ ក្រៅពីនេះអនុប្រធានភូមិត្រូវទទួលជួយមេភូមិលើការអនុវត្តគម្រោងអភិវឌ្ឍន៍នានាក្នុងភូមិតាមគម្រោងផែនការរបស់ឃុំ សង្កាត់។
- **សមាជិកភូមិ** ទទួលជួយធ្វើជាលេខាធិការឲ្យភូមិ និងទទួលជួយមេភូមិលើការងារស្ថិតិ ការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ភូមិ។

**បញ្ជាក់៖** ក្រៅពីការងារខាងលើនេះមេភូមិអាចធ្វើការបែងចែក ឬប្រគល់ភារកិច្ចដល់ អនុប្រធានភូមិ និងសមាជិកភូមិតាមការចាំបាច់ និងធ្វើសេចក្ដីរាយការណ៍ជូនមេឃុំ ចៅសង្កាត់សាមី។[26]

## ២.៤. ក្របខ័ណ្ឌវិនិយោគ និងគម្រោងវិនិយោគរបស់ឃុំប្រាសាទ

### ២.៤.១. ក្របខ័ណ្ឌវិនិយោគ

ថវិការបស់ឃុំប្រាសាទឆ្នាំ ២០១៩ សរុបចំនួន ១២៥,៧២២,៧០៩រ ក្នុងនោះទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋានមានចំនួន ៣៥០ ០០០រ ហើយថវិកា ទាំងនេះប្រើប្រាស់ផ្ដោតសំខាន់លើដូចជា៖

- គម្រោងជួលជុលផ្លូវលំក្រាលខ្សាច់ក្រហម ប្រវែង ២.៥ គីឡូម៉ែត្រ ចំណាយអស់ថវិកាចំនួន ១១៦.៩១លានរៀល ដែលមានទីតាំងនៅក្នុងភូមិប្រាសាទ និងភូមិក្លូង។
- គម្រោងសាងសង់លូកាត់ផ្លូវ ប្រវែង ១ គីឡូម៉ែត្រ ចំណាយអស់ថវិកាចំនួន ៤.២ លានរៀល ដែលមានទីតាំងស្ថិតនៅភូមិក្លូង។
- គម្រោងឧបត្ថម្ភដល់គ្រូមត្តេយ្យសហគមន៍ នៅភូមិចំនួន៣ភូមិក្នុងរយៈពេល៩ខែដែលចំណាយអស់ថវិការអស់៥.៤លានរៀល។

[26] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា, ការជំរុញលើកស្ទួយសេដ្ឋកិច្ចជនបទករណីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង របស់និស្សិត គង់ សេកលីម និង ទូច សេរីព័រ ឆ្នាំ២០១៨ ទំព័រទី ៤២

- ឧបត្ថម្ភសម្ភារៈមត្តេយ្យសហគមន៍ គ្រប់ភូមិនៅឃុំប្រាសាទ ក្នុងរយៈពេល៩ខែដែលចំណាយអស់០.៧២លានរៀល។
- ជួយធ្វើការផ្សព្វផ្សាយអំពីសុខភាពអនាម័យនៅក្នុងឃុំប្រាសាទក្នុងរយៈពេលពេញ១ឆ្នាំដែលចំណាយអស់៣.២លានរៀល។

**២.៤.២. គម្រោងវិនិយោគ**

**២.៤.២.១. ថវិកាវិនិយោគតាមប្រភព**

ឆ្នាំ ២០១៩ ការវិនិយោគនៅក្នុងឃុំប្រាសាទបានទទួលប្រភពថវិកាមកពី៖

- ទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន ចំនួន ៣៥០០០០៛
- មូលនិធិអភិវឌ្ឍឃុំ ចំនួន ១២៥,៧២២,៧០៩៛
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង ចំនួន ១២,០០០,០០០៛
- ទុនពីអង្គការវ៉ូមែន ចំនួន ១,៦០០,០០០៛

លើសពីនេះទៅទៀត ក៏ទទួលបានទុនពី ស្ថាប័ន ក្រុមហ៊ុន និងអង្គការនានាផងដែរ។

**២.៤.២.២ គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ**

**ក. ផ្នែកសេដ្ឋកិច្ច**

- មានការថែទាំផ្លូវជាប្រចាំ (DBST) ប្រវែង ១២០០ ម៉ែត្រ ចំណាយអស់ប្រហែល ១២០០០០០០៛ ដែលស្ថិតនៅភូមិចំបក់។
- បណ្តុះបណ្តាលផ្នែកយេនឌ័រ និងអាហារូបត្ថម្ភទៀតអស់ ចំនួន ៦វគ្គ ចំណាយអស់ប្រហែល ៥១២៤០០០៛ ដែលស្ថិតនៅក្នុងឃុំ។
- ចែកមាន់ ចំនួន១លើក ចំណាយអស់ប្រហែល ២២០០០០០៛ ដែលស្ថិតនៅក្នុងឃុំ។
- ចែកពូជបន្លែ ចំនួន១លើក ចំណាយអស់ប្រហែល ១០៥៦០០០០៛ ដែលស្ថិតនៅក្នុងឃុំ។

ក្រៅពីនេះ ក៏មានសេវាកម្មផ្សេងៗ ដែលជួយដល់ការវិនិយោគផងដែរ ប៉ុន្តែពុំទាន់មានការបញ្ជាក់ចំនួនទឹកប្រាក់ច្បាស់លាស់នោះទេ។

**ខ.ផ្នែកសង្គមកិច្ច**

- កម្មវិធីចម្រោះទឹកបង្គន់អនាម័យ ចំនួន ១ឆ្នាំ ចំណាយអស់ប្រហែល ៨៨០០០០០០៛ ដែលធ្វើនៅគ្រប់ភូមិ។
- បង្គន់អនាម័យ ចំនួន ១ឆ្នាំ ចំណាយអស់ប្រហែល ៥៧៦០០០០៛ ដែលធ្វើនៅគ្រប់ភូមិ។
- សាលារៀន ចំនួន ១ឆ្នាំ ចំណាយអស់ប្រហែល ៦០០០០០០០៛ ស្ថិតនៅសាលារៀន។

- កម្មវិធីផ្ដល់ការថែទាំគាំទ្រដល់អ្នកផ្ទុក និងកើតជម្ងឺអេសដ៍ និងកុមាររងគ្រោះដោយសារជម្ងឺអេសដ៍ ចំនួន១ឆ្នាំ ចំណាយអស់ប្រហែលចំនួន ៥៥៥៦០០០០៛ ដែលធ្វើនៅគ្រប់ភូមិនៅក្នុងឃុំប្រាសាទ។
- ប័ណ្ណសុខភាព CLTS ចំនួន ១ឆ្នាំ ចំណាយអស់ប្រហែល ៣៦០០០០០០៛ ដែលធ្វើនៅគ្រប់ភូមិ។និងផ្សព្វផ្សាយកម្មវិធី CLTS ចំនួន៣០ខែ ចំណាយអស់ប្រហែល ៦០០០០០០៛ ដែលធ្វើនៅ ៥ភូមិ។
- វគ្គបណ្ដុះបណ្ដាល និងផ្សព្វផ្សាយ SCWASH និងផ្សព្វផ្សាយ CLT/BCE ប៉ុន្តែមិនទាន់មានការបញ្ជាក់អំពីចំនួនទឹកប្រាក់នោះទេ។

ក្រៅពីពីរផ្នែកខាងលើ ក៏មានការវិនិយោគលើផ្នែកធនធានធម្មជាតិ និងបរិស្ថាន ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ និងផ្នែកយេនឌ័រផងដែរ។

### ២.៤.២.៣ គម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ

#### ក.ផ្នែកសេដ្ឋកិច្ច

- ជួសជុលផ្លូវលំដីស ប្រវែង ៨.៨ គីឡូម៉ែត្រ ចំណាយអស់ប្រហែល ១៥១,៩៦០,០០០៛ ដែលស្ថិតនៅ ភូមិចំនួន៧។
- ស្ពារប្រឡាយស្រោចស្រប ប្រវែង១០គីឡូម៉ែត្រ ចំណាយអស់ប្រហែល ២៥២,៩០០,០០០៛ ដែលស្ថិតនៅចំនួន៧ភូមិ។
- សាងសង់ទរបណ្ដោត ប្រវែង ២គីឡូម៉ែត្រ ចំណាយអស់ប្រហែល ៣០,០០០,០០០៛ ដែលស្ថិតនៅ ភូមិចំនួន២ភូមិ។
- ផ្ដល់ម៉ាស៊ីនបូមទឹក ចំនួន២គ្រឿងក្នុងមួយសប្ដាហ៍ ចំណាយអស់ប្រហែល ៤០,០០០,០០០ ៛ ដែលស្ថិតនៅក្នុងឃុំប្រាសាទ។
- ជីកស្រះចិញ្ចឹមត្រី ចំនួន១៨ស្រះ ចំណាយអស់ ៣៦,០០០,០០០៛ ដែលស្ថិតនៅគ្រប់ភូមិ
- ផ្ដល់ទុនសម្រាប់ប្រកបមុខរបរ ចំនួន១លើក ចំណាយអស់ប្រហែល៦៥,០០០,០០០៛ ដែលស្ថិតនៅគ្រប់ភូមិ។
- បណ្ដុះបណ្ដាលជំនាញកាត់ដេរ ចំនួន១វគ្គ ក្នុងរយៈពេល៣ខែ ដែលចំណាយអស់ប្រហែល ២,០០០,០០០៛ ដែលស្ថិតនៅគ្រប់ភូមិ
- ផ្ដល់ពូជគោ ចំនួន ១៩៥ក្បាល ចំណាយអស់ប្រហែល ១៩៥,០០០,០០០៛ ដែលស្ថិតនៅក្នុងឃុំ

- បណ្តុះបណ្តាលជំនាញជួសជុលម៉ាស៊ីនគ្រប់ប្រភេទ ចំនួន១វគ្គ ដែលចំណាយអស់ប្រហែល២,០០០,០០០៛ ដែលស្ថិតនៅក្នុងឃុំប្រាសាទ។

**ខ.ផ្នែកសង្គមកិច្ច**

- ផ្សព្វផ្សាយដល់ឪពុកម្តាយឲ្យយល់ដឹងពីសារៈប្រយោជន៍នៃការសិក្សា ចំនួន ៩លើក ចំណាយអស់ប្រហែល ៣៦០០០០០៛ ដែលស្ថិតនៅគ្រប់ភូមិ
- ផ្តល់អាហាររូបករណ៍ដល់សិស្សក្រីក្រ ចំនួនទាំងអស់ ២៧០នាក់ ចំណាយអស់ប្រហែល ៦៥,០០០,០០០៛ ដែលស្ថិតនៅតាមសាលា
- ផ្តល់ថ្នាក់មត្តេយ្យសហគមន៍ ចំនួន៦ថ្នាក់ ចំណាយអស់ប្រហែល ២៤,០០០,០០០៛ ដែលស្ថិតនៅឃុំប្រាសាទ
- បើកថ្នាក់បំប៉ុនដល់កុមារដែលរៀនខ្សោយ នៅតាមសាលា ចំនួន៣សាលា ដែលចំណាយអស់ប្រហែល ៤,០០០,០០០៛ ដែលស្ថិតនៅតាមសាលានៅក្នុងឃុំ
- ធ្វើការឧបត្ថម្ភសៀវភៅសម្រាប់សិស្សានុសិស្សអាន ចំនួន ៦០០ក្បាល ចំណាយអស់ប្រហែល ៦,០០០,០០០៛ ដែលស្ថិតនៅតាមសាលា
- ប្រជុំនិងពង្រឹងការងារអប់រំរបស់សាលា ដោយធ្វើការប្រជុំចំនួន១២ដង ចំណាយអស់ប្រហែល ១,២០០,០០០៛ ដែលធ្វើឡើងស្ថិតនៅសាលាឃុំ
- ផ្តល់រទេះដល់សិស្សដែលពិការ ចំនួន១១គ្រឿង ចំណាយអស់ប្រហែល ៨,៨០០,០០០៛ ដែលស្ថិតនៅគ្រប់ភូមិ
- ផ្តល់ការគោរពដល់អ្នកផ្ទុកមេរោគអេដស៍ ចំនួន១លើក ចំណាយអស់ប្រហែលចំនួន ៤,០០០,០០០៛ ដែលស្ថិតនៅគ្រប់ភូមិ
- ធ្វើការផ្សព្វផ្សាយពីច្បាប់និងសិទ្ធមនុស្ស ចំនួន៩លើក ចំណាយអស់ប្រហែលមានចំនួន ៣,៦០០,០០០៛ ដែលស្ថិតគ្រប់ភូមិ
- រៀបចំកែលំអសាងសង់ប្រព័ន្ធទឹកស្អាត ចំនួន ១ កន្លែង ចំណាយអស់ប្រហែលមានចំនួន ៤,០០០,០០០៛ ដែលស្ថិតនៅ ភូមិប្រាសាទ
- បណ្តុះបណ្តាលពីយេនឌ័រ ធ្វើឡើងចំនួន២លើកក្នុងនោះ ដែលធ្វើការចំណាយអស់ប្រហែល ៤,០០០,០០០៛ ដែលស្ថិតនៅគ្រប់ភូមិ
- ធ្វើការផ្សព្វផ្សាយពីការជួញដូរមនុស្ស បានចំនួន៩លើក ដែលធ្វើការចំណាយអស់ប្រហែល ៣,៦០០,០០០៛ ដែលស្ថិតនៅគ្រប់ភូមិ។

- បន្ថែមបុគ្គលិកពេទ្យដល់មណ្ឌលសុខភាព ប្រហែលចំនួន ៥នាក់ ដែលចំណាយអស់ប្រហែល ២០០,០០០៛ ដែលស្ថិតនៅតាមមណ្ឌលសុខភាព។
- ផ្តល់ឱសថបន្ថែមដល់មណ្ឌលសុខភាព ប្រហែលចំនួន ៤ត្រីមាស ដែលចំណាយអស់ប្រហែល ៨០០,០០០៛ ដែលស្ថិតនៅតាមមណ្ឌលសុខភាព។
- ផ្តល់សម្ភារៈពិនិត្យជម្ងឺទូទៅដល់មណ្ឌលសុខភាព ចំនួន១កំប្លេ ក្នុងរយៈពេល ១សប្តាហ៍ ដែលចំណាយអស់ប្រហែល ២,០០០,០០០៛។

**គ. ផ្នែកធនធានធម្មជាតិ និងបរិស្ថាន**

- ផ្សព្វផ្សាយច្បាប់ជលផល ចំនួន៩លើក ចំណាយអស់ប្រហែល ៣,៦០០,០០០៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្តល់ពូជត្រីធម្មជាតិ ចំនួន៩៣០០០ក្បាល ចំណាយអស់ប្រហែល ៧,៤០០,០០០៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្សព្វផ្សាយដល់ថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋពីផលប៉ះពាល់នៃគ្រោះមហន្តរាយ និងត្រៀមរៀបចំផែនបង្ការ ចំនួន៩លើក ដែលចំណាយថវិការអស់ប្រហែល ៣,៦០០,០០០៛ ដែលស្ថិតនៅគ្រប់ភូមិ។

**ឃ. ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ**

- ផ្សព្វផ្សាយពីច្បាប់គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព សរុបចំនួន៩លើក ចំណាយអស់ប្រហែល ៣,៦០០,០០០៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការចុះសំបុត្រអត្រានុកូលដ្ឋានចំនួន៩លើក ដែលចំណាយអស់ប្រហែល ២៥៨៨០០០០៛ ដែលស្ថិតនៅគ្រប់ភូមិ។
- បណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ស្ត្រី ចំនួន១វគ្គ ចំណាយអស់ប្រហែល ២,០០០,០០០៛ ដែលធ្វើឡើងនៅឃុំប្រាសាទ។
- បណ្តុះបណ្តាលជំនាញសម្របសម្រួលការងារស្ត្រី ចំនួន១វគ្គ ដែលនិងចំណាយអស់ប្រហែល ២,០០០,០០០៛ ដែលធ្វើឡើងនៅឃុំប្រាសាទ។
- ប្រជុំពង្រឹងពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ មេភូមិ និងធអ្នកពាក់ព័ន្ធ ចំនួន១២លើកក្នុង១ឆ្នាំ ដែលចំណាយអស់ប្រហែល ១,២០០,០០០៛ ដែលប្រព្រឹត្តទៅនៅសាលាឃុំប្រាសាទ។

- ផ្តល់ក្តារព័ត៌មាននៅតាមភូមិ ចំនួន ១០កន្លែង ដែលចំណាយអស់ប្រហែល ៥,០០០,០០០៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន សរុបចំនួន៩លើក ដែលចំណាយអស់ប្រហែល ៣,៦០០,០០០៛ ដែលស្ថិតនៅគ្រប់ភូមិ។

**ង. ផ្នែកយេនឌ័រ**

- បណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ស្ត្រី ចំនួន១វគ្គ ចំណាយអស់ប្រហែល ២០០០០០០៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស ចំនួន៩លើក ចំណាយអស់ប្រហែល ៣៦០០០០០៛ ដែលស្ថិតនៅគ្រប់ភូមិប្រាសាទ។
- ផ្សព្វផ្សាយច្បាប់ទប់ស្កាត់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារចំនួន ១កន្លែង ចំណាយអស់ប្រហែល ៣៦០០០០០៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្សព្វផ្សាយពីល្បិចកលឆបោករបស់ជនល្មើសផ្សេង ចំនួន៩លើក ដែលចំណាយអស់ប្រហែល ៣៦០០០០០៛ ដែលស្ថិតនៅគ្រប់ភូមិ។[27]

## ២.៥. ការប្រព្រឹត្តិទៅនៃដំណើរអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តឃុំប្រាសាទ

បើយើងនិយាយអំពីភាពរីកចំរើននៃហេដ្ឋារចនាសម្ព័ន្ធរបស់ឃុំប្រាសាទ ចាប់តាំងពីមានការកកើតនៃឃុំ រហូតដល់ឆ្នាំ ២០១៧ យើងឃើញមានការអភិវឌ្ឍន៍ជាច្រើនទៅលើប្រព័ន្ធគមនាគមន៍ ការអប់រំនិងសាលារៀន និងរដ្ឋបាលសន្តិសុខជាដើម។ ខាងក្រោមនេះ គឺជាដំណើរការនៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តរួមមាន៖

- ប្រព័ន្ធគមនាគមន៍: ចំពោះប្រវែងផ្លូវជាតិដែលឆ្លងកាត់ឃុំសង្កាត់មានប្រវែងសរុប៨០០០ ម៉ែត្រ, ផ្លូវខេត្តរាជធានីឬក្រុងដែលឆ្លងកាត់ឃុំមានប្រវែងសរុប៥០០០ម៉ែត្រ, ចំនួនខ្សែផ្លូវដែលបានសាងសង់នៅក្នុងឃុំមានចំនួនសរុប ៧ខ្សែដែលមានប្រវែងសរុបចំនួន១៩,២៩៥ ម៉ែត្រ។ បន្ទាប់ពីនេះគេឃើញមានផ្លូវលំក្រាលគ្រួសក្រហម ខ្សាច់ភ្នំសរុបប្រវែង៥,៨០០ ម៉ែត្រ, ផ្លូវលំដីសរ (លើកដីសរួច) សរុបប្រវែងទាំងអស់ ៩,១៩៥ម៉ែត្រ និងផ្លូវលំធម្មតាសរុបប្រវែង៨,៩០០ម៉ែត្រ។
- ការអប់រំ និង សាលារៀន: ការរីកចម្រើននៃប្រព័ន្ធអប់រំដែលបណ្តាមកពី មានការកើនឡើងនូវមជ្ឈមណ្ឌលអប់រំដូចជា សាលាមត្តេយ្យសហគមន៍ចំនួន៣កន្លែង, សាលាមត្តេយ្យរដ្ឋ

[27] ដកស្រង់ចេញពីឯកសារដើម:កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៩ ២០២១

សរុបចំនួន ៣កន្លែងដែលក្នុងនោះមានបន្ទប់សរុប៧បន្ទប់និងថ្នាក់សរុបចំនួន៧ថ្នាក់, សាលាបឋមសិក្សារដ្ឋសរុបចំនួន ៩កន្លែង ដែលមានបន្ទប់ចំនួន៥២បន្ទប់ និងថ្នាក់ចំនួន៥១ថ្នាក់, សាលាអនុវិទ្យាល័យចំនួន១កន្លែង ដែលមានបន្ទប់ចំនួនទាំងអស់១១បន្ទប់និងថ្នាក់ចំនួន១១ថ្នាក់, សាលាវិទ្យាល័យរដ្ឋ១កន្លែងដែលមានបន្ទប់ចំនួន២២បន្ទប់និងថ្នាក់ចំនួន២២ថ្នាក់, សាលាបឋមសិក្សារដ្ឋមានទឹកស្អាតប្រើប្រាស់សរុបចំនួន៩កន្លែង, សាលាបឋមរដ្ឋដែលមានអណ្តូងខួងប្រើប្រាស់សរុបចំនួន៩កន្លែង, ចំនួនបង្គន់ដែលមានលក្ខណៈស្តង់ដារសរុបចំនួននៅតាមសាលាបឋមសរុបចំនួន២៥បន្ទប់, ចំនួនសាលាអនុវិទ្យារដ្ឋដែលមានទឹកស្អាតប្រើប្រាស់សរុបចំនួន១កន្លែង, និងចំនួនបង្គន់ដែលមានលក្ខណៈស្តង់ដាសរុបនៅតាមសាលាអនុវិទ្យាល័យចំនួន២៣បង្គន់។

+ រដ្ឋបាលនិងសន្តិសុខៈ សកម្មភាពរបស់បុគ្គលិកសុខាភិបាលបានចុះកន្លងមកក្នុងរយៈពេល១២ខែ (អប់រំណែនាំអំពីសុខភាព ចាក់ថ្នាំបង្ការ...)សរុបចំនួន ៩ដង, ចំនួនអ្នកស្ម័គ្រចិត្តផ្នែកសុខភាពភូមិបំរើការងារនៅក្នុងឃុំសង្កាត់សរុបចំនួន ២ដង និងគ្រួសារដែលមានជនរងគ្រោះដែលទទួលជំនួយផ្នែកសង្គមកិច្ច ពីឃុំក្នុងរយៈពេល១២ខែកន្លងមកសរុបចំនួន២ដង។ [28]

## ២.៦ សមិទ្ធិផលនៃការអភិវឌ្ឍឃុំប្រាសាទ

### ១. ការគ្រប់គ្រងរដ្ឋបាលឃុំ

- អំពីក្រុមប្រឹក្សា

ឃុំប្រាសាទមាន៩រូប ស្រី ១រូប រីឯការលើកកំពស់ប្រសិទ្ធិភាព ការគ្រប់គ្រងរដ្ឋបាលឃុំតាមរយៈការប្រជុំ យោងតាមបទបញ្ជាផ្ទៃក្នុង ក្រុមប្រឹក្សាឃុំបានធ្វើការប្រជុំអាណត្តិទៀងទាត់ជារៀងរាល់ខែ និងការប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា បានប្រជុំអនុម័តលើការងារចាំបាច់ និងកិច្ចការផ្សេងៗទៀត ដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាឃុំបានប្រជុំពិគ្រោះយោបល់ ជាមួយប្រជាពលរដ្ឋ នូវផែនការ៥ឆ្នាំ និងកម្មវិធីវិនិយោគឃុំ ១ឆ្នាំម្តងៗស្វែងរកតម្រូវការនិងដំណោះស្រាយជូនប្រជាពលរដ្ឋ។ ហើយក្រុមប្រឹក្សាឃុំ និង គ.ក.ន. បានប្រជុំលើកនៅផែនការ និងកម្មវិធីវិនិយោគឃុំ បញ្ចូលនូវគម្រោងមួយចំនួនពាក់ព័ន្ធស្ត្រី និងកុមារ ដើម្បីក្រុមប្រឹក្សាឃុំធ្វើការអនុម័ត។

- ការងាររដ្ឋបាល

[28] ដកស្រង់ចេញពីឯកសារដើម សេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៨ ឃុំប្រាសាទ

ការផ្តល់សេវារដ្ឋបាលៈ ក្នុងការធ្វើលិខិតស្នាមផ្សេងៗ មានដូចជា ច្បាប់ការ ច្បាប់បុណ្យ សំបុត្រកំណើតចំនួន ៨៥៣នាក់ សំបុត្របញ្ជាក់កំណើតចំនួន ១៥៨៨នាក់ សំបុត្រអាពាហ៍ពិពាហ៍ចំនួន ២៧៨គូរ សំបុត្រមរណៈភាពចំនួន ២៣៦នាក់ និងសេវាផ្សេងៗទៀតបានធ្វើជូន ប្រជាជនតាមសំណូមពរ និងទាន់ពេលវេលា។

ការទំនាក់ទំនង ការគាំទ្រ និងសហប្រតិបត្តិការ រវាងរដ្ឋបាលឃុំជាមួយរដ្ឋបាលក្រុង ស្រុក ខេត្ត មន្ទីអង្គភាពនានា រយៈពេល៥ឆ្នាំ ឃុំបានទំនាក់ទំនងស្វែងរកការងារ គាំទ្រ ពីស្រុក ខេត្តអង្គភាពនានា មន្ទីអង្គភាពនានា មន្ទីវិស័យ អង្គការ សប្បុរសជន និងដៃគូរអភិវឌ្ឍន៍ រូបវន្ត និងអរូបវន្ត ដើម្បីសំដៅឲ្យជីវភាពប្រជាពលរដ្ឋកាន់តែប្រសើរឡើង និងកាត់បន្ថយភាពក្រីក្រ។

**២. ប្រាក់មូលនិធិឃុំ ឆ្នាំ២០១២-២០១៧**

- ជួលជុសផ្លូវលំដីស ប្រវែង ១២១៣០ ម៉ែត្រ
- ក្រាលខ្សាច់ភ្នំ ប្រវែង ៤០៩០ ម៉ែត្រ
- ចៃទាំផ្លូវ ប្រវែង ៤៧០០ ម៉ែត្រ
- លូ ទោល ១០ កន្លែង មុខកាត់ ៦០
- លូ ភ្លោះ ២ កន្លែង មុខកាត់ ៨០

សរុបថវិកាចំនួន ៤ ៩២១ ៦៥០ ០០០៛, សរុបទុនចូលរួម ២ ១៥០ ០០០៛

បន្ថែមពីនេះ ឃុំក៏បានកសាងអាគារមួយខ្នង បណ្តោយ ប្រវែង ៨ម៉ែត្រ ទទឹង ៤ម៉ែត្រ ប្រក់ដែក ដោយទទួលបានការឧបត្ថម្ភពីសប្បុរសជន ប្រជាពលរដ្ឋ អាចារ្យ នាយកសាលា នាយករង សរុប ១៤ ៤២០ ០០០៛។

**៣. ប្រាក់មូលនិធិមនុស្សធម៌ ស ខេង**

ការផ្គត់ផ្គង់សមាគមមូលនិធិ មនុស្សធម៌ ស ខេង គិតចាប់ពីថ្ងៃទី១៦ ខែ តុលា ឆ្នាំ ២០១៣ ដល់ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦

- ស្ត្រីសម្រាលកូន ៤១៥នាក់ កូន៤២១នាក់ ទឹកប្រាក់ ៧៨ ៧៩៩ ០០០៛
- ចូលបុណ្យសព ១៤៥នាក់ ទឹកប្រាក់ ២៨ ៨០០ ០០០៛
- អ្នកជំងឺ ១នាក់ ទឹកប្រាក់ ២០០ ០០០៛

ដូចនេះចំនួនទឹកប្រាក់មូលនិធីមនុស្សធម៌របស់លោក ឯកឧត្តម ស ខេង ក្នុងការជួយផ្គត់ផ្គង់សមាគមមូលនិធីមនុស្សធម៌សរុបមានចំនួន១០៧ ៧០០ ០០០៛។

**៤. វិស័យសេដ្ឋកិច្ច**

សេដ្ឋកិច្ចទាំងមូលនៃជីវភាពរបស់ប្រជាជនដែលរស់នៅឃុំនេះ ក្នុងឆ្នាំ២០១៧ គឺគេសង្កេតឃើញថា ផ្ទៃដីធ្វើស្រែសរុប ២,៤០៨.៥ ហិចតា ដែលទទួលបានបរិមាណស្រូវសរុប៥,៩៨១.0 ហិចតា និងទិន្នផលស្រូវសរុបស្មើនឹង ២.៥ តោនក្នុងមួយហិចតា និងផ្តល់ជាចំណូលជូនប្រជាពលរដ្ឋជាមធ្យមគឺ ៩១.៥ដុល្លា។ ក្រៅពីការធ្វើស្រែប្រជាជននៅតំបន់នោះ គឺមានការដាំដុះនូវដំណាំក្នុងរយៈពេលខ្លី-វែង និងការចិញ្ចឹមសត្វ ដែលអាចផ្តល់នូវប្រាក់ចំណូលមួយចំនួនដល់ប្រជាជនជាមធ្យម ប្រជាជនម្នាក់ទទួលបានប្រាក់ចំណូលពីដំណាំរយៈពេលខ្លីវែង និងការចិញ្ចឹមសត្វមានចំនួន ៥៧.៩ ដុល្លាក្នុងម្នាក់នៅក្នុងឆ្នាំ ២០១៧។

ក្រៅពីនេះគេឃើញប្រជាជនមួយភាគទៀតមានមុខរបរចំបងក្រៅពីវិស័យកសិកម្មចំនួន ២,៣៦១នាក់ដែលប្រកបរបរសេវាកម្ម និងអាជីវកម្មផ្ទាល់ខ្លួន។

**៥. វិស័យអប់រំ**

មត្តេយ្យសហគមន៍មានសរុបចំនួន ៣ បន្ទប់ ដែលមានគ្រូបង្រៀនចំនួន៣នាក់ និងសិស្សកំពុងសិក្សាចំនួន៦៥នាក់, សាលាមត្តេយ្យរដ្ឋមានចំនួន ៣កន្លែង មានបន្ទប់ចំនួន៧បន្ទប់, ថ្នាក់ចំនួន៧ថ្នាក់, គ្រូបង្រៀនចំនួន៧នាក់ និងសិស្សកំពុងសិក្សាចំនួន ១៩១នាក់ និងសាលាមត្តេយ្យឯកជនមានចំនួន១កន្លែង មានបន្ទប់ចំនួន៥បន្ទប់, ថ្នាក់ចំនួន១០ថ្នាក់, គ្រូបង្រៀនចំនួន ៥នាក់ និងសិស្សកំពុងសិក្សាចំនួន ១៨០នាក់។

សាលាបឋមសិក្សាមានចំនួន៨កន្លែង មានបន្ទប់ចំនួន៥២បន្ទប់, ថ្នាក់ចំនួន៥១ថ្នាក់, គ្រូបង្រៀនចំនួន៨២នាក់ និងសិស្សកំពុងសិក្សាចំនួន១,៦៧៧នាក់។ និងអនុវិទ្យាល័យរដ្ឋមានចំនួន១កន្លែង ដែលមានបន្ទប់ចំនួន១១បន្ទប់, ថ្នាក់ចំនួន១១ថ្នាក់, គ្រូបង្រៀនចំនួន២៥នាក់ និងសិស្សកំពុងសិក្សាចំនួន៦១៣នាក់។ ហើយចំពោះវិទ្យាល័យរដ្ឋមានចំនួន១កន្លែង ដែលមានបន្ទប់ចំនួន ២២បន្ទប់, ថ្នាក់ចំនួន២២ថ្នាក់, ដោយគ្រូបង្រៀនចំនួន ៤៩នាក់ និងសិស្សកំពុងសិក្សាមានចំនួន ១,១៦១នាក់។

**៦. វិស័យសុខាភិបាល**

ក្រោមការពង្រឹង និងពង្រីកប្រព័ន្ធសុខភាព ដើម្បីធានានូវការផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធិភាព គុណភាព និងសមធម៌ បានធ្វើឲ្យប្រជាពលរដ្ឋនៅក្នុងតំបន់ទទួលបាននូវអត្ថប្រយោជន៍ជាច្រើនដូចជា: ការធ្វើឲ្យប្រជាជនទទួលបានការនូវសុខភាពល្អ និងកាត់បន្ថយនូវការចំណាយទៅលើការព្យាបាលជម្ងឺ, កាត់បន្ថយចំនួនស្លាប់របស់ស្ត្រី និងទារកក្រោយពេលសំរាលកូនរួច បន្ទាប់ពីទទួលបានការពិនិត្យមក និងការព្យាបាលយ៉ាងយកចិត្តទុក

ដាក់ពីគ្រូពេទ្យទាំងក្នុងកំឡុងពេលពពោះ និងពេលសំរាលកូន, កាត់បន្ថយការស្លាប់ដោយជម្ងឺអេដស៍ គ្រុនឈាន គ្រុនចាញ់ ជម្ងឺរបេង និងជម្ងឺឆ្លងផ្សេងៗ ដោយពួកគាត់ទទួលបាននូវការព្យាបាលដោយការយកចិត្តទុកដាក់ និងការពិគ្រោះពិភ្សាពីជម្ងឺដោយគ្រូពេទ្យជំនាញ និងការជួយរក្សាអាថកំបាំងរបស់អ្នកជម្ងឺ, កុមារទទួលបាននូវការផ្តល់ថ្នាំបង្ការ ឬវ៉ាក់សាំងការពារជម្ងឺផ្សេងៗ និងការជម្រុញអោយប្រជាជនទទួលសេវាព្យាបាលនៅមន្ទីរពេទ្យជាដើម។

**៧. វិស័យគមនាគមន៍**

ប្រវែងផ្លូវទៅតាមប្រភេទ ដែលជាសមទ្ធិផលទទួលបានពីការអភិវឌ្ឍក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ:

- ផ្លូវក្រាលខ្សាច់ភ្នំ ៣ខ្សែ ប្រវែង៥០៩០ម៉ែត្រ
- ផ្លូវដីស ៨ខ្សែ ប្រវែង១២,១៣០ម៉ែត្រ
- ថែទាំផ្លូវ ២ខ្សែ ប្រវែង៤,៧០០ម៉ែត្រ
- ផ្លូវកអណ្តើក-មេសាង ១ខ្សែ ប្រវែង២,៨០០ម៉ែត្រ
- ផ្លូវក្រាលកៅស៊ូ ពីផ្សារកអណ្តើកទៅភ្នំឈើកាច់ ក្នុងនោះមានប្រវែង១,៩៥០ម៉ែត្រ ជាថវិការបស់រាជរដ្ឋាភិបាល
- ផ្លូវធម្មជាតិលើកដោយប្រជាជនមានប្រវែង១៤.១៩០ម៉ែត្រ។

**៨. វិស័យធារាសាស្ត្រ**

នៅក្នុងវិស័យធារាស្តាស្ត្រគឺទទួលបានដូចជា ការស្តារប្រឡាយ អកអំបុក ប្រវែង៨០០០ ម៉ែត្រ, ដាក់លូរំដោះទឹកភ្លៀងតាមបណ្តោយផ្លូវជាតិ ប្រវែង ១,៨០០ម៉ែត្រ និងបានធ្វើលូរំដោះទឹកស្អុយ ប្រវែង១,២០០ម៉ែត្រ។ [29]

## ២.៧. បញ្ហាដែលជួបប្រទះ និងដំណោះស្រាយ

### ២.៧.១. បញ្ហាដែលជួបប្រទះ

ទន្ទឹមនឹងភាពជោគជ័យក្នុងការអភិវឌ្ឍជីវភាពប្រជាជននៅក្នុងឃុំប្រាសាទទាំងអស់ខាងលើនេះឃុំក៏ជួបនូវបញ្ហាប្រឈមមួយចំនួនដែលបានធ្វើឲ្យឃុំប្រាសាទមានការអភិវឌ្ឍយឺតៗមានពេលខ្លះមានការបំផ្លិតបំផ្លាញទៀតផង ហើយបញ្ហាទាំងអស់នោះមានដូចខាងក្រោមៈ

[29] ដកស្រង់ពីឯកសារដើម: ឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ២០១៨ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

- ផ្លូវពិបាកធ្វើដំណើរ: បញ្ហានេះកើតមានគ្រប់ភូមិទាំងអស់ដែលនៅក្នុងឃុំប្រាសាទ ពោលគឺភូមិទាំង៩ ដែលមូលហេតុទាំងនេះគឺដោយសារ ផ្លូវលិចទឹក, ខ្វះលូ, ពេលភ្លៀងរអិល, និងខ្វះការថែទាំ។
- ទិន្នផលស្រូវទាប: បញ្ហានេះកើតមានគ្រប់ភូមិក្នុងឃុំប្រាសាទ ហើយមូលហេតុគឺបណ្តាលមកពី ខ្វះពូជស្រូវទិន្នផលខ្ពស់, ខ្វះបច្ចេកទេសដំណាំស្រូវ, ដីខ្សោះជីជាតិ, និងខ្វះបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត។
- ទឹកស្រោចស្រពដីកសិកម្មមិនគ្រប់គ្រាន់: បញ្ហានេះកើតមានឡើងគ្រប់ភូមិក្នុងឃុំប្រាសាទ មូលហេតុដែលបណ្តាមកពី ខ្វះប្រឡាយ, ខ្វះទរបណ្តែត, និងខ្វះម៉ាស៊ីនបូមទឹក។
- សត្វឈឺច្រើន: បញ្ហានេះកើតមានឡើងគ្រប់ភូមិក្នុងឃុំប្រាសាទ ហើយវាបណ្តាលមកពី ខ្វះវ៉ាក់សាំងចាក់ការពារជំងឺសត្វ, ខ្វះបច្ចេកទេសចិញ្ចឹមសត្វ, និងខ្វះបច្ចេកទេសផលិតចំណីសត្វទៀតផង។
- ប្រាក់ចំណូលគ្រួសារទាប: បញ្ហានេះកើតមានគ្រប់ភូមិក្នុងឃុំប្រាសាទ ដែលបណ្តាលមកពីមូលហេតុដូចជា ខ្វះទុនប្រកបមុខរបរ, ខ្វះពូជសត្វចិញ្ចឹម, ខ្វះពូជបន្លែ, ខ្វះបច្ចេកទេសដាំដំណាំ បន្លែ, ខ្វះពូជត្រីចិញ្ចឹម, ខ្វះបច្ចេកទេសចិញ្ចឹមត្រី, និងខ្វះស្រះចិញ្ចឹមត្រីជាដើមច្រើនទៀតដែលជាមូលហេតុ។
- ចំណាកស្រុកច្រើន: កើតមានឡើងគ្រប់ភូមិទាំងអស់ក្នុងឃុំប្រាសាទ ដែលបណ្តាលមកពីប្រជាជនខ្វះជំនាញវិជ្ជាជីវៈ។
- កុមារអាយុពី០៦ទៅ១១ឆ្នាំមួយចំនួនមិនបានចូលរៀន: បញ្ហាកើតមានគ្រប់ភូមិក្នុងឃុំប្រាសាទ ហើយវាកើតឡើងដោយសារតែឪពុកម្តាយខ្វះការយល់ដឹងពីសារៈប្រយោជន៍នៃការសិក្សា និងដោយសារភាពក្រីក្រ។
- កុមារអាយុពី០៣ទៅ០៥ឆ្នាំមួយចំនួនមិនបានចូលរៀន: បញ្ហាមួយនេះកើតមាននៅគ្រប់ភូមិទាំងអស់ក្នុងឃុំនេះ ដែលវាបណ្តាលមកពី ខ្វះថ្នាក់មត្តេយ្យសហគមន៍, ខ្វះគ្រូមត្តេយ្យសហគមន៍, ខ្វះសម្ភារៈថ្នាក់មត្តេយ្យ,និងអាណាព្យាបាលខ្វះការយល់ដឹងពីសារៈប្រយោជន៍ថ្នាក់មត្តេយ្យ
- ក្រុមជនងាយរងគ្រោះ: បញ្ហានេះកើតមានឡើងគ្រប់ភូមិក្នុងឃុំនេះ ហើយមូលហេតុគឺ ខ្វះការយល់ដឹងពីវិធានការការពារ និងទប់ស្កាត់ការរីករាលនៃមេរោគអេដស៍, ពិការពីកំណើត, ខ្វះជំនាញវិជ្ជាជីវៈសម្រាប់ជនពិការ, ខ្វះការយល់ពីដឹងពីច្បាប់ចរាចរជើងគោក, ចាស់ជរា

កុមារកំព្រាគ្មានទីពឹង, ខ្វះការយល់ដឹងពីចំណាកស្រុកដោយសុវត្ថិភាព និងខ្វះការយល់ដឹងពីការជួញដូរមនុស្ស។

- ប្រជាពលរដ្ឋឈឺច្រើនៈ បញ្ហានេះកើតឡើងគ្រប់ភូមិក្នុងឃុំនេះ ហើយវាកើតឡើងដោយសារ ខ្វះការយល់ដឹងពីសុខភាពអនាម័យ, ខ្វះបង្គន់អនាម័យ, ខ្វះវ៉ាក់សាំងចាក់ការពារជំងឺផ្សេងៗ, និងខ្វះការយល់ដឹងពីការប្រែប្រួលអាកាសធាតុ។
- ទឹកស្អាតប្រើប្រាស់មិនគ្រប់គ្រាន់ៈ គឺបញ្ហានេះកើតមានគ្រប់ភូមិក្នុងឃុំនេះ ដែលមូលហេតុគឺខ្វះជើងចម្រោះទឹកស្អាត, ខ្វះប្រព័ន្ធទឹកស្អាតដែរ និងខ្វះការយល់ដឹងពីសារៈប្រយោជន៍នៃការចុះអត្រានុកូលដ្ឋាន, និងខ្វះសំបុត្របញ្ជាក់កំណើត និងមរណៈភាពដោយពួកគាត់មិនសូវបានចូលរួមកម្មវិធីអប់រំ។
- អសន្តិសុខៈ បញ្ហានេះកើតឡើងគ្រប់ភូមិក្នុងឃុំនេះ ដែលកើតឡើងដោយសារ ខ្វះការយល់ដឹងពីច្បាប់គោលនយោបាយភូមិឃុំមានសុវត្ថិភាព, ខ្វះការរាយការណ៍ជនមុខសញ្ញា, សកម្មភាពក្រុមប្រជាការពារនៅមានកម្រិត។
- ទំនាស់ដីធ្លីៈ បញ្ហានេះកើតឡើងគ្រប់ភូមិក្នុងឃុំនេះ ហើយមូលហេតុគឺ ខ្វះការយល់ដឹងពីច្បាប់ភូមិបាល, និងខ្វះប្លង់កម្មសិទ្ធិដីធ្លី។
- អំពើហឹង្សាក្នុងគ្រួសារៈ បញ្ហានេះកើតមានឡើងគ្រប់ភូមិក្នុងឃុំនេះ ដែលវាបណ្តាលមកពីខ្វះការយល់ដឹងពីច្បាប់សិទ្ធិមនុស្ស, ខ្វះការយល់ដឹងពីច្បាប់ទប់ស្កាត់ប្រឆាំងអំពីហិង្សាក្នុងគ្រួសារ, និងខ្វះការយល់ដឹងពីយេនឌ័រ។
- គ្រូមានបន្ទុកការងារលើសពីលទ្ធភាពៈ បញ្ហានេះកើតមានឡើងនៅសាលាព្រៃវៀរ-ជ្រៃ ដែលបណ្តាលមកពីការខ្វះនូវគ្រូបង្រៀន ដែលជាហេតុធ្វើឲ្យគ្រូនីមួយៗត្រូវធ្វើការបង្រៀនសិស្សចំនួនច្រើនម៉ោង។
- ប្រជាពលរដ្ឋមួយចំនួនមិនបានចុះសំបុត្រអត្រានុកូលដ្ឋានៈ ចំពោះបញ្ហានេះកើតមានឡើងនៅគ្រប់ភូមិ ដោយកត្តាមួយចំនួនដូចជា ខ្វះការយល់ដឹងពីសារៈប្រយោជន៍ និងសារៈសំខាន់នៃការចុះសំបុត្រអត្រានុកូលដ្ឋាន។
- ក្មេងៗមួយចំនួនប្រើប្រាស់គ្រឿងញៀនៈ បញ្ហានេះកើតមឡើងនៅគ្រប់ភូមិ នៅឃុំប្រាសាទមួយនេះ ទើបបានឲ្យបណ្តាមកពីកុមារទាំងនោះខ្វះការយល់ដឹងពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន, ការខ្វះខាត់ការយល់ដឹងពីគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព

ដែលទាក់ទងទៅនឹងការទប់ស្កាត់និងប្រឆាំងគ្រឿងញៀន និងចំណាត់ការរបស់សមត្ថកិច្ចនៅមានសម្រិត។

- កុមារតូចមួយចំនួនមិនបានចាក់ថ្នាំបង្ការជម្ងឺគ្រប់មុខតាមការកំណត់: បញ្ហានេះកើតមានឡើងនៅគ្រប់ភូមិ ដែលបណ្តាលមកពីការខ្វះការយល់ដឹងពីការចាក់ថ្នាំបង្ការ, មិនបានតាមដានការបរិច្ឆេទដែលពេទ្យបានកំណត់ក្នុងប័ណ្ណ និងការខ្វះខាត់នូវថវិការ ពេលវេលាសម្រាប់ជូនកូនទៅទទួលថ្នាំបង្ការ។
- ស្ត្រីជាថ្នាក់ដឹកនាំនៅមានចំនួន: បញ្ហានេះកើតមានឡើងនៅគ្រប់ភូមិ ដោយស្ត្រីមួយចំនួនមានចំណេះដឹងទាបនៅឡើយ, និងខ្វះភាពជាអ្នកដឹកនាំ ដែលជាហេតុធ្វើឲ្យស្ត្រីនៅមានភាពទន់ខ្សោយក្នុងគ្រួសារនិងសង្គម។

**២.៧.២. ដំណោះស្រាយនូវបញ្ហាដែលកើតមានឡើង**

ដើម្បីដោះស្រាយនូវរាល់បញ្ហាដែលកើតមានឡើងនៅក្នុងឃុំប្រាសាទ ក្រុមប្រឹក្សាឃុំបានស្វែងរកដំណោះស្រាយជាច្រើនដើម្បីផ្តល់នូវភាពងាយស្រួលដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំដូចជា:

- ចំពោះបញ្ហាផ្លូវពិបាកធ្វើដំណើរ: ក្រុមប្រឹក្សាឃុំមានយុទ្ធសាស្ត្រមួយចំនួនដូចជា ជួសជុលផ្លូវលំដីស សាងសង់លូកាត់ផ្លូវ ជួសជុលផ្លូវក្រាលខ្សាច និងថែទាំផ្លូវខ្សាច់ភ្នំដើម្បីជួយសម្រួលដល់ការធ្វើដំណើរសម្រាប់ប្រជាជន។
- ចំពោះបញ្ហាទិន្នផលស្រូវទាប: ក្រុមប្រឹក្សាឃុំបានផ្តល់នូវពូជស្រូវទិន្នផលខ្ពស់ដល់ប្រជាជនសម្រាប់ធ្វើពូជ បណ្តុះបណ្តាលបច្ចេកទេសដាំដុះដំណាំស្រូវ ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការប្រើប្រាស់ជីធម្មជាតិ និងធ្វើការបណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត។
- បញ្ហាទឹកស្រោចស្រពដឹកសិកម្មមិនគ្រប់គ្រាន់: ពួកគេបានធ្វើការជីកប្រឡាយទឹក សាងសង់ទរបណ្តែត និងផ្តល់ម៉ាស៊ីនបូមទឹកសម្រាប់ឲ្យប្រជាជនធ្វើការបូមទឹកដាក់ស្រែឬដំណាំរបស់ពួកគេ។
- បញ្ហាសត្វឈឺច្រើន: ចំពោះបញ្ហានេះក្រុមប្រឹក្សាឃុំសង្កាត់ បានរៀបចំយុទ្ធសាស្ត្រជាច្រើនដូចជា ផ្តល់វ៉ាក់សាំងចាក់ការពារជម្ងឺសត្វ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ និងបណ្តុះបណ្តាលបច្ចេកទេសផលិតចំណីសត្វ។

- បញ្ហាប្រាក់ចំណូលទាបៈ ដើម្បីដោះស្រាយបញ្ហានេះក្រុមប្រឹក្សារៀបចំនូវពូជសត្វមួយចំនួនដើម្បីផ្តល់ជូនប្រជាពលរដ្ឋសម្រាប់ប្រកបរបរចិញ្ចឹមសត្វ បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនិងដាំដំណាំ ជីកស្រះជាលក្ខណៈគ្រួសារជូនប្រជាជន និងផ្តល់ជាទុននិងកម្ចីឥណទានដែលមានការប្រាក់ទាបអាចជូនប្រជាពលរដ្ឋ សម្រាប់ប្រកបរបរចិញ្ចឹមជីវិតគ្រួសារ។
- បញ្ហាចំណាកស្រុកច្រើនៈ ចំពោះបញ្ហានេះ ពួកគេបានបើកវគ្គបណ្តុះបណ្តាលមួយចំនួនជំនាញសំអាងការ ជំនាញកាត់ដេរ ជំនាញជួសជុលម៉ាស៊ីនគ្រប់ធុន ជំនាញជួលជុលគ្រឿងអេឡិចត្រូនិច និងបង្កើតរោងចក្រកាត់ដេរដើម្បីឲ្យប្រជាជនអាចមានមុខរបរផ្ទាល់ខ្លួននិងជៀសវាងការធ្វើចំណាក។
- បញ្ហាកុមារមួយចំនួនមិនបានចូលរៀនៈ ឃុំប្រាសាទបានរៀបចំនូវផែនការមួយចំនួនដូចជាផ្សព្វផ្សាយដល់ឪពុកម្តាយឲ្យយល់ដឹងអំពីអត្ថប្រយោជន៍នៃការសិក្សា បើកថ្នាក់បំប៉ន់បន្ថែម និងជួយឧបត្ថម្ភជាសម្ភារៈសិក្សានិងបណ្តុះបណ្តាលគ្រូបន្ថែម។
- បញ្ហាក្រុមជនងាយរងគ្រោះៈ ដើម្បីដោះស្រាយនូវបញ្ហានេះគេគួរធ្វើការផ្សព្វផ្សាយអំពីវិធានការការពារការរីករាលដាលនៃមេរោគអេដស៍និងជម្ងឺឆ្លងនានា ផ្តល់នូវឈើច្រត់ រទេះរុញ និងជើងសិប្បនិម្មិត និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ជនពិការ។
- បញ្ហាប្រជាពលរដ្ឋឈឺច្រើនៈ បញ្ហានេះកើតឡើងដោយការខ្វះការយល់ដឹងពីសុខភាពអនាម័យ ហេតុនេះហើយក្រុមប្រឹក្សាឃុំ បានធ្វើការផ្សព្វផ្សាយពីសុខភាពអនាម័យ សាងសង់បង្គន់អនាម័យ និងផ្សព្វផ្សាយពីការការពារនៃបំរែបំរួលអាកាសធាតុ។
- បញ្ហាអំពើហិង្សាក្នុងគ្រួសារៈ គឺធ្វើការផ្សព្វផ្សាយអំពីច្បាប់សិទ្ធិមនុស្ស ផ្សព្វផ្សាយអំពីច្បាប់ទប់ស្កាត់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ និងបណ្តុះបណ្តាលពីយេនឌ័រ។
- បញ្ហាកុមារមួយចំនួនមិនបានចាក់ថ្នាំបង្ការៈ គឺក្នុងឃុំប្រសាទគេឃើញមានការផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការចាក់ថ្នាំបង្ការ និងជំរុញនិងលើកទឹកចិត្តដល់ឪពុកម្តាយក្នុងការនាំកូនមកទទួលថ្នាំបង្ការ។
- ចំពោះបញ្ហាស្ត្រីជាអ្នកដឹកនាំមានតិចៈ ក្រុមប្រឹក្សាឃុំបានរៀបចំវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ប្រជាជនជាស្ត្រី និងជួយជំរុញដល់ការបញ្ចេញមតិយោបល់របស់ស្ត្រី។[30]

[30] ដកស្រងពីឯកសារដើម កម្មវិធីវិនិយោគបីឆ្នាំរំកិល ឆ្នាំ២០១៩-២០២១ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

## សេចក្ដីសន្និដ្ឋាន

ក្រោយពីបានចុះទៅធ្វើការសិក្សាស្រាវជ្រាវរួចមក យើងខ្ញុំបានយល់ដឹងនូវទិន្នភាពទូទៅនៃស្ថានភាពសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធជាក់ស្ដែងរបស់ឃុំយ៉ាងច្បាស់តាមរយៈការសាកសួរដោយផ្ទាល់ពីមេឃុំ និងឯកសារមួយចំនួនដែលបានតម្កល់ទុកនៅមន្ទីរឃុំដែលបានធ្វើការរៀបរាប់ពីស្ថានភាពទូទៅ។ ម្យ៉ាងវិញទៀត ក្រៅពីស្ថានភាពទូទៅរបស់ឃុំ យើងក៏បានសង្កេតឃើញថាប្រជាជន ៧៥%ដែលប្រកបរបរធ្វើស្រែ ២៤%ទៀតធ្វើការប្រកបរបរផ្នែកសេវាកម្ម និង១%ធ្វើការប្រកបរបរផ្នែកសិប្បកម្ម។ ក្រៅពីនេះទៅទៀត យើងសង្កេតឃើញថា ឃុំប្រាសាទគឺជាឃុំមួយដែលមានការរីចម្រើនយ៉ាងខ្លាំងលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ វិស័យសុខាភិបាល និងប្រព័ន្ធអប់រំជាដើម ក្រោមការយកចិត្តទុកដាក់យ៉ាងខ្លាំងខ្លាពីសំណាក់ក្រុមប្រឹក្សាឃុំក្នុងការរៀបចំចុក្ខវិស័យ គោលបំណងនិងគោលដៅ និងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍឃុំ និងផ្ដល់នូវភាពងាយស្រួលដល់ប្រជាពលរដ្ឋ។

# ជំពូកទី ៣

# ការវិភាគលើលទ្ធផលនៃ
# ការអភិវឌ្ឍហេដ្ឋារចនា
# សម្ព័ន្ធរូបវន្តឃុំប្រាសាទ

# ជំពូកទី ៣

# ការវិភាគលើលទ្ធផលនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តឃុំប្រាសាទ

## ៣.១. សមិទ្ធិផលដែលឃុំប្រាសាទសម្រេចបាន

ក្នុងរយះពេល៥ឆ្នាំចុងក្រោយនេះ ក្រុមប្រឹក្សាឃុំប្រាសាទ បានសម្រេចនូវលទ្ធផលការងារជាច្រើនក្នុងការអភិវឌ្ឍជនបទ ដែលប្រកបដោយប្រសិទ្ធភាពខ្ពស់ ដែលផ្តល់ជាអត្ថប្រយោជន៍យ៉ាងច្រើនដល់ប្រជាជនក្នុងតំបន់ ភាពរីកចម្រើននេះកើតឡើងក៏ដោយសារមានការចូលរួមយ៉ាងខ្លាំងពីប្រជាជន មន្ទីរអភិវឌ្ឍជនបទខេត្តព្រៃវែង ដៃគូជាម្ចាស់ជំនួយ សប្បុរសជន និងជាពិសេសអង្គការវ៉ូមែន ( GFCRS ) ដែលជាដៃគូរជំនួយដ៏សំខាន់មួយចំនួនសម្រាប់អភិវឌ្ឍជនបទនៅឃុំប្រាសាទទាំងមូល។

### ៣.១.១. ផ្នែកគមនាគមន៍

### ក. ចន្លោះឆ្នាំ ២០១៥ ដល់ ២០១៧

ក្នុងឆ្នាំ ២០១៥ ដល់ ឆ្នាំ២០១៧ គេសម្រេចបាននូវការសាងសង់ផ្លូវមួយចំនួនដែលមានប្រវែងសរុប ប្រហែលចំនួន ៣១,២៩៥ ម៉ែត្រ។ ដោយក្នុងនោះមានផ្លូវចំនួន៣ប្រភេទគឺ:

**តារាង ១.១ ប្រវែងផ្លូវនៅក្នុងឃុំប្រាសាទ**

| បរិយាយ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|
| សរុបផ្ទៃដីឃុំសង្កាត់ (ម៉ែត្រ) | ២,៩០៨ | ២,៩០៨ | ២,៩០៨ |
| សរុបប្រវែងផ្លូវ(ម៉ែត្រ) | ៣១,២៩៥ | ៣១,២៩៥ | ៣១,២៩៥ |
| ប្រវែងផ្លូវតាមបណ្តាឃុំសង្កាត់(ម៉ែត្រ) | ១៩,២៩៥ | ១៩,២៩៥ | ១៩,២៩៥ |
| ប្រវែងផ្លូវស្រុកឆ្លងកាត់តាមបណ្តាឃុំសង្កាត់ (ម៉ែត្រ) | ៤០០០ | ៤០០០ | ៤០០០ |
| ប្រវែងផ្លូវជាតិឆ្លងកាត់តាមបណ្តាឃុំសង្កាត់(ម៉ែត្រ) | ៨០០០ | ៨០០០ | ៨០០០ |

- ផ្លូវតាមបណ្តាឃុំ សង្កាត់ ដែលមានប្រវែងសរុប ១៩,២៩៥ ម៉ែត្រ
- ផ្លូវខេត្តស្រុកឆ្លងកាត់តាមបណ្តាឃុំ សង្កាត់ ដែលមានប្រវែងសរុប ៤,០០០ ម៉ែត្រ
- ផ្លូវជាតិ ឆ្លងកាត់តាមបណ្តាឃុំ សង្កាត់ ដែលមានប្រវែងសរុប ៨,០០០ ម៉ែត្រ។

ម្យ៉ាងវិញទៀតនៅក្នុងឆ្នាំ២០១៥ គឺឃុំប្រាសាទបានសម្រេចនូវគម្រោងជួសជុលផ្លូវក្រាលខ្សាច់ភ្នំ បានចំនួន ២ភូមិ គឺភូមិបី និងភូមិភ្លង ដែលមានប្រវែង ២.១៤០ម៉ែត្រ ដែលក្នុងនោះដែលត្រូវ

ចំណាយថវិកាអស់ ៨១,៦៨៣,៨០០រៀល ហើយបានផ្ដល់ផលដល់ប្រជាជនសរុប ២,០០៤ ក្នុងនោះស្រីចំនួន ១,០៣៥នាក់ និងប្រភពគ្រាំទ្របានមកពីមូលនិធីឃុំ២០១៥។

**ខ. ឆ្នាំ ២០១៨**

ដោយនៅក្នុងឆ្នាំ ២០១៨ លទ្ធផលនៃការអនុវត្តគម្រោងរបស់ឃុំប្រាសាទដែលទាក់ទងទៅនិងផ្នែកគមនាគមន៍គេឃើញមានចំនួនពីរធំៗដូចខាងក្រោមៈ

ទី១ គឺការជួសជុលផ្លូវលំដីស ដែលស្ថិតនៅក្នុងភូមិអំពិល ដែលមានប្រវែងចំនួន ២.៦ គីឡូម៉ែត្រ ដែលចំណាយពេលអស់ប្រហែលចំនួន ៣ខែ ដែលក្នុងនោះគេធ្វើការចំណាយប្រាក់សរុបអស់ប្រហែលចំនួន ៩៦,២០០,០០០៛ មានប្រភពថវិកាគឺជាមូលនិធីឃុំ ហើយបានផ្ដល់ផលប្រយោជន៍ដល់ប្រជាជនទាំងអស់សរុបចំនួន ៩១៦នាក់ ក្នុងនោះមានស្រីទាំងអស់ចំនួនប្រហែល ៤៨១នាក់។

ទី២ គឺមានការថែទាំផ្លូវជាប្រចាំ ដែលមានទីតាំងស្ថិតនៅភូមិ គ្រោកដូង ដែលមានប្រវែង ៥៩០០ម៉ែត្រ ក្នុងរយៈពេល១២ខែ ចំណាយថវិការអស់ ១២,០០០,០០០៛ ដែលជាមូលនិធីរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង។

**គ. ឆ្នាំ ២០១៩**

ដោយនៅក្នុងឆ្នាំ ២០១៩ លទ្ធផលនៃការអនុវត្តគម្រោងរបស់ឃុំប្រាសាទដែលទាក់ទងទៅនិងផ្នែកគមនាគមន៍គេឃើញមានចំនួនពីរធំៗដូចខាងក្រោមៈ

ទី១ គឺការជួសជុលផ្លូវលំក្រាលខ្សាច់ក្រហម ដែលស្ថិតនៅក្នុងភូមិអំពិល ដែលមានប្រវែងចំនួន ២.៦២ គីឡូម៉ែត្រ ដែលក្នុងនោះគេធ្វើការចំណាយប្រាក់សរុបអស់ប្រហែល ១២៥,៧២២,៧០៩៛ មានប្រភពថវិកាគឺជាមូលនិធីឃុំ១២៥,៧២២,៧០៩៛ និងទុនចូលរួមចំនួន ៣៥០,០០០៛ ហើយបានផ្ដល់ផលប្រយោជន៍ដល់ប្រជាជនសរុបចំនួន ៤,១៧៥នាក់ ក្នុងនោះមានស្រីចំនួន ២,៩៦៩នាក់។

ទី២ គឺមានការថែទាំផ្លូវជាប្រចាំ ដែលមានទីតាំងស្ថិតនៅភូមិ គ្រោកដូង ដែលមានប្រវែង ៥៩០០ម៉ែត្រ ក្នុងរយៈពេល១២ខែ ចំណាយថវិការអស់ ១២,០០០,០០០៛ ដែលជាមូលនិធីរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង។

**៣.១.២. ផ្នែកធារាសាស្ត្រ**

ចំពោះប្រព័ន្ធធារាសាស្ត្រ គេទទួលបានសមិទ្ធិផលមួយចំនួនដូចជាៈ

- ស្ពានប្រឡាយ អកអំបុក ដែលមានប្រវែង ៨០០០ម៉ែត្រ
- ដាក់លូរំដោះទឹកភ្លៀងតាមបណ្ដោយផ្លូវជាតិ ដែលមានប្រវែង ១,៨០០ម៉ែត្រ

- ធ្វើលូរំដោះទឹកស្អុយ ដែលមានប្រវែង ១,២០០ម៉ែត្រ។
- ការដាក់លូ ដែលមានទីតាំងស្ថិតនៅភូមិអំពិល មានចំនួន៣កន្លែង ក្នុងនោះផងដែលគេធ្វើការចំណាយរយៈពេលអស់ប្រហែល ១ខែ ហើយចំណាយថវិការអស់ ១៣,៥០០,០០០៛ ដែលជាមូលនិធិរបស់ឃុំ។
- សាងសង់លូកាត់ផ្លូវ ដែលស្ថិតនៅក្នុងភូមិដងទុង ចំនួន ១កន្លែង ដែលក្នុងនោះគេនិងធ្វើការចំណាយប្រាក់សរុបអស់ចំនួនប្រហែល ៤,៨០០,០០០៛ មានប្រភពថវិកាគឺជាមូលនិធីឃុំ៤,៨០០,០០០៛ និងទុនចូលរួមចំនួន ០៛ ហើយបានផ្តល់ផលប្រយោជន៍ដល់ប្រជាជនសរុបចំនួន ៤,១៧៥នាក់ ក្នុងនោះមានស្រីចំនួន ២,៩៦៩នាក់។

### ៣.១.៣. ផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត

**ក. សាលារៀន**

សាលារៀន គឺជាកន្លែងបណ្តុះបណ្តាលនូវធនធានមនុស្សដោយផ្តល់នូវចំណេះដឹងផ្សេងៗ លុបបំបាត់នូវអនក្ខរកម្មតាមរយៈ ការអប់រំទូន្មាន និងបណ្តុះនូវមនសិការជាតិមាតុភូមិដល់ពួកគេ ព្រោះពួកគេនិងក្លាយជាសសរទ្រូងសម្រាប់ប្រទេសជាតិទៅថ្ងៃខាងមុខ។ ការសាងសង់ សាលារៀន និងបំពាក់ តុ កៅអី ក្តាខៀនដល់សាលារៀន មានសារៈសំខាន់ណាស់ ជាពិសេសនៅតាមទីជនបទមានការខ្វះខាត់សាលារៀន សម្រាប់កុមាររៀន ទើបរាជរដ្ឋាភិបាលបានកែប្រែនូវប្រព័ន្ធអប់រំយ៉ាងតឹងរឹង ។ ក្រៅពីនេះផងដែរ នៅឃុំប្រាសាទគេសង្កេតឃើញថា មានការកើនឡើងនូវសាលារៀនជាច្រើនដែលទទួលបានការគ្រាំទ្រពីរដ្ឋាភិបាលដែលក្នុងនោះមានដូចជា៖

**តារាង ១.២ បង្ហាញពីចំនួននៃបន្ទប់សាលាដែលបានសាងសង់បន្ថែម**

| បរិយាយ | បរិមាណកន្លែង | ចំនួនបន្ទប់ |
|---|---|---|
| មត្តេយ្យសហគមន៍ | ១ | ៣ |
| សាលាមត្តេយ្យរដ្ឋ | ៣ | ៧ |
| សាលាមត្តេយ្យឯកជន | ១ | ៥ |
| សាលាបឋមសិក្សា | ៤ | ៥២ |
| អនុវិទ្យាល័យរដ្ឋ | ១ | ១១ |
| វិទ្យាល័យរដ្ឋ | ១ | ២២ |

**ក្រាហ្វិក ១.១ បង្ហាញពីចំនួននៃបន្ទប់សាលាដែលបានសាងសង់បន្ថែម**




- មត្តេយ្យសហគមន៍ ដែលមានចំនួន៣បន្ទប់
- សាលាមត្តេយ្យរដ្ឋ ដែលមានចំនួន ៣កន្លែង ក្នុងនោះមានបន្ទប់ចំនួន ៧បន្ទប់
- សាលាមត្តេយ្យឯកជន ចំនួន ១កន្លែង ដែលក្នុងនោះមានបន្ទប់ចំនួន ៥បន្ទប់
- សាលាបឋមសិក្សា ដែលមានចំនួន ៤កន្លែង ក្នុងនោះមានបន្ទប់ចំនួន ៥២បន្ទប់
- អនុវិទ្យាល័យរដ្ឋ ដែលមានចំនួន ១កន្លែង ដែលមានបន្ទប់ចំនួន ១១បន្ទប់
- និងវិទ្យាល័យរដ្ឋ ចំនួន ១កន្លែង ដែលក្នុងនោះមានបន្ទប់ចំនួន ២២បន្ទប់។

**ខ. សុខាភិបាល**

ដើម្បីថែទាំ និងគាំពារសុខភាពរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំប្រាសាទ ឲ្យទទួលបាននូវសុខភាពល្អ, កាត់បន្ថយនូវការចំណាយថវិកាទៅលើការព្យាបាលជម្ងឺ, កាត់បន្ថយការស្លាប់ដោយជម្ងឺអេដស៍, កាត់បន្ថយការស្លាប់របស់ស្ត្រី និងទារកក្រោយពេលសំរាលកូនរួច ក្រុមប្រឹក្សាឃុំបានរៀបចំនូវផែនការមួយចំនួន ដែលក្នុងនោះរួមមាន កម្មវិធីការផ្តល់ការថែទាំ គាំទ្រអ្នកផ្ទុកមេរោគអេដស៍ និងកុមាររងគ្រោះដោយសារជម្ងឺអេដស៍ ដែលស្ថិតនៅគ្រប់ភូមិ ក្នុងរយះពេល១២ខែ ដែលចំណាយថវិកាអសប្រហែលចំនួន ៥,៥៦០,០០០៛ ដែលជាជំនួយរបស់អង្គការវ៉ូមែន។ ក្រៅពីនេះ គេក៏ឃើញមានការចុះផ្សព្វផ្សាយទាក់ទងនិងសុខភាព អនាម័យ និងរបៀបទប់ស្កាត់ការឆ្លងជម្ងឺផ្សេងៗ។

**គ. អនាម័យបរិស្ថាន និងការផ្គត់ផ្គង់ទឹក**

ការប្រើប្រាស់បង្គន់អនាម័យ នៅក្នុងឃុំប្រាសាទក្នុងឆ្នាំ ២០១៧ ដែលគេទទួលបានសមិទ្ធិផលមួយចំនួនដូចជា៖

**តារាង ១.៣ ចំនួនគ្រួសារដែលប្រើប្រាស់បង្គន់អនាម័យ**

| បរិយាយ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|
| ចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | ២,៣៦២ | ២,២៦៤ | ២,៤២៩ |
| ចំនួនគ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេស | ២,១៥៦ | ២,០៨០ | ២,៣៥២ |
| ចំនួនគ្រួសារមានប្រភពទឹកជិតជាង១៥០ម៉ែត្រពីផ្ទះ | ២,៦២១ | ២,៧៩៦ | ២,២២១ |
| %មានបង្គន់អនាម័យប្រើប្រាស់ | ៨៥.១% | ៨១.០% | ៨៦.១% |
| %ប្រើប្រាស់បង្គន់មានបច្ចេកទេស | ៧៧.៧% | ៧៤.៤% | ៨៣.៤% |
| %មានប្រភពទឹកជិតជាង១៥០ម៉ែត្រពីផ្ទះ | ៩៤.៥% | ១០០.០% | ៧៨.៨% |

**ក្រាហ្វិក ១.២ ចំនួនគ្រួសារដែលប្រើប្រាស់បង្គន់អនាម័យ**



- ចំនួនគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ នៅឆ្នាំ២០១៥ គឺមានចំនួន ២,៣៦២ គ្រួសារ ដែលត្រូវនិង៨៥,១% ហើយក៏មានការធ្លាក់ចុះមកវិញនៅឆ្នាំ២០១៦ ដែលមានចំនួនប្រហែល ២,២៦៤ គ្រួសារដែលត្រូវនិង ៨១,០% ប៉ុន្តែមានការកើនឡើងវិញរហូតដល់ ២,៤២៩គ្រួសារក្នុងឆ្នាំ២០១៧ ហើយត្រូវនិង ៨៦,១%។
- ចំនួនគ្រួសារដែលប្រើប្រាស់បង្គន់មានបច្ចេកទេស នៅឆ្នាំ២០១៥ គឺមានចំនួន ២,១៥៦ ដែលត្រូវនិង៧៧,៧% ហើយមានការធ្លាក់ចុះវិញនៅឆ្នាំ២០១៦ ដែលមានចំនួនប្រហែល ២,០៨០ ដែលត្រូវនិង៧៤,៤% ប៉ុន្តែមានការកើនឡើងរហូតដល់ ២,៣៥២ គ្រួសារក្នុងឆ្នាំ ២០១៧ ហើយត្រូវនិង ៨៣,៤%។
- ចំណែកគ្រួសារដែលមានប្រភពទឹកជិតជាង១៥០ម៉ែត្រពីផ្ទះ នៅឆ្នាំ២០១៥ គឺមានចំនួន ២,៦២១ គ្រួសារ ដែលត្រូវនិង៩៤,៥% ហើយក៏មានការកើនឡើងវិញនៅឆ្នាំ២០១៦ ដែលក្នុងនោះមានចំនួនប្រហែល ២,៧៩៦ ដែលត្រូវនិង១០០.០% ប៉ុន្តែមានការកើនឡើងរហូតដល់ ២,២២១ គ្រួសារក្នុងឆ្នាំ២០១៧ ហើយត្រូវនិង ៧៨,៨% ។

## ក្រាហ្វិក ១.៣ ភាគរយគ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេស



**តារាង១.៤ ការប្រើប្រាស់ទឹក**

| បរិយាយ | | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|
| គ្រួសារសរុបដែលមានការប្រើប្រាស់ទឹកស្អាត | | ២,៧៧៤ | ២,៧៨៦ | ២,៨២០ |
| ក្នុងនោះ | ទឹកដែលឆ្លងកាត់ប្រព័ន្ធធ្វើទឹកឲ្យស្អាត | ១៥០ | ២៨០ | ៦៥០ |
| | ទឹកអណ្តូងស្នប់ឬអណ្តូងចំរុះ | ២,៦៩៥ | ២,៥០៦ | ២,១៧០ |
| %គ្រួសារមានទឹកស្អាតប្រើប្រាសើ | | ១០០.០ | ១០០.០ | ១០០.០ |

**ក្រាហ្វិក១.៤ ការប្រើប្រាស់ទឹក**




ចំពោះការប្រើប្រាស់ទឹកស្អាតនៅក្នុងឃុំប្រាសាទនៅក្នុងឆ្នាំ ២០១៥ដល់២០១៧ ក៏មានការកើនឡើងពីចំនួន២,៧៧៤គ្រួសារ នៅឆ្នាំ២០១៥ ហើយមានចំនួន២,៧៨៦ នៅឆ្នាំ២០១៦ និងកើនដល់២,៨២០គ្រួសារ នៅឆ្នាំ២០១៧នៃចំនួនគ្រួសារសរុប។ដោយក្នុងនោះគ្រួសារដែលមានការប្រើប្រាស់ទឹកឆ្លងកាត់ប្រព័ន្ធ ធ្វើឲ្យទឹកស្អាតមានការកើនឡើងពី១៥០គ្រួសារនៅឆ្នាំ ២០១៥, ២៨០

គ្រួសារឆ្នាំ២០១៦ និង៦៥០គ្រួសារនៅឆ្នាំ ២០១៧។ បន្ទាប់ពីនេះ គ្រួសារដែលប្រើប្រាស់ទឹកអណ្តូងមានការថយចុះពីចំនួន ២,៦៩៥គ្រួសារនៅឆ្នាំ ២០១៥ និងមានចំនួន២៥០៦ នៅឆ្នាំ២០១៦ ហើយមានការថយចុះរហូតដល់ ២,១៧០គ្រួសារឆ្នាំ ២០១៧ ដោយមានការកែប្រែនៃការប្រើប្រាស់ទឹកពីការប្រើទឹកអណ្តូងទៅប្រើប្រាស់នូវទឹកដែលមានការឆ្លងកាត់ប្រព័ន្ធធ្វើឲ្យទឹកស្អាតវិញ។

សរុបមកសមិទ្ធិផលដែលទទួលបានមកពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនេះ បានលើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំប្រាសាទ ក៏ដូចជាប្រជាជនដែលធ្វើដំណើរឆ្លងកាត់ផ្លូវទាំងនោះយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព។ បន្ទាប់ពីការសាងសង់រួច ការប្រែប្រួលជាវិជ្ជមាននៃជីវភាពរបស់ប្រជាជនបានប្រសើរឡើងដោយអង្កេតឃើញថា កម្រិតនៃបញ្ហាសុខភាពបានថយចុះ អត្រាចុះឈ្មោះចូលរៀនមានកម្រិតខ្ពស់ សកម្មភាពធ្វើដំណើរ និងដឹកជញ្ជូនមានការកើនឡើង ទំនាក់ទំនងទីផ្សារបានលឿន ការប្រកបរបរកសិកម្មកើនឡើង ដោយសារប្រជាពលរដ្ឋមិនបានធ្វើការពឹងផ្អែកលើទឹកភ្លៀងទៀត ហើយសកម្មភាពលក់ដូរនៅទីផ្សារមួយចំនួនក៏មានការកើនឡើនដែរ។

## ៣.២. គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តមិនទាន់សម្រេច និងគ្មានថវិកាគាំទ្រ

សរុបមកនៅក្នុងឃុំប្រាសាទគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តមិនទាន់សម្រេច និងគ្មានថវិកាគាំទ្រ គឺមានចំនួន ៦គម្រោងទៀតនៅក្នុងឆ្នាំ ២០១៩

**តារាង ១.៥ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តមិនទាន់សម្រេច និងគ្មានថវិកាគាំទ្រ**

| បរិយាយ | | ជួសជុលផ្លូវលំដីស | ស្តារប្រឡាយស្រោចស្រព | កសាងទរបណ្តែត |
|---|---|---|---|---|
| ទីតាំង | | ភូមិ១ដល់៥,៧,៩ | ភូមិ ១,៣,៤,៥,៦,៧,៩ | ភូមិ ១,៥ |
| លទ្ធផល | បរិមាណ | ៨.៨ | ១០ | ២ |
| | ឯកតា | គ.ម | គ.ម | គ.ម |
| រយៈពេល | | ២ ខែ | ២ ខែ | ១ ខែ |
| អ្នកទទួលផល | សរុប | ១០,០២៨ | ១៣,៣២៧ | ៤,១៩១ |
| | ស្រី | ៥,៩៧៧ | ៦,៩០៤ | ២,១៧៥ |
| តម្លៃប៉ាន់ស្មាន (រៀល) | | ១៥១,៩៦០,០០០ | ២៥២,៩០០,០០០ | ៣០,០០០,០០០ |

**តារាង ១.៦ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តមិនទាន់សម្រេច និងគ្មានថវិកាគាំទ្រ**

| បរិយាយ | | ជីកស្រះចិញ្ចឹមត្រី | ផ្តល់ថ្នាក់មត្តេយ្យសហគមន៍ | កែលម្អសោសាងសង់ប្រព័ន្ធទឹកស្អាត |
|---|---|---|---|---|
| ទីតាំង | | គ្រប់ភូមិ | ឃុំ | ប្រាសាទ |
| លទ្ធផល | បរិមាណ | ១៨ | ៦ | ១ |
| | ឯកតា | ស្រះ | ថ្នាក់ | កន្លែង |
| រយៈពេល | | ៣ ខែ | ១ ខែ | ១ ឆ្នាំ |
| អ្នកទទួលផល | សរុប | ៣,៥០០ | ១៥០ | ២,៩៦៥ |
| | ស្រី | ១,៨៧៥ | ៩៤ | ១,៥៨៥ |
| តម្លៃប៉ាន់ស្មាន (រៀល) | | ៣៦,០០០,០០០ | ២៤,០០០,០០០ | ៤,០០០,០០០ |

- គម្រោងទី១ គឺការជួសជុលផ្លូវលំដីស ក្នុងនោះមានប្រវែងចំនួន ៨.៨ គីឡូម៉ែត្រ ចំណាយអស់ប្រហែល ១៥១,៩៦០,០០០៛ ដែលស្ថិតនៅ ភូមិចំនួន៧ គឺភូមិប្រាសាទ ភូមិចំបក់ ភូមិអំពិល ភូមិពាន់វត្ត ភូមិជ្រលង ភូមិបី និងភូមិច្វូរ ដែលប្រើរយៈពេលប្រហែល២ខែ ជាពិសេសបានផ្តល់ផលដល់ចំនួនប្រជាជនសរុប ១០,០២៨នាក់ ក្នុងនោះមានស្រីចំនួន ៥,៩៧៧នាក់។
- គម្រោងទី២ គឺការស្តារប្រឡាស្រោចស្រប ក្នុងនោះមានប្រវែង ១០ គីឡូម៉ែត្រ ចំណាយអស់ប្រហែល ២៥២,៩០០,០០០៛ ដែលស្ថិតនៅ ភូមិចំនួន៧ គឺភូមិប្រាសាទ ភូមិអំពិល ភូមិពាន់វត្ត ភូមិជ្រលង ភូមិដងទុង ភូមិបី និងភូមិច្វូរ ដែលប្រើរយៈពេលប្រហែល២ខែ ជាពិសេសបានផ្តល់ផលដល់ចំនួនប្រជាជនសរុប ១៣,៣២៧នាក់ ក្នុងនោះមានស្រីចំនួន ៦,៩៧៧នាក់។
- គម្រោងទី៣ គឺសាងសង់ទរបណ្តោត ក្នុងនោះមានប្រវែង ២ គីឡូម៉ែត្រ ចំណាយអស់ប្រហែល ៣០,០០០,០០០៛ ដែលស្ថិតនៅ ភូមិចំនួន៤ គឺភូមិប្រាសាទ ភូមិចំបក់ និងភូមិជ្រលង ដែលប្រើរយៈពេលទាំងអស់ប្រហែលជា ១ខែ ជាពិសេសបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់ចំនួនប្រជាជនទាំងអស់សរុបចំនួន ៤,១៩១នាក់ ក្នុងនោះមានស្រីចំនួន ២,១៧៥នាក់។

- គម្រោងទី៤ គឺការជីកស្រះចិញ្ចឹមត្រីក្នុងនោះមានសរុបចំនួន ១៨ស្រះ ចំណាយអស់ប្រហែល ៣៦,០០០,០០០៛ ដែលស្ថិតនៅ ភូមិចំនួន៩ គឺភូមិប្រាសាទ ភូមិចំបក់ ភូមិអំពិល ភូមិពាន់វត្ត ភូមិជ្រលង ភូមិដងទុង ភូមិបី ភូមិភ្លូង និងភូមិច្បូវ ដែលប្រើរយៈពេលប្រហែល៣ខែ ជាពិសេសបានផ្តល់ផលដល់ចំនួនប្រជាជនសរុប ៣,៥០០នាក់ ក្នុងនោះមានស្រីចំនួន ១,៨៧៥នាក់។
- គម្រោងទី៥ គឺផ្តល់ថ្នាក់មត្តេយ្យសហគមន៍ ក្នុងនោះមានចំនួន៦ថ្នាក់ ចំណាយអស់ប្រហែល ២៥,០០០,០០០៛ ដែលស្ថិតនៅ ក្នុងឃុំប្រាសាទផ្ទាល់ ដែលនិងប្រើរយៈពេលប្រហែល១ខែ ជាពិសេសបានផ្តល់ផលដល់ចំនួនប្រជាជនសរុប ១៥០នាក់ ក្នុងនោះមានស្រីចំនួន ៩៤នាក់។
- គម្រោងទី៦ គឺការរៀបចំកែលំអសាងសង់ប្រព័ន្ធទឹកស្អាត ក្នុងនោះមានចំនួន ១ កន្លែង ដែលនិងចំណាយអស់ប្រហែល ៥,០០០,០០០៛ ដែលស្ថិតនៅ ភូមិប្រាសាទ ហើយប្រហែលជាត្រូវចំណាយពេលកែប្រែ ១ឆ្នាំ ម្យ៉ាងវិញទៀតបានផ្តល់ផលប្រយោជន៍ដល់ប្រជាជនសរុប២,៩៨៥ ក្នុងនោះមានស្រីចំនួន ១,៥៨៥នាក់។

## ៣.៣. បញ្ហាប្រឈមលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងឃុំប្រាសាទ

ចំពោះបញ្ហាប្រឈមនៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តមានកត្តាមួយចំនួនដូចជា:

- ទឹកស្រោចស្រពដីកសិកម្មមិនគ្រប់គ្រាន់: បញ្ហានេះកើតមានឡើងគ្រប់ភូមិក្នុងឃុំប្រាសាទ មូលហេតុដែលបណ្តាមកពី ខ្វះប្រឡាយ, ខ្វះទរបណ្តោត, និងខ្វះម៉ាស៊ីនបូមទឹក។
- ភាពខ្វះខាត់ថវិការគាំទ្រ: ក្នុងការសាងសង់សំណង់នីមួយៗគឺត្រូវការជាចាំបាច់នូវថវិការក្នុងការប្រើប្រាស់ដូចជា ការទិញសម្ភារៈ ការទិញវត្ថុធាតុដើម ការចំណាយទៅលើកម្មករ ( ការចំណាយទៅលើការហូបចុក ការស្នាក់នៅ ការឈឺស្កាត់ និងប្រាក់ចំណូលរបស់កម្មករ) ។ ការចំណាយទាំងនេះ គឺសុទ្ធសឹងត្រូវការប្រាក់ ហេតុនេះហើយវាគឺជាកត្តាមួយដល់សំខាន់ក្នុងការអភិវឌ្ឍន៍ជនបទផងដែរ។
- រថយន្តធំបើកបរលើទម្ងន់: បញ្ហានេះដែលគឺបានកើតឡើងគ្រប់ភូមិទាំងអស់នៅក្នុងឃុំប្រាសាទ គឺតែងតែទទួលនូវឥទ្ធិពលមួយចំនួនពីសង្គមដែលបង្កការលំបាកដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមានដូចជា បញ្ហានយោបាយនៅក្នុងសង្គមទាំងមូល ការប្រើប្រាស់រថយន្តផ្ទុកទំនិញលើសទំងន់ដែលបានកំណត់ ការចាត់ចែងថវិការនិងសម្ភារៈសាងសង់ពុំបាន

ត្រឹមត្រូវ ខ្វះខាត់ភាពទំនួលខុសត្រូវរបស់អ្នកមៅការ និងការមិនបានត្រួចពិនិត្យ ឬពុំបានត្រួចពិនិត្យត្រឹមត្រូវ។

- កត្តាអនាម័យ: ប្រជាជននៅក្នុងឃុំប្រាសាទមានការយល់ដឹងតិចពីអនាម័យពីព្រោះកម្មវិធី ឬការជួបជុំដែលអប់រំពីអត្ថប្រយោជន៍នៃការប្រើប្រាស់បង្គន់អនាម័យ នៅមានកម្រិតហើយពុំធ្វើឡើងជាច្រើនដងនោះទេ ហើយបើទោះជាមានក៏ប្រជាជនជាច្រើនមិនបានទៅចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយដែរ ទើបជាហេតុដែលពួកគាត់មួយចំនួននៅតែប្រកាន់ភ្ជាប់ការបន្ទោរបង់នៅតាមព្រៃតូចៗក្បែរផ្ទះរបស់ពួកគាត់ និងប្រើប្រាស់ទឹកមិនស្អាត។ ហើយកាលណាប្រជាជនបានយល់ដឹងពីសារៈប្រយោជន៍សំខាន់នៃការប្រើប្រាស់បង្គន់អនាម័យដែលជួយការពារពួកគាត់ពីជម្ងឺផ្សេងៗនិងមានភាពងាយស្រួលក្នុងការប្រើប្រាស់ នោះពួកគាត់និងពិចារណាក្នុងការកសាងសង់បង្គន់អនាម័យ។
- តំបន់មួយចំនួនមានបញ្ហាលិចទឹក: បញ្ហាលិចទឹកនេះពិតជាមានការលំបាកខ្លាំងណាស់ក្នុងការអភិវឌ្ឍនៅក្នុងតំបន់ជនបទនេះ និងបញ្ហានេះបានកើតឡើងនៅគ្រប់ភូមិទាំងអស់នៃឃុំប្រាសាទហើយតំបន់ដែលមានបញ្ហាលិចទឹកនេះផងដែរ ក៏ងាយនឹងមានការឆ្លងជម្ងឺផ្សេងៗទៀតយ៉ាងងាយស្រួល ដោយសារប្រជាជនដែលរស់នៅក្នុងឃុំនេះមិនបានយល់ដឹងពិការប្រើប្រាស់ទឹកស្អាត និង ការបន្ទោរបង់ឲ្យបានត្រឹមត្រូវ និងមានអនាម័យក្នុងការរស់នៅប្រចាំថ្ងៃ។ តំបន់ដែលមានការលិចនេះគឺពិតជាមានការលំបាកក្នុងការសាងសង់បង្គន់អនាម័យ។

## ៣.៤. ដំណោះស្រាយ

ដើម្បីដោះស្រាយនូវបញ្ហាដែលជះឥទ្ធិពលទៅលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គេគួរធ្វើការសិក្សាឲ្យបានត្រឹមត្រូវទៅលើបញ្ហាដែលជួបប្រទះ ហើយដំណោះស្រាយទាំងអស់នោះរួមមាន:

- ✓ កត្តាទឹកស្រោចស្រពដីកសិកម្មមិនគ្រប់គ្រាន់: ឆ្លើយតបចំពោះបញ្ហានេះ រាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងធនធានទឹកនិងឧត្តុនិយម គួរតែពិនិត្យ យកចិត្តទុកដាក់ និងដោះស្រាយបញ្ហាគ្មានប្រព័ន្ធស្រោចស្រព (ប្រជាជនក្នុងឃុំភាគច្រើនកំពុងជួបប្រទះ) និងបញ្ហាមិនមានទឹកគ្រប់គ្រាន់ក្នុងការស្រោចស្រព។ ស្របទៅតាម គោលនយោបាយទឹក និងប្រព័ន្ធធារាសាស្ត្រសម្រាប់នីតិកាលទី៥ រួមមានការលើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ បង្កើនប្រសិទ្ធភាពនៃការថែទាំ និង

ជួសជុលហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ។ ជាក់ស្តែង យោងតាមប្រភពទិន្នន័យខាងលើក្នុងឃុំនេះត្រូវធ្វើការដោះស្រាយបញ្ហាប្រព័ន្ធធាដោយៈ កសាងប្រព័ន្ធធារាសាស្ត្រថ្មី នៅគ្រប់ភូមិទាំងអស់ដោយចាប់ផ្តើមពីភូមិដែលជួបប្រទះ បញ្ហាច្រើនទៅតិចតាមលំដាប់រៀងគ្នាដូចជា ភូមិជ្រលង និងភូមិថ្កូវ (បញ្ហាស្មើគ្នា), ភូមិចំបក់ និងភូមិពាន់វត្ត(បញ្ហាស្មើគ្នា), ភូមិបី,ភូមិអំពិល,ភូមិត្លុង,ភូមិប្រាសាទ, និងភូមិដូនទុង។ ទី២គឺធ្វើការជួសជុល ឬស្តារប្រព័ន្ធធារាសាស្ត្រ នៅភូមិចំនួន៤ ដោយចាប់ផ្តើមពីភូមិដែលជួបប្រទះបញ្ហាច្រើនតិចទៅតាមលំដា ប់រៀងគ្នាដូចជា ភូមិអំពិល, ភូមិប្រាសាទ, ភូមិដូនទុង និងភូមិថ្កូវ(បញ្ហាស្មើគ្នា)។ សម្គាល់ៈ ភូមិចំនួន ៤ មានភូមិអំពិល ភូមិប្រាសាទ ភូមិដូនទុង និងភូមិថ្កូវ ជួបបញ្ហាទាំង២ខាងលើដោយគ្រួសារខ្លះក្នុងភូមិទាំងនេះមានដីស្រែដែលមិនមានប្រឡាយទឹក និងគ្រួសារខ្លះទៀតមានប្រឡាយ ប៉ុន្តែមិនមានទឹកស្រោចស្រពគ្រប់គ្រាន់។ យោងតាមទិន្នន័យវិភាគដែលទទួលបានពីប្រជាជន ជាទូទៅ ដីស្រែដែលនៅជិត ប្រព័ន្ធធារាសាស្ត្រ អាចមានលទ្ធភាពធ្វើការដាំដុះបាន ២រដូវ ឬ៣រដូវ ប៉ុន្តែចំពោះដីស្រែដែលគ្មានប្រព័ន្ធធារាសាស្ត្រ អាចធ្វើការដាំដុះបានតែម្តងគត់។ ប្រសិនបើដោះស្រាយបញ្ហានោះបាន នោះពិតជាធ្វើឲ្យកើនឡើងកម្រិតជីវភាពរបស់ប្រជាកសិករមែន ព្រោះបើតាមទិន្នន័យវិភាគបញ្ជាក់ថា ទិន្នផលជាមធ្យមនៃការដាំដុះតែមួយរដូវ ស្មើនឹង ២,១១តោនក្នុង១ហិកតា។ រីឯទិន្នផលជាមធ្យមនៃការដាំដុះ២រដូវ ស្មើនឹង ៥,៣០តោនក្នុង១ហិកតា ហើយចំពោះទិន្នផលជាមធ្យមនៃការដាំដុះ ៣រដូវ ស្មើនឹង ៦,២០ តោនក្នុង១ហិកតា។ ចំពោះអាជ្ញាធរដែនដីមូលដ្ឋានក្នុងឃុំប្រាសាទផ្ទាល់ មានគោលដៅឲ្យប្រជាកសិករមានទឹកស្រោចស្រពដំណាំកសិកម្មគ្រប់គ្រាន់ដែលតម្រូវឲ្យជួសជុល ស្តារ និងកសាងប្រព័ន្ធធារាសាស្ត្រថ្មីប្រវែង ១៥គីឡូម៉ែត្រនៅឆ្នាំ ២០២២ (សព្វថ្ងៃមានប្រវែងត្រឹមតែ ៣គីឡូម៉ែត្រតែប៉ុណ្ណោះ)។

- ✓ កត្តាថវិកា: មិនថានៅទីណា តំបន់ណា ឬឃុំណាទេគឺសុទ្ធសឹងតែជួបបញ្ហាខ្វះខាត់ថវិកាក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដូចគ្នានេះដែលឃុំប្រាសាទក៏បែបនេះដែរ ដើម្បីដោះស្រាយនូវបញ្ហានេះមានតែធ្វើការដេញថ្លៃក្នុងការសាងសង់ ដើម្បីកាត់បន្ថយការចំណាយខ្ពស់ និងទទួលបានគុណភាពខ្ពស់, ស្វែងរកដៃគូអភិវឌ្ឍនិងសប្បុរសជល់ជនបទឲ្យបានច្រើនដូចជា ស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលជាដើម, ស្នើទៅកាន់រាជរដ្ឋាភិបាលក្នុងការផ្តល់ជំនួយក្នុងការអភិវឌ្ឍឃុំប្រាសាទ ស្រុកកំពង់ត្របែក ដែលមានភូមិចំនួន៩ និងបង្កើតកម្មវិធីសប្បុរសធម៌ ដើម្បីទទួលបានប្រាក់សម្រាប់អភិវឌ្ឍ

- ✓ រថយន្តធំបើកបរលើសទម្ងន់: ដំណោះស្រាយនៃបញ្ហានេះ មានដូចជាទប់ស្កាត់ការប្រើប្រាស់រថយន្តផ្ទុកទំនិញលើសទំងន់ដែលបានកំណត់, រក្សាសន្តិភាព និងសណ្តាប់ធ្នាប់ល្អក្នុងប្រទេស, រៀបចំគោលនយោបាយក្នុងប្រទេសទាំងមូលឲ្យបានត្រឹមត្រូវ និងបែងចែងថវិការក្នុងការសាងសង់ឲ្យមានប្រសិទ្ធិភាពខ្ពស់
- ✓ កត្តាអនាម័យ: វិធីសាស្ត្រក្នុងការដោះស្រាយបញ្ហានេះ គឺបង្កើនការបណ្តុះបណ្តាលដល់ជនបង្គោល ដើម្បីធ្វើការអប់រំបន្តដល់ប្រជាជននៅជនបទឲ្យទទួលបាននូវចំណេះដឹងពីអនាម័យ ឬក៏អាចប្រើវិធីសាស្ត្រមួយទៀតគឺ ការផ្តល់អំណាយ ឬ វត្ថុអនុស្សាវរីយ៍ដល់អ្នកចូលរួមដើម្បីលើកទឹកចិត្តឲ្យប្រជាជនជនបទមកចូលរួមការប្រជុំអប់រំស្តីពីអនាម័យក្នុងការរស់នៅប្រចាំថ្ងៃ។
- ✓ តំបន់មួយចំនួនមានបញ្ហាលិចទឹក: ដើម្បីដោះស្រាយលើតំបន់ដែលលិចទឹកគឺ ត្រូវឲ្យប្រជាពលរដ្ឋដែលរស់នៅតំបន់នេះឲ្យពួកគាត់ចេះហូបស្អាត ផឹកស្អាតគឺទឹកដែលដាំពុះ និងចម្រោះបានត្រឹមត្រូវ និងរស់នៅស្អាតដោយមានការសម្អាតផ្ទះសំបែងឲ្យបានស្អាត ហើយមួយវិញគឺការដាក់លូឲ្យបានត្រឹមត្រូវ។

## ៣.៥. វាយតម្លៃ

### ៣.៥.១. គុណសម្បត្តិ

ក្រោមការអភិវឌ្ឍជនបទដល់មានប្រសិទ្ធិភាព ទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត័បានផ្តល់នូវគុណសម្បត្តិជាច្រើនដូចជា:

- ផ្តល់ជាផ្លូវលំដីស ផ្លូវក្រាលខ្សាច់ និងផ្លូវកៅស៊ូដែលជាផ្លូវល្អសម្រាប់ឲ្យប្រជាជនមានភាពងាយស្រួលដល់ការធ្វើដំណើរទៅមក
- អាចមានការធ្វើការសមាហរណកម្មរវាងទីក្រុង ទីប្រជុំជន និងជនបទ
- អាចទាក់ទាញអ្នកវិនិយោគឲ្យទៅកាន់ទីប្រជុំជន និងជនបទ
- ផ្តល់ភាពងាយស្រួលក្នុងការតភ្ជាប់ទំនាក់ទំនង ពីតំបន់មួយទៅតំបន់មួយផ្សេងៗទៀតដោយមានការធ្វើដំណើរចុះឡើងពីសំណាក់ប្រជាជនដែលរស់នៅក្នុងតំបន់
- ផ្តល់ភាពងាយស្រួលក្នុងការដឹកជញ្ជូនទំនិញ ឬផលិតផលកសិកម្មទៅកាន់ទីផ្សារ
- លើកកម្ពស់ជីវភាពប្រជាជនក្នុងតំបន់ដោយមានការបង្កើតនូវទំនាក់ទំនងពាណិជ្ជកម្មរវាងប្រជាពលរដ្ឋដែលរស់នៅក្នុងផ្សេង
- កាត់បន្ថយគម្លាត រវាងទីក្រុង និងកន្លែងជនបទជាច្រើនតាមរយៈជីវភាពរបស់ប្រជាពលរដ្ឋនៅតាមជនបទ
- កាត់បន្ថយការធ្វើចំណាកស្រុកពីជនបទ ទៅកាន់ទីក្រុង ដោយបង្កើតនូវរោងចក្រ មន្ទីរពេទ្យ សាលារៀន និងជាប្រភពចំណូលដល់ពួកគេ
- កាត់បន្ថយការចំណាយពេលវេលាច្រើនក្នុងការធ្វើដំណើរ
- កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលមកពីបញ្ហាផ្លូវថ្នល់
- ផ្តល់ភាពងាយស្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ ដោយមានការភាពរីកចម្រើនទាំងសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងសន្តិភាពក្នុងតំបន់ជាដើម

- បង្កើននូវគុណភាពអប់រំ តាមរយៈការពង្រឹងនូវប្រព័ន្ធអប់រំឲ្យមានគុណភាព និងបង្កើតសាលារៀនឲ្យបានច្រើន
- បង្កើននូវចំណេះដឹង និងព័ត៍មានសារធារណៈដល់ប្រជាជនតាមរយៈការផ្សព្វផ្សាយពីសំណាក់មេឃុំ មេភូមិ និងភ្នាក់ងារភូមិជាដើម
- កាត់បន្ថយអក្ខរជននៅតាមទីជនបទ
- ផ្សព្វផ្សាយចំណេះដឹងទាក់ទងនិងសុខភាព ( បង្កើនអនាម័យ តាមដានសុខភាព និង វិធីបង្ការជម្ងឺផ្សេងៗ )

### ៣.៥.២. គុណវិបត្តិ

ថ្វីត្បិតតែការអភិវឌ្ឍហេដ្ឋារចនាស័ម្ពន្ធរូបវន្តបានផ្តល់នូវគុណសម្បត្តិយ៉ាងច្រើនសន្ធឹកសន្ធាប់ ចំពោះប្រជាជននៅទីជនបទ ប៉ុន្តែក៏មានផលអវិជ្ជមានមួយចំនួនចំពោះប្រជាជនដែលរស់នៅជិតតំបន់អភិវឌ្ឍក្នុងកំឡុងពេលកំពុងអភិវឌ្ឍន៍ដូចជាៈ

- ធ្វើឲ្យមានផលប៉ះពាល់ដល់សុខភាពប្រជាជនដែលរស់នៅតាមផ្លូវ ដែលបណ្តាលមកពីការហុយដីក្នុងកំឡុងពេលជួសជុល
- រាំងស្ទះការធ្វើដំណើររបស់ប្រជាជនក្នុងតំបន់
- អាចបង្កជាគ្រោះថ្នាក់ចរាចរណ៍ ដោយកក្តាផ្លូវរអិល ផ្លូវជុះកទឹក ផ្លូវរណ្តៅ
- ខាត់បង់ការសិក្សារបស់របស់កុមារ ដោយមានការពិបាកធ្វើដំណើរទៅសាលារៀន
- ខាត់បង់ពេលវេលារកស៊ី និងធ្វើកសិកម្មរបស់កសិករ
- ធ្វើឲ្យដីដែលនៅជាប់ចិញ្ចឹមផ្លូវមានសភាពក្រាំង មិនអាចធ្វើកសិកម្មបាន ដោយសារសារធាតុគីមីហូរចេញពីផ្លូវ
- ចំណាយថវិកាច្រើនក្នុងការជួសជុល និងថែទាំផ្លូវថ្នល់
- ផ្លូវដែលកំពុងជួសជុលអាចធ្វើឲ្យប៉ះពាល់ដល់ដំណាំស្រែ ចំការរបស់ប្រជាពលរដ្ឋ
- ដំណាំស្រូវទទួលបានទិន្នផលខ្ពស់
- បង្កើនប្រាក់ចំណូលដល់ប្រជាកសិករ ដែលធ្វើឲ្យជីវភាពរបស់ពួកគាត់កាន់តែប្រសើរឡើង
- ធ្វើឲ្យមានកំណើនទិន្នផលដំណាំស្រូវ និងដំណាំកសិកម្មទូទាំងប្រទេស
- កាត់បន្ថយផលប៉ះពាល់ហេដ្ឋារចនាស័ម្ពន្ធ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋពីគ្រោះទឹកជំនន់ជាដើម។

សរុបសេចក្តីមកវិញ ជំពូកទីបីនេះគឺជាជំពូកដែលមានអត្ថប្រយោជន៍យ៉ាងខ្លាំងសំរាប់ការសិក្សា និងការអភិវឌ្ឍឃុំសង្កាត់ ដោយពួកយើងបានធ្វើការវិភាគយ៉ាងម៉ត់ចត់ទៅលើសមិទ្ធិផលធ្វើការពិភាក្សាទៅលើបញ្ហាប្រឈម និងស្វែងរកដំណោះស្រាយជាច្រើនដែលអាចធ្វើជាស្ពានក្នុងការអភិវឌ្ឍ និងយកទៅដោះស្រាយនូវបញ្ហាដែលកើតមានឡើងនៅក្នុងឃុំឲ្យមានប្រសិទ្ធិភាព និងកាត់បន្ថយនូវបញ្ហាក៏ដូចជាឧបគ្គសដែលធ្វើឲ្យមានភាពយឺតយ៉ាវក្នុងការអភិវឌ្ឍ។ ក្រៅពីនេះគេអាចយកដំណោះស្រាយទាំងនេះ ទៅដោះស្រាយបញ្ហានៅក្នុងស្រុកភូមិដទៃផ្សេងទៀត ដែលជួបនូវបញ្ហាស្រដៀងគ្នានេះដែរ ឬដូចគ្នាទៅនិងបញ្ហាដែលកើតមានឡើងទៀតនៅក្នុងឃុំប្រាសាទនេះផងដែរ។

# សេចក្តីសន្និដ្ឋាន
# និង ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទបានល្អ ជាហេតុជម្រុញឲ្យមានកើនឡើងនូវកំណើនសេដ្ឋកិច្ចក្នុងស្រុក ក៏ដូចជាប្រទេសជាតិទាំងមូល ដែលអាចជួយកាត់បន្ថយភាពក្រិក្ររបស់ប្រជាជននៅជនបទ ហើយក៏ជាគោលបំណងនៃយុទ្ធសាស្ត្រក្នុងការកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលផងដែរ។ ភាពរីកចម្រើននៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ អាចធ្វើឲ្យមានភាពងាយស្រួលក្នុងការតភ្ជាប់ពីតំបន់មួយទៅតំបន់មួយទៀតដោយមានការអភិវឌ្ឍន៍ផ្លូវខ្វាត់ខ្វែងដល់ការធ្វើដំណើរ និងធ្វើសកម្មភាពសេដ្ឋកិច្ចរវាងទីជនបទ និងទីក្រុងមានភាពឆាប់រហ័ស។ ម្យ៉ាងវិញទៀត ការអភិវឌ្ឍន៍ជនបទ ក៏អាចកាត់បន្ថយបាននូវបញ្ហាជាច្រើនទៀត ដូចជាបញ្ហាអនក្ខរភាព និងការធ្វើចំណាកស្រុកពីជនបទទៅកាន់ទីក្រុងផងដែរ។

ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទបានគ្រប់គ្រាន់ដែលមានដូចជា ផ្លូវលំ លូ ស្ពាន សាលារៀន មន្ទីរពេទ្យ ជាពិសេសប្រព័ន្ធធារាសាស្ត្រដែលអាចឲ្យប្រជាពលរដ្ឋធ្វើស្រែចំការនិងទទួលបានទិន្នផលខ្ពស់ដោយមានទឹកគ្រប់គ្រាន់ក្នុងការស្រោចស្រពដំណាំ និងជួយបង្កើននូវប្រាក់ចំណូលដល់កសិករ។

ចំណែកឯឃុំប្រាសាទនេះវិញ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តគេឃើញមានការរីកចម្រើនយ៉ាងខ្លាំងតាមរយៈការអនុវត្តតាមចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ឃុំដោយក្នុងនោះគេឃើញមានការសាងសង់ផ្លូវជាច្រើនដូចជាផ្លូវលំ ផ្លូវលំក្រាល់ដីស ការដាក់លូតាមដងផ្លូវ ការថែទាំផ្លូវជាដើម។ ក្រៅពីនេះទៅទៀតគេឃើញមានការស្តារប្រឡាយ ដាក់លូរំដោះទឹកភ្លៀង និងការឧបត្ថម្ភនូវម៉ាស៊ីនបូមទឹកសម្រាប់ឲ្យប្រជាជនប្រើប្រាស់ជាដើម។ ទន្ទឹមនឹងភាពជោគជ័យទាំងនេះ ឃុំក៏បានជួបនូវបញ្ហាមួយចំនួនដែលជាឧបគ្គសក្នុងការអភិវឌ្ឍន៍ឃុំផងដែរ គឺបញ្ហាខ្វះថវិការគាំទ្រ ប្រជាជនក្រីក្រ ការធ្វើចំណាកស្រុក ប្រជាជនខ្វះចំណេះដឹងនិងជំនាញ បញ្ហាខ្វះបច្ចេកទេស និងភាពអត់ការងារធ្វើជាដើម។ ដោយហេតុនេះហើយទើប យើងខ្ញុំបានធ្វើការបកស្រាយ និងបង្ហាញពីរបៀបនៃការដោះស្រាយបញ្ហាទាំងនេះដូចដែលបានបង្ហាញនៅខាងលើហើយយើងខ្ញុំជឿជាក់ថា វានឹងអាចជួយសម្រេចបំណងក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយនៅសេដ្ឋកិច្ចរបស់ប្រជាជននៅទីជនបទ និងធ្វើសេដ្ឋកិច្ចជាតិទាំងមូលឲ្យមានការកើនឡើងផងដែរ។

## ២. ការផ្តល់អនុសាសន៍

បន្ទាប់ពីការស្រាវជ្រាវ និងការចុះកម្មសិក្សាដោយផ្ទាល់របស់ក្រុមយើងខ្ញុំនៅឃុំប្រាសាទ យើងខ្ញុំសូមចូលរួមយោបល់ខ្លះៗក្នុងការអភិវឌ្ឍន៍ជនបទខេត្តព្រៃវែងដូចខាងក្រោមៈ

- ប្រព័ន្ធធារាសាស្ត្រសម្រាប់នីតិកាលទី៥ រួមមានការលើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ បង្កើនប្រសិទ្ធភាពនៃការថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ។
- ស្វែងរកដៃគូអភិវឌ្ឍន៍និងសប្បុរសជល់ជនបទឲ្យបានច្រើនដូចជា ស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលជាដើម និង ស្នើទៅកាន់រាជរដ្ឋាភិបាលក្នុងការផ្តល់ជំនួយផ្សេងក្នុងការអភិវឌ្ឍស្រុក ភូមិ និងបង្កើតកម្មវិធីសប្បុរសធម៌ ដើម្បីទទួលបានប្រាក់សម្រាប់អភិវឌ្ឍ។
- គួរសាងសង់ផ្លូវថ្មីក្រាលដោយកៅស៊ូពីរជាន់ជំនួសដោយគ្រួសក្រហមនៅផ្លូវណា ដែលមានសកម្មភាពចរាចរណ៍មមាញឹកព្រោះអាចរក្សាគុណភាពផ្លូវបានយូរអង្វែង និងមិនពិបាកថែទាំច្រើនដង។
- ចំពោះតំបន់ជនបទមួយចំនួនដែលប្រជាជនមានជីវភាពធូរធារ ឬមធ្យម គួរតែឲ្យប្រជាជនចូលរួមបដិភាគថវិការខ្លះក្នុងការសាង់សង់ផ្លូវលំជនបទដើម្បីឲ្យប្រជាជនមានស្មារតីទទួលខុសត្រូវនិងការពារផ្លូវដែលជាទ្រព្យសម្បត្តិរួមរបស់សាធារណៈ។
- ត្រូវឲ្យប្រជាពលរដ្ឋដែលរស់នៅតំបន់នេះឲ្យពួកគាត់ចេះហូបស្អាត ផឹកស្អាតគឺទឹកដែលដាំពុះ និងចម្រោះបានត្រឹមត្រូវ និងរស់នៅស្អាតដោយមានការសម្អាតផ្ទះសំបែងឲ្យបានស្អាត ហើយមួយវិញគឺការដាក់លូឲ្យបានត្រឹមត្រូវ។
- គួរបណ្តុះបណ្តាលប្រធានភូមិ ឬប្រជាជនមួយចំនួននៅក្នុងភូមិ អំពីវិធីជួលជុលអណ្តូងដែលខូចដើម្បីឲ្យប្រជាជនអាចទទួលបានទឹកប្រើប្រាស់ទាន់ពេលវេលាឡើងវិញ ពេលអណ្តូងខូច។
- គួរជីកស្រះរួមឲ្យបានច្រើន ដើម្បីរក្សាទុកទឹកភ្លៀងនារដូវវស្សាទុកសម្រាប់ប្រើប្រាស់នៅរដូវប្រាំងចំពោះតំបន់ដែលនៅឆ្ងាយពីប្រភពទឹក។
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង គួរបង្កើនការធ្វើសហការជាមួយអង្គការជាដៃគូរដើម្បីជំរុញឲ្យមានការអភិវឌ្ឍកាន់តែឆាប់រហ័ស។
- ស្វែងរកជំនួយបរទេសក្នុងការបណ្តុះបណ្តាលនូវបច្ចេកទេសក្នុងការអភិវឌ្ឍជនបទ និងបច្ចេកទេសក្នុងការសាង់សង់ផងដែរ។

- ប៉ូលីសចរាចរណ៍ ឬ ស្ថាបន័ដែលពាក់ពន្ធចូលរួមផាកពិន័យយានយន្តដែលផ្ទុកល្មើសច្បាប់ ដូចជាការដាក់បង្គោលមិនអនុញ្ញាតឲ្យមានរថយន្តធុនធ្ងន់ឆ្លងកាត់ជាដើម។

# ឯកសារយោង

# ឯកសារយោង


1. សៀវភៅ សេដ្ឋកិច្ចអភិវឌ្ឍន៍ រៀបរៀងដោយបណ្ឌិត ជ្រឹង ហៃ និងបណ្ឌិត ទិន ហេង, បោះពុម្ពនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧
2. ជួនណាត វចនានុក្រមខ្មែរ ភាគទី១ ទី២ ភ្នំពេញ ពុទ្ធសាសនបណ្ឌិត១៩៦៧ ទំព័រ១៦៦៦
3. សាស្ត្រាចារ្យបណ្ឌិត ឈុន ពហុ មេរៀនក្នុងមុខវិជ្ជា អភិវឌ្ឍន៍ជនបទ ឆ្នាំសិក្សា ២០១៧ ២០១៨
4. ដកស្រង់ចេញពីសៀវភៅ សន្ធានុក្រមពាក្យថ្មី(សាស្ត្រាចារ្យ ទូច គីមស្រ៊ាង សមាក្រុមប្រឹក្សា
5. https:/km.m.wikipedia.org/wiki/ហេដ្ឋារចនាសម្ព័ន្ធ
6. Khmerdict.wordpress.com
7. និស្សិត ឈិន ប៊ុនណាវ៉ាណិច របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា គំរោងកែលំអហេដ្ឋារចនាសម្ព័ន្ធដើម្បីអភិវឌ្ឍន៍ជនបទ ឆ្នាំ ២០១៤
8. សារណាបញ្ចប់ការសិក្សា ការសិក្សាអំពីកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ, របស់និស្សិត យិន ឡូត ឆ្នាំ២០១៦
9. របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា គំរោងកែលំអហេដ្ឋារចនាសម្ព័ន្ធជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ របស់និស្សិត យិន សុភា, ឈាក ពិសិដ្ឋ, ហាក់ បុប្ផារ័ត្ន ឆ្នាំ ២០០៦
10. សារណាបញ្ចប់ការសិក្សា ការសិក្សាអំពីកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ, របស់និស្សិត យិន ឡូត ឆ្នាំ២០១៦
11. Rostow´s stage of Growthដកស្រង់ចេញពីសៀវភៅ Michael P.TodaraEconomic Development, Eight Edition
12. សាស្ត្រាចារ្យ ហាស់ វង់ដារ៉ា មេរៀនក្នុងមុខវិជ្ជា កំណើនសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៧ ២០១៨
13. Prof. Dr. DUY CHANDINA, Economic Development, Academic year 2013-2014
14. និស្សិត ហាម ខេមរិន្ទ, របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា, ប្រធានបទ៖ ការអភិវឌ្ឍផ្លូវលំជនបទ(សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១០)
15. ទីស្តីការគណៈរដ្ឋមន្ត្រី, យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា ចតិកោណទី២.ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, មុំទី១. ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍, ឆ្នាំ ២០០៤

16. បាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា គំរោងកែលំអហេដ្ឋារចនាសម្ព័ន្ធជនបទ របស់និស្សិត នួន ឡាដា ឆ្នាំ ២០០៥
17. និស្សិត ផល វិទូ, របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា, ប្រធានបទៈ ការកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍផ្លូវលំ(សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច, ឆ្នាំ២០១១)
18. បទដ្ឋានណែនាំសម្រាប់អនុវត្តន៍ការងារថែទាំតាមរយៈការ(ខូប), ក្រសួងអភិវឌ្ឍជនបទ, ឆ្នាំ ២០១២
19. និស្សិត គង់ សេកលីម និង ទូច សេរីព័រ, របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា, ការជំរុញលើកស្ទួយសេដ្ឋកិច្ចជនបទករណីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង (សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច, ឆ្នាំ២០១៨)
20. ដកស្រង់ចេញពីឯកសារដើម កម្មវិធីវិនិយោគបីឆ្នាំរំកិល ( ២០១៩-២០២១) ឃុំប្រាសាទ
21. ដកស្រង់ចេញពីឯកសារដើម (ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ២០១៧ ដល់២០២១ ឃុំប្រាសាទ)
22. ដកស្រង់ចេញពីឯកសារដើម សេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៨ ឃុំប្រាសាទ
23. ដកស្រងពីឯកសារដើមៈ ឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ២០១៨ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

# ឧបសម្ព័ន្ធទី ១

# ឧបសម្ព័ន្ធទី ១៖ ផែនទីខេត្តព្រៃវែង



# ឧបសម្ព័ន្ធទី ២

# ផែនទីឃុំប្រាសាទ


ជើង
កំនត់សំគាល់
ស្ពាន
ប្រឡាយទឹក
វត្ត
មន្ទីរពេទ្យ
ព្រំប្រទល់ឃុំ
ផ្លូវលំ
ផ្សារ
សាលារៀន
ផ្លូវជាតិលេខ ១
ភូមិ
សាលាឃុំ
ប៉ុស្តិ៍រដ្ឋបាល
តំបន់ឆ្លងកាត់
មុខសញ្ញាលួច
មុខសញ្ញាសង្ស័យ
មុខសញ្ញាដោះលែង
ឃុំកន្សោមអក
ឃុំអន្សោង
ឃុំព្រៃឈរ
ឃុំកំពង់ត្របែក
វត្តប្រាសាទ
ភូមិប្រាសាទ
មន្ទីរពេទ្យបង្អែក
ស្រុកកំពង់ត្របែក
ភូមិប្រលេង
ភូមិចំបក់
ភូមិត្នោតទុង
សាលាឃុំ
ភូមិចំ
ភូមិភ្លង
ភូមិផ្លូវ
ភូមិអំពិល
វត្តអំពិល
ភូមិពាន់វត្ត
វត្តកល្យាណ:

# ឧបសម្ព័ន្ធទី ៣

**ចក្ខុវិស័យ៖** ប្រជាពលរដ្ឋ ឃុំប្រាសាទ ស្រុកកំពង់ត្របែក មានសុខមាលភាពល្អ ចំណូលកើនឡើង មានប្រព័ន្ធគមនាគមន៍ ធារាសាស្ត្រ ហើយរស់នៅក្នុងបរិស្ថានល្អ និងប្រកបដោយសុខសន្តិភាព ។

| គោលបំណង និងគោលដៅ | សូចនាករ | | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|---|
| | ការបរិយាយ | ឯកតា | ដើមគ្រា | ២០២២ | |
| **១.ផ្នែកសេដ្ឋកិច្ច** | | | | | |
| ១.១. គោលបំណងទី១៖ ប្រជាពលរដ្ឋមានផ្លូវល្អសម្រាប់ធ្វើដំណើរ និងដឹកជញ្ជូនផលិតផល មានទឹកស្រោចស្រពដីកសិកម្មគ្រប់គ្រាន់ ទិន្នន័យស្រូវកើនឡើង ធានាបានសន្តិសុខស្បៀង និងយល់ដឹងពីបច្ចេកទេសកសិកម្ម បច្ចេកទេសចិញ្ចឹមសត្វ ដើម្បីបង្កើនប្រាក់ចំណូល ។ | | | | | |
| ១.១.១. គោលដៅទី១៖ នៅបំណាច់ឆ្នាំ ២០២២ ផ្លូវលំដែលខូចខាតត្រូវបានជួសជុលបានល្អប្រសើរឡើងវិញ | ប្រជាពលរដ្ឋមានផ្លូវល្អសម្រាប់ធ្វើដំណើរ ប្រវែង ២៥ គីឡូម៉ែត្រ | គ.ម | ៥ | ២៥ | • ជួសជុលផ្លូវលំ ក្រាលខ្សាច់ក្រហម |
| | | គ.ម | ៥ | ២៥ | • ជួសជុលផ្លូវលំដីស |
| | | គ.ម | ៣ | ១៥ | • ថែទាំផ្លូវក្រាលខ្សាច់ |
| | | គណៈកម្មការ | ១ | ៥ | • បង្កើតគណៈកម្មការថែទាំផ្លូវ |
| | | កន្លែង | ៣ | ១៥ | • ដាក់លូកាត់ផ្លូវ |
| ១.១.២.គោលដៅទី២៖ កសិករមានទឹកស្រោចស្រពដំណាំកសិកម្មគ្រប់គ្រាន់ | ប្រព័ន្ធធារាសាស្ត្រត្រូវជួសជុល ប្រវែង ១៥ គ.ម | គ.ម | ៣ | ១៥ | • ស្តារប្រឡាយស្រោចស្រព |
| | | ម៉ាស៊ីន | ២ | ១០ | • ផ្តល់ម៉ាស៊ីនបូមទឹក |

| គោលបំណង និងគោលដៅ | សូចនាករ<br>ការរៀបរាប់ | ឯកតា | ដើមគ្រា | ២០២២ | យុទ្ធសាស្ត្រអនុវត្ត |
|---|---|---|---|---|---|
| ១.១.៣.គោលដៅទី៣៖ បង្កើនទិន្នផលស្រូវ និងការចិញ្ចឹមសត្វ ដើម្បីបង្កើនប្រាក់ចំណូល | ទិន្នផលកើនឡើងពី ៣,៥ តោន ទៅ ៥ តោន/១ហិកតា និងជម្រុញការចិញ្ចឹមសត្វ | វគ្គ | ២ | ១០ | • បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ |
| | | តោន | ១,៥ | ៧,៥ | • ផ្តល់ពូជស្រូវទិន្នផលខ្ពស់ |
| | | វគ្គ | ២ | ១០ | • បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត |
| | | វគ្គ | ២ | ១០ | • បណ្តុះបណ្តាលបច្ចេកទេសផលិតជីកំប៉ុស្តិ៍ |
| | | វគ្គ | ២ | ១០ | • បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ |
| | | លើក | ១ | ៥ | • ផ្តល់វ៉ាក់សាំងការពារជម្ងឺសត្វ |
| | | វគ្គ | ១ | ៥ | • ពង្រឹងសមត្ថភាពពេទ្យសត្វភូមិ |
| | | ក្បាល | ៨០ | ៤០០ | • ផ្តល់ពូជសត្វល្អសម្រាប់ចិញ្ចឹម |
| | | វគ្គ | ២ | ១០ | • បណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ |
| | | ក្បាល | ៨០០ | ៤០.០០០ | • ផ្តល់ពូជត្រីចិញ្ចឹម |
| | | វគ្គ | ២ | ១០ | • វគ្គស្រែបង្ហាញដំណាំស្រូវ និងបង្ហាញចម្រុះ |
| | | កន្លែង | ២ | ១០ | • សាងសង់ឡជីវឧស្ម័ន |
| | | កន្លែង | ៥ | ២៥ | • ជីកស្រះចិញ្ចឹមត្រីលក្ខណៈគ្រួសារ |
| | | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយពីការប្រើប្រាស់ឥណទាន |
| | | វគ្គ | ២ | ១០ | • បណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ |

## ២.វិស័យសង្គមកិច្ច

២.១.គោលបំណងវិស័យអប់រំ៖ ប្រជាពលរដ្ឋមានចំណេះដឹង និងសមត្ថភាព រួមចំណែកយ៉ាងសំខាន់ក្នុងការងារសង្គម ។

| គោលបំណង និងគោលដៅ | សូចនាករ ការបរិយាយ | ឯកតា | ដើមគ្រា | ២០២២ | យុទ្ធសាស្ត្រអនុវត្ត |
|---|---|---|---|---|---|
| ២.១.១.គោលដៅទី១៖ កុមារអាយុពី ០៣ទៅ ០៥ ឆ្នាំ បានចូលរៀនគ្រប់គ្នា | បើកថ្នាក់មត្តេយ្យបន្ថែម ៨ ថ្នាក់ | ថ្នាក់ | ១ | ៦ | • បើកថ្នាក់មត្តេយ្យសហគមន៍ |
| | | កំប្លេ | ៩ | ៤៥ | • ផ្តល់សម្ភារៈថ្នាក់មត្តេយ្យ |
| | | នាក់ | ១ | ៩ | • ផ្តល់គ្រូមត្តេយ្យ |
| ២.១.២.គោលដៅទី២៖ ជំរុញក្មេងគ្រប់អាយុចាប់ពីអាយុ ០៦ទៅ ១១ឆ្នាំ ឲ្យបានចូលរៀនគ្រប់ៗគ្នា | ជំរុញកុមារដល់អាយុអោយចូលរៀនបាន១០០% | % | ៩៣ | ១០០ | • ជំរុញឪពុកម្តាយនាំកូនចូលរៀន |
| | សិស្សក្រីក្រ១ឆ្នាំ១២០នាក់ | នាក់ | ១២០ | ៦០០ | • ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ |
| | | អគារ | ១ | ២ | • សាងសង់អគារសិក្សា |
| | | នាក់ | ៥៥០ | ២,៧៥០ | • ផ្តល់អាហារពេលព្រឹក |
| ២.២. គោលបំណងវិស័យសុខាភិបាល៖ ប្រជាពលរដ្ឋមានសុខភាពល្អ យល់ដឹងពីសុខភាពអនាម័យ ជាពិសេសអត្រាមរណៈភាពមាតា និងទារកត្រូវបានលុបបំបាត់ ។ | | | | | |
| ២.២.១.គោលដៅទី១៖ ប្រជាពលរដ្ឋមានសុខភាពល្អ និងរស់នៅប្រកបដោយផាសុខភាព | ប្រជាពលរដ្ឋយល់ដឹងពីការថែទាំសុខភាព និងរស់នៅប្រកបដោយអនាម័យ | បង្គន់ | ២៤០ | ១២០០ | • សង់បង្គន់អានាម័យតាមខ្នងផ្ទះ |
| | | អណ្តូង | ១០ | ៥០ | • ជីកអណ្តូងទឹកស្អាត |
| | | ធុង | ១៦០ | ៨០០ | • ផ្តល់ធុងចម្រោះទឹកស្អាត |
| | | នាក់ | ៨០ | ៤០០ | • ផ្តល់អាហារូបត្ថម្ភ |
| | | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយពីសុខភាពអនាម័យ |
| | | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយពីសុខភាពបន្តពូជ |
| | | លើក | ៩ | ៤៥ | • ផ្តល់ការពិនិត្យទឹកអណ្តូងរកជាតិអាសេនិច |
| | | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយពីការបរិភោគទឹកមានសុវត្ថិភាព |
| ២.២.២. គោលដៅទី២៖ កាត់បន្ថយការឈឺ និងស្លាប់របស់មាតាទារក និងកុមារ | អត្រាឈឺ និងស្លាប់ មាតាទារកត្រូវបានលុបបំបាត់ | វគ្គ | ១ | ៥ | • បណ្តុះបណ្តាលសមត្ថភាពឆ្មប |
| | | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយពីសារៈប្រយោជន៍ការពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាព |

| គោលបំណង និងគោលដៅ | សូចនាករ | | | | យុទ្ធសាស្ត្រអនុវត្ត |
|---|---|---|---|---|---|
| | ការបរិយាយ | ឯកតា | ដើមគ្រា | ២០២២ | |
| | | លើក | ៥ | ៤៥ | • ជំរុញអ្នកមានផ្ទៃពោះមកទទួលសេវានៅមណ្ឌលសុខភាព |
| | | លើក | ២ | ១០ | • ផ្តល់អាហារបន្ថែមដល់ស្ត្រីមានផ្ទៃពោះ |
| ២.២.៣.គោលដៅទី៣៖ កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយសារជំងឺអេដស៍ | កាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍ជំងឺអេដស៍ | លើក | ៥ | ៤៥ | • អប់រំនិងផ្សព្វផ្សាយពីការឆ្លងនៃជំងឺអេដស៍ |
| | | លើក | ១ | ៥ | • ផ្តល់ការគាំទ្រអ្នក ផ្ទុក និងអ្នកជំងឺអេដស៍ |
| **២.៣.គោលបំណងវិស័យសង្គមកិច្ច៖** បង្កើនប្រសិទ្ធិភាព ការផ្តល់សេវាសុខាភិបាល ដើម្បីរក្សាសុខមាលភាពប្រជាពលរដ្ឋ និងបង្កើនការយកចិត្តទុកដាក់ក្រុមជនងាយរងគ្រោះ កុមារកំព្រា ជនពិការ ស្ត្រីមេម៉ាយ និងការរំលោភបំពានផ្សេងៗ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ។ | | | | | |
| ២.៣.១.គោលដៅទី១៖ ជនរងគ្រោះ និងក្រុមងាយរងគ្រោះ ត្រូវបានយកចិត្តទុកដាក់ ហើយប្រជាពលរដ្ឋចំណាកស្រុកប្រកបដោយសុវត្ថិភាព | ក្រុមជនងាយរងគ្រោះត្រូវបានកាត់បន្ថយ និងជម្រុញការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីចំណាកស្រុក | គ្រឿង | ៥ | ២៥ | • ឈើច្រត់ ទេះរុញ ជើងសិប្បនិម្មិត |
| | | វគ្គ | ១ | ៥ | • បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់ជនពិការ |
| | | លើក | ៥ | ៤៥ | • ផ្សព្វផ្សាយពីច្បាប់ចរាចរផ្លូវគោក |
| | | លើក | ១ | ៥ | • បញ្ជូនកុមារកំព្រា ចាស់ជរាគ្មានទីពឹងទៅមណ្ឌល |
| | | លើក | ៥ | ៤៥ | • ផ្សព្វផ្សាយពីច្បាប់ប្រឆាំងការជួញដូរស្រី និងកុមារ |
| | | លើក | ៥ | ៤៥ | • ផ្សព្វផ្សាយពីល្បិចកលឆបោករបស់ជនល្មើស |
| | | លើក | ៥ | ៤៥ | • ផ្សព្វផ្សាយពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព |

| គោលបំណង និងគោលដៅ | សូចនាករ | | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|---|
| | ការបរិយាយ | ឯកតា | ដើមគ្រា | ២០២២ | |
| **២.៤.គោលបំណងវិស័យយេនឌ័រ៖ កាត់បន្ថយអំពើ ហិង្សាក្នុងគ្រួសារ ។** | | | | | |
| ២.៤.១.គោលដៅទី១៖ លើកកម្ពស់ការយល់ដឹងពីច្បាប់ទប់ស្កាត់អំពើ ហិង្សាក្នុងគ្រួសារ | ប្រជាពលរដ្ឋយល់ដឹងពីច្បាប់ទប់ស្កាត់អំពើ ហិង្សាក្នុងគ្រួសារ | លើក<br>លើក<br>វគ្គ | ៩<br>៩<br>២ | ៤៥<br>៤៥<br>១០ | • ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស<br>• ផ្សព្វផ្សាយពីច្បាប់ទប់ស្កាត់អំពើ ហិង្សាក្នុងគ្រួសារ<br>• បណ្តុះបណ្តាលពីយេនឌ័រ |
| **៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនិងការប្រែប្រួលអាកាសធាតុ** | | | | | |
| ៣.១.គោលបំណងវិស័យធនធានធម្មជាតិ បរិស្ថាន៖ ប្រជាពលរដ្ឋមានការយល់ដឹងពីបំរែបំរួលអាកាសធាតុ ការការពារបរិស្ថាន កាត់បន្ថយជាតិពុល ដើម្បីបង្កើតត្រីធម្មជាតិ និងជីវៈចម្រុះ ។ | | | | | |
| ៣.១.១.គោលដៅទី១៖ លុបបំបាត់ការនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ | បង្កើនពូជត្រីធម្មជាតិតាមរយៈការលើកកម្ពស់ការយល់ដឹងពីច្បាប់ជលផល | លើក<br>កន្លែង<br>ក្បាល<br>លើក | ១១<br>១<br>២.១០០<br>៩ | ៥៥<br>១<br>២.១០០<br>៤៥ | • ផ្សព្វផ្សាយច្បាប់ជនផល<br>• ស្តារបឹងធម្មជាតិ<br>• ផ្តល់ពូជត្រីធម្មជាតិ<br>• ផ្សព្វផ្សាយពង្រឹងសកម្មភាពសហគមន៍នេសាទ |
| ៣.២.គោលបំណងវិស័យការបន្សាំនិងការប្រែប្រួលអាកាសធាតុ៖ប្រជាជនដែលរងគ្រោះដោយគ្រោះមហន្តរាយទទួលបានសេវាសង្គ្រោះបន្ទាន់និងការឆ្លើយតប ភ្លាមៗ និងបន្សាំ ទៅនឹងអាកាសធាតុ ។ | | | | | |
| ៣.២.១.គោលដៅទី២៖បង្កើនការយល់ដឹងដល់ប្រជាជនពីហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ | នៅបំណាច់ឆ្នាំ២០២២ប្រជាពលរដ្ឋយល់ដឹងពីការប្រែប្រួលអាកាសធាតុ | លើក<br>លើក | ៩<br>៩ | ៤៥<br>៤៥ | • ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ<br>• ផ្សព្វផ្សាយពីវិធីត្រៀមបង្ការគ្រោះមហន្តរាយនៃការប្រែប្រួលអាកាសធាតុ |
| **៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | |

| [illegible] | ការបរិយាយ | ឯកតា | ដើមគ្រា | ២០២២ | [illegible] |
|---|---|---|---|---|---|
| ៤.១.គោលបំណងវិស័យរដ្ឋបាល៖ បង្កើនការបម្រើសេវាសាធារណៈដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ភូមិ ឃុំ ឲ្យបានកាន់តែមានប្រសិទ្ធិភាព ។ | | | | | |
| ៤.១.១.គោលដៅទី១៖ ប្រជាពលរដ្ឋនឹងទទួលបានឯកសារអត្រានុកូលដ្ឋានគ្រប់ៗគ្នា | បង្កើនការយល់ដឹងពីសារៈប្រយោជន៍នៃការឯកសារអត្រានុកូលដ្ឋានតាមរយៈការផ្សព្វផ្សាយ | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាន |
| ៤.១.២.គោលដៅទី២៖ក្រុមប្រឹក្សាឃុំនិងថ្នាក់ដឹកនាំភូមិជាស្ត្រីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតួនាទីភារកិច្ចក្នុងការផ្តល់សេវារដ្ឋបាលដល់ប្រជាជន | បង្កើនសមត្ថភាពស្ត្រីតាមរយៈការបណ្តុះបណ្តាល | វគ្គ | ១ | ៥ | • បណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ស្ត្រី |
| **៤.២.គោលបំណងវិស័យសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ៖ ប្រជាពលរដ្ឋរស់នៅ ប្រកបដោយសុវត្ថិភាពនិងភាពសុខសាន្តនៅក្នុងសង្គម ។** | | | | | |
| ៤.២.១.គោលដៅទី២៖កាត់បន្ថយទំនាស់ដីធ្លីរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន | បង្កើនការយល់ប្រជាពលរដ្ឋតាមរយៈការផ្សព្វផ្សាយ | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពី ច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យដីធ្លី |
| ៤.២.២.គោលដៅទី៣៖ អនុវត្តច្បាប់ដើម្បីរក្សាសន្តិសុខសង្គម | បង្កើនការយល់ដល់ប្រជាពលរដ្ឋស្តីពីការអនុវត្តច្បាប់តាមរយៈការផ្សព្វផ្សាយជាប្រចាំ | លើក<br>លើក<br>លើក | ៩<br>៩<br>៩ | ៤៥<br>៤៥<br>៤៥ | • ជម្រុញអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព<br>• ផ្សព្វផ្សាយពីសារៈប្រយោជន៍ការរាយការណ៍ជនមុខសញ្ញា<br>• ផ្សព្វផ្សាយជម្រុញសកម្មភាពក្រុមប្រជាការពារ |

# ឧបសម្ព័ន្ធទី ៤

## តារាងប្រើប្រាស់ថវិកាឃុំ ឆ្នាំ២០១៩

| ល.រ | ឈ្មោះគម្រោង | ទីតាំងអនុវត្ត | លទ្ធផលគ្រោង | | តម្លៃប៉ាន់ស្មាន | | ប្រភពថវិកា | | អ្នកទទួលផល | |
|---|---|---|---|---|---|---|---|---|---|---|
| | | | ចំនួន | ឯកតា | ឯកតា | សរុប | មូលនិធិឃុំ | ទុនចូលរួម | សរុប | ស្រី |
| ១ | ជួសជុលផ្លូវលំក្រាលខ្សាច់ក្រហម | ០២,០៦ | ២.៦១ | គ.ម | ២៥លាន | ១២៥,៧២២,៧០៩ | ១២៥,៧២២,៧០៩ | ៣៥០,០០០រ | ៤,១៧៥ | ២,៩៦៩ |
| ២ | សាងសង់លូកាត់ផ្លូវ | ០៦, | ១ | កន្លែង | ៤,៤០០,០០០ | ៤,៤០០,០០០ | ៤,៤០០,០០០ | 0 | ៤,១៧៥ | ២,៩៦៩ |
| ៣ | ប្រាក់ឧបត្ថម្ភគ្រូមត្តេយ្យ | ០៣,០៥,០៦ | ៩ | ខែ | ៦០០,០០០ | ៥,៤០០,០០០ | ៥,៤០០,០០០ | 0 | ៧៥ | ៤៦ |
| ៤ | សម្ភារៈមត្តេយ្យសហគមន៍ | ឃុំ | ៩ | ខែ | ៨០,០០០ | ៧២០,០០០ | ៧២០,០០០ | 0 | ៧៥ | ៤៦ |
| ៥ | ផ្សព្វផ្សាយសុខភាព អនាម័យ | ឃុំ | ១០ | ខែ | ៣២០,០០០ | ៣,២០០,០០០ | ៣,២០០,០០០ | 0 | ៥៩៦៧ | ៣១២២ |

តារាង ១.២៖ លទ្ធផលនៃការអនុវត្តគម្រោងក្នុងឆ្នាំ ២០១៨ ឃុំ [illegible]

| ល.រ | ឈ្មោះគម្រោងសកម្មភាព | ទីតាំង | លទ្ធផល | | រយៈ | អ្នកទទួលផល | | តម្លៃ | ប្រភពនិធិ |
|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | ពេល | សរុប | ស្រី | | |
| **គម្រោងប្រើប្រាស់មូលនិធិឃុំ** | | | | | | | | | |
| **ក.បានអនុវត្តស្ថាពរ** | | | | | | | | | |
| **ខ.កំពុងអនុវត្ត** | | | | | | | | | |
| **ផ្នែកសេដ្ឋកិច្ច** | | | | | | | | | |
| ១ | ជួសជុលផ្លូវលំដីស | ភូមិអំពិល | ២,៦ | គ.ម | ៣ខែ | ៩១៦ | ៤៨១ | ៩៦,២០០,០០០. | មូលនិធិឃុំ |
| ២ | ដាក់លូ | អំពិល | ៣ | កន្លែង | ១ ខែ | ៩១៦ | ៤៨១ | ១៣,៥០០,០០០ | មូលនិធិឃុំ |
| **ផ្នែកសង្គមកិច្ច** | | | | | | | | | |
| ១ | មត្តេយ្យសហគមន៍ | ០២,០៤,០៦ | ៣ | ថ្នាក់ | ៩ ខែ | ២,៦៤៨ | ១,៤១៥ | ៤,៥០០,០០០. | មូលនិធិឃុំ |
| ២ | ជំនួយសេវាសង្គមផ្សេងៗ | ឃុំ | ១២ | ខែ | ១ ឆ្នាំ | ១៧៦ | ៨៩ | ១១,០៩៦,០០០ | មូលនិធិឃុំ |
| **គ.មិនបានអនុវត្ត** | | | | | | | | | |
| **គម្រោងឃុំដែលមានការសន្យាគាំទ្រ** | | | | | | | | | |
| **ឃ.បានអនុវត្តរួចជាស្ថាពរ** | | | | | | | | | |
| **ផ្នែកសេដ្ឋកិច្ច** | | | | | | | | | |
| ១ | ថែទាំផ្លូវប្រចាំ | ត្រោក ដូង | ៥៩០០ | ម | ១២ខែ | | | ១២ លាន | មន្ទីរអភិវឌ្ឍន៍ |
| | | | | | | | | | |
| | | | | | | | | | |
| **ផ្នែកសង្គមកិច្ច** | | | | | | | | | |
| | | | | | | | | | |
| **ខ.កំពុងអនុវត្ត** | | | | | | | | | |
| **ផ្នែកសេដ្ឋកិច្ច** | | | | | | | | | |
| ១ | សេវាឥណទាន | គ្រប់ភូមិ | | | | ១៣,០៧៨ | ៦,៥២៧ | | អេស៊ីលីដា |
| ២ | សេវាប្រាក់សន្សំ | គ្រប់ភូមិ | | | | ១៣,០៧៨ | ៦,៥២៧ | | អេស៊ីលីដា |

ក្រាហ្វិក៧.១៤ ៖ ភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់




### ៧.៦.១.ការប្រើប្រាស់ទឹកពីប្រភពផ្សេងៗ (គ្មាន)

### ៧.៦.២.ចំនួនអណ្តូង និងស្រះទឹក

| បរិយាយ | 2015 | 2016 | 2017 |
|---|---|---|---|
| ចំនួនអណ្តូងស្នប់ឬអណ្តូងចុះ | 2,160 | 2,154 | 2,023 |
| ចំនួនអណ្តូងជីកមានការពារ | 0 | 0 | 0 |
| ចំនួនអណ្តូងជីកគ្មានការពារ | 0 | 0 | 0 |
| ចំនួនស្រះទឹកដែលប្រើប្រាស់ | 0 | 0 | 0 |

### ៧.៧.អនាម័យនៃការទទួលទានទឹក

| បរិយាយ | | 2015 | 2016 | 2017 |
|---|---|---|---|---|
| សរុបគ្រួសារដែលមានទំលាប់ទទួលទានទឹកស្អាត | | 2,020 | 2,083 | 2,181 |
| ក្នុងនោះ: | ទឹកម៉ាស៊ីនឬទឹកបរិសុទ្ធ | 132 | 231 | 141 |
| | ប្រើឧបករណ៍ចម្រោះទឹក | 462 | 410 | 537 |
| | ធ្វើទឹកឱ្យស្អាតដោយដាក់សារធាតុក្លរ | 0 | 135 | 275 |
| | ទឹកសំលាប់មេរោគដោយពន្លឺព្រះអាទិត្យ | 0 | 0 | 0 |
| | ដោយដាំទឹកឱ្យពុះ | 1,426 | 1,307 | 1,228 |
| %ភាគរយគ្រួសារទំលាប់ទទួលទានទឹកស្អាត | | 72.8 | 74.5 | 77.3 |

ក្រាហ្វិក៧.១៥ ៖ ភាគរយគ្រួសារទំលាប់ទទួលទានទឹកស្អាត



ក្រាហ្វិកគ.១០ ៖ ភាគរយគ្រួសារដែលទទួលរងផលប៉ះពាល់ពីការបំពុលបរិស្ថាន (គ្មាន)

### គ.៥.ការប្រើប្រាស់បង្គន់អនាម័យ

| បរិយាយ | 2015 | 2016 | 2017 |
|---|---|---|---|
| ចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | 2,362 | 2,264 | 2,429 |
| ចំនួនគ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេស | 2,156 | 2,080 | 2,352 |
| %គ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេស | 77.7 | 74.4 | 83.4 |
| %គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | 85.1 | 81.0 | 86.1 |
| ចំនួនគ្រួសារមានប្រភពទឹកជិតជាង១៥០ម៉ែត្រពីផ្ទះ | 2,621 | 2,796 | 2,221 |
| %គ្រួសារមានប្រភពទឹកជិតជាង១៥០ម៉ែត្រពីផ្ទះ | 94.5 | 100.0 | 78.8 |

ក្រាហ្វិកគ.១១ ៖ ភាគរយគ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេស




ក្រាហ្វិកគ.១២ ៖ ភាគរយគ្រួសារមានប្រភពទឹកជិតជាង១៥០ម៉ែត្រ




### គ.៦.ការប្រើប្រាស់ទឹក

| បរិយាយ | | 2015 | 2016 | 2017 |
|---|---|---|---|---|
| សរុបគ្រួសារមានទឹកស្អាតប្រើប្រាស់ | | 2,774 | 2,796 | 2,820 |
| ក្នុងនោះ: | ទឹកដែលឆ្លងកាត់ប្រព័ន្ធធ្វើទឹកឱ្យស្អាត | 150 | 290 | 650 |
| | ទឹកអណ្តូងស្នប់ឬអណ្តូងចំរុះ | 2,624 | 2,506 | 2,170 |
| | ទឹកអណ្តូងជីកមានការការពារ | 0 | 0 | 0 |
| | ទឹកភ្លៀងដែលមានការការពារ | 0 | 0 | 0 |
| %គ្រួសារមានទឹកស្អាតប្រើប្រាស់ | | 100.0 | 100.0 | 100.0 |

ក្រាហ្វិក៣.៥ ៖ ភាគរយអ្នកធ្វើចំណាកស្រុកទៅក្រៅប្រទេស(អាយុ១៨ឡើង)




ក្រាហ្វិក៣.៦ ៖ ចំនួនមនុស្សធ្វើចំណាកស្រុកនៅក្នុងប្រទេសនិងក្រៅប្រទេស




## ៣.៤.ផ្ទៃដីនិងផ្លូវ

| បរិយាយ | | 2015 | 2016 | 2017 |
|---|---|---|---|---|
| សរុបផ្ទៃដីឃុំសង្កាត់ | | 2,908 | 2,908 | 2,908 |
| សរុបប្រវែងផ្លូវ | | 31,295 | 31,295 | 31,295 |
| ក្នុងនោះ: | ប្រវែងផ្លូវតាមបណ្តាឃុំសង្កាត់ | 19,295.0 | 19,295.0 | 19,295.0 |
| | ប្រវែងផ្លូវខេត្តស្រុកឆ្លងកាត់តាមបណ្តាឃុំសង្កាត់ | 4,000.0 | 4,000.0 | 4,000.0 |
| | ប្រវែងផ្លូវជាតិឆ្លងកាត់តាមបណ្តាឃុំសង្កាត់ | 8,000.0 | 8,000.0 | 8,000.0 |
| ផលធៀបប្រវែងផ្លូវនិងផ្ទៃដីឃុំសង្កាត់ | | 10.8 | 10.8 | 10.8 |

## ៣.៥.មធ្យោបាយដឹកជញ្ជូន

### ៣.៥.១.មធ្យោបាយដឹកជញ្ជូនផ្លូវគោក

| បរិយាយ | | 2015គ្រឿង | 2016គ្រឿង | 2017គ្រឿង |
|---|---|---|---|---|
| ផលធៀបមធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុង1000គ្រួសារ | | 22.4 | 27.5 | 31.9 |
| សរុបមធ្យោបាយដឹកជញ្ជូនជើងគោក | | 120 | 154 | 174 |
| ក្នុងនោះ: មាន | គ្រឿងចក្រយានយន្ត | 21 | 33 | 32 |
| | រថយន្តដឹកទំនិញធុនតូច | 4 | 7 | 8 |
| | រថយន្តដឹកទំនិញធុនធំ | 22 | 21 | 26 |
| | រថយន្តដឹកអ្នកដំណើរធុនតូច | 5 | 5 | 7 |
| | រថយន្តដឹកអ្នកដំណើរធុនធំ | 0 | 1 | 0 |
| | រថយន្តប្រើប្រាស់ក្នុងគ្រួសារ | 58 | 77 | 84 |

# ឧបសម្ព័ន្ធទី ៥

**តារាង ២.៤ គម្រោង សកម្មភាពវិនិយោគឃុំ ដែលមិនទាន់មានថវិកាគាំទ្រ**

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ទីតាំង | លទ្ធផល | | រយៈពេល | អ្នកទទួលផល (នាក់) | | តម្លៃប៉ាន់ស្មាន (រៀល) |
|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | សរុប | ស្រី | |
| **I ផ្នែកសេដ្ឋកិច្ច** | | | | | | | | |
| ១ | ជួសជុលផ្លូវលំដីស | ១ផល់ ៥ .៧.៩ | ៨.៨ | គ.ម | ២ ខែ | ១០,០២៨ | ៥,៩៧៧ | ១៥១,៩៦០,០០០ |
| ២ | ស្តារប្រឡាយស្រោចស្រព | 1,3,4,5,6,7,9 | ១០ | គ.ម | ២ ខែ | ១៣,៣២៧ | ៦៩,០៤ | ២៥២,៩០០,០០០ |
| ៣ | សាងសង់ទរបណ្តែត | ០១.០៥ | ២ | គ.ម | ១ ខែ | ៤,១៩១ | ២,១៧៥ | ៣០,០០០.០០០ |
| ៤ | ផ្តល់ម៉ាស៊ីនបូមទឹក | ឃុំ | ២ | គ្រឿង | ១ សប្តាហ៍ | ១៣,៣២៧ | ៦៩,០៤ | ៤០,០០០,០០០ |
| ៥ | ជីកស្រះចិញ្ចឹមត្រី | គ្រប់ភូមិ | ១៨ | ស្រះ | ៣ខែ | ៣,៥០០ | ១,៨៧៥ | ៣៦,០០០,០០០ |
| ៦ | ផ្តល់ពូជគោ | គ្រប់ភូមិ | ១៤៥ | ក្បាល | ១ខែ | ៧២៥ | ៤៣៥ | ១៤៥,០០០,០០០ |
| ៧ | ផ្តល់ទុនសម្រាប់ប្រកបមុខរបរ | ឃុំ | ១ | លើក | ១ឆ្នាំ | ២,៥៦០ | ១,៥៥០ | ៦៥,០០០,០០០. |
| ៨ | បណ្តុះបណ្តាលជំនាញកាត់ដេរ | ឃុំ | ១ | វគ្គ | ៣ខែ | ៤៥ | ៤៥ | ២,០០០,០០០. |
| ៩ | បណ្តុះបណ្តាលជំនាញជួសជុលម៉ាស៊ីនគ្រប់ប្រភេទ | ឃុំ | ១ | វគ្គ | ៣ខែ | ៤៥ | ០ | ២,០០០,០០០. |
| **II ផ្នែកសង្គមកិច្ច** | | | | | | | | |
| ១ | ផ្សព្វផ្សាយដល់មាតាបិតាកុមារតូចឱ្យយល់ដឹងពីសារៈប្រយោជន៍ និងបញ្ជូនកូនចូលរៀនមត្តេយ្យ | គ្រប់ភូមិ | ៩ | លើក | ១ខែ | ៤,៦០៩ | ២,៤១៥ | ៣,៦០០,០០០. |
| ២ | ផ្តល់ថ្នាក់មត្តេយ្យសហគមន៍ | ឃុំ | ៦ | ថ្នាក់ | ១ខែ | ១៥០ | ៩៤ | ២៤,០០០,០០០. |
| ៣ | ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ | តាមសាលា | ២៧០ | នាក់ | ១សប្តាហ៍ | ២៧០ | ១៣៥ | ៦៤,០០០,០០០. |
| ៤ | បើកថ្នាក់បំប៉នបន្ថែមដល់កុមារដែលរៀនខ្សោយ | តាមសាលា | ៣ | សាលា | ៣ខែ | ៩៥ | ៤៧ | ៤,០០០,០០០. |
| ៥ | ផ្តល់សៀវភៅសម្រាប់សិស្សអាន | សាលាបឋម | ៦០០ | ក្បាល | ១ ខែ | ១,៣៥០ | ៨៧០ | ៦,០០០.០០០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៦ | រៀបចំកែលម្អសោសាងសង់ប្រព័ន្ធទឹកស្អាត | ប្រាសាទ | ១ | កន្លែង | ១ឆ្នាំ | ២៩៦៥ | ១៥៨៥ | ៤,០០០,០០០ |
| ៧ | ប្រជុំពង្រឹងការងារអប់រំរបស់សាលា | ឃុំ | ១២ | ប្រជុំ | ១ ឆ្នាំ | ១,៥៣២ | ៧១៣ | ១,២០០,០០០ |
| ៨ | ផ្តល់រទេះសម្រាប់អ្នកពិការ | គ្រប់ភូមិ | ១១ | គ្រឿង | ១ខែ | ១១ | ៦ | ៨,៨០០,០០០. |
| ៩ | ផ្តល់ការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ | គ្រប់ភូមិ | ១ | លើក | ១ខែ | ២៥ | ១១ | ៤,០០០,០០០. |
| ១០ | ផ្សព្វផ្សាយពីច្បាប់និងសិទ្ធិមនុស្ស | គ្រប់ភូមិ | ៩ | លើក | ១ខែ | ៦,៨០៩ | ៤,២១៥ | ៣,៦០០,០០០. |
| ១១ | បណ្តុះបណ្តាលពីយេនឌ័រ | គ្រប់ភូមិ | ២ | វគ្គ | ៤ថ្ងៃ | ៩០ | ៤៧ | ៤,០០០,០០០. |
| ១២ | ផ្សព្វផ្សាយពីការជួញដូរមនុស្ស | គ្រប់ភូមិ | ៩ | លើក | ១ខែ | ១៣,៣២៧ | ៦,៩០៤ | ៣,៦០០,០០០. |
| ១៣ | បន្ថែមបុគ្គលិកពេទ្យដល់មណ្ឌលសុខភាព | មណ្ឌលសុខភាព | ៥ | នាក់ | ១សប្តាហ៍ | ៦,៨០៩ | ៤,២១៥ | ២០០,០០០. |
| ១៤ | ផ្តល់ឱសថបន្ថែមដល់មណ្ឌលសុខភាព | មណ្ឌលសុខភាព | ៤ | ក្រុមហ៊ុន | ១ឆ្នាំ | ៦,៨០៩ | ៤,២១៥ | ៨០០,០០០. |
| ១៥ | ផ្តល់សម្ភារៈពិនិត្យជម្ងឺទូទៅដល់មណ្ឌលសុខភាព | មណ្ឌលសុខភាព | ១ | កំប្លេ | ១សប្តាហ៍ | ៦,៨០៩ | ៤,២១៥ | ២,០០០,០០០ |
| III **ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ** | | | | | | | | |
| ១ | ផ្សព្វផ្សាយច្បាប់ជលផល | គ្រប់ភូមិ | ៩ | លើក | ១ខែ | ៦,៨០៩ | ៤,២១៥ | ៣,៦០០,០០០. |
| ២ | ផ្តល់ពូជត្រីធម្មជាតិ | គ្រប់ភូមិ | ៩៣,០០០ | ក្បាល | ១ខែ | ៦,៨០៩ | ៤,២១៥ | ៧,៤០០,០០០. |
| ៣ | ផ្សព្វផ្សាយដល់ថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋពីផលប៉ះពាល់នៃគ្រោះមហន្តរាយ និងត្រៀមរៀបចំផែនបង្ការ | គ្រប់ភូមិ | ៩ | លើក | ១ខែ | ៦,៨០៩ | ៤,២១៥ | ៣,៦០០,០០០. |
| IV **ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | | | | |
| ១ | ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការចុះសំបុត្រអត្រានុកូលដ្ឋាន | គ្រប់ភូមិ | ៩ | លើក | ១ខែ | ៦,៨០៩ | ៤,២១៥ | ៣,៦០០,០០០. |
| ២ | បណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ស្ត្រី | ឃុំ | ១ | វគ្គ | ២ថ្ងៃ | ៤៥ | ៤៥ | ២,០០០,០០០. |
| ៣ | បណ្តុះបណ្តាលជំនាញសម្របសម្រួលការងារដល់ស្ត្រី | ឃុំ | ១ | វគ្គ | ២ថ្ងៃ | ៤៥ | ៤៥ | ២,០០០,០០០. |
| ៤ | ប្រជុំពង្រឹងពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ មេភូមិ និងអ្នក | ឃុំ | ១២ | លើក | ១ឆ្នាំ | ៤១ | ៦ | ១,២០០,០០០ |

# ឧបសម្ព័ន្ធទី ៦

តារាង ១.១. តារាងបូកសរុប បញ្ហា តម្រូវការ និង ដំណោះស្រាយថ្នាក់ឃុំ

| ល.រ | បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុនៃបញ្ហា | តម្រូវការ | ដំណោះស្រាយ | [illegible] |
|---|---|---|---|---|---|---|
| ១ | ផ្លូវពិបាកធ្វើដំណើរ | គ្រប់ភូមិ | -ផ្លូវលិចទឹកនិងដក់ទឹក<br>-ខ្វះលូកាត់ផ្លូវ<br>-រថយន្តធំបើកបរលើសទម្ងន់ | -ផ្លូវល្អ<br>-លូកាត់ផ្លូវ<br>-ក្រាលខ្សាច់ភ្នំ<br>-ថែទាំ | -ជួសជុលផ្លូវលំដីស<br>-ដាក់លូកាត់ផ្លូវ<br>-ជួសជុលផ្លូវក្រាលខ្សាច់ភ្នំ<br>-បង្កើតគណៈកម្មការជួសជុល និងថែទាំផ្លូវលំ | |
| ២ | ទិន្នផលស្រូវទាប | គ្រប់ភូមិ | -ខ្វះបច្ចេកទេសដាំស្រូវ<br>-ខ្វះការយល់ដឹងពីសារៈសំខាន់នៃការប្រើប្រាស់ជីធម្មជាតិ<br>-ខ្វះពូជស្រូវទិន្នផលខ្ពស់ | -បច្ចេកទេសដាំដំណាំស្រូវ<br>-បច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត<br>-បច្ចេកទេសធ្វើជីកំប៉ុស្តិ៍<br>-ការយល់ដឹងពីសារៈសំខាន់នៃការប្រើប្រាស់ជីធម្មជាតិ | -បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត<br>-បណ្តុះបណ្តាលបច្ចេកទេសធ្វើជីកំប៉ុស្តិ៍<br>-ផ្សព្វផ្សាយការយល់ដឹងពីសារៈសំខាន់នៃការប្រើប្រាស់ជីធម្មជាតិ<br>-ផ្តល់ពូជស្រូវទិន្នផលខ្ពស់ | |
| ៣ | ទឹកស្រោចស្រពដីកសិកម្មមិនគ្រប់គ្រាន់ | គ្រប់ភូមិ | -ខ្វះប្រឡាយទឹក<br>-ខ្វះម៉ាស៊ីនបូមទឹក | -ប្រភពទឹកធ្វើកសិកម្ម<br>-ម៉ាស៊ីនបូមទឹក | -ស្តារប្រឡាយស្រោចស្រព<br>-សាងសង់ទំនប់ណែត<br>- ផ្តល់ម៉ាស៊ីនបូមទឹក | |
| ៤ | សត្វមានជម្ងឺ | គ្រប់ភូមិ | -មិនបានចាក់វ៉ាក់សាំងការពារជម្ងឺ<br>-ខ្វះបច្ចេកទេសក្នុងការចិញ្ចឹម | -វ៉ាក់សាំងការពារជម្ងឺសត្វ<br>-បច្ចេកទេសចិញ្ចឹមសត្វ<br>-បច្ចេកទេសថ្នាំចំណីសត្វ | -ផ្តល់វ៉ាក់សាំងការពារជម្ងឺសត្វ<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ<br>-បណ្តុះបណ្តាលបច្ចេកទេសធ្វើចំណីសត្វ<br>-ពង្រឹងសមត្ថភាពពេទ្យសត្វភូមិ<br>- ផ្តល់ពូជគោ | |
| ៥ | ប្រាក់ចំណូលក្នុងគ្រួសារទាប | គ្រប់ភូមិ | -ខ្វះពូជសត្វចិញ្ចឹមគ្រប់ប្រភេទ<br>-ខ្វះបច្ចេកទេសចិញ្ចឹមត្រី<br>- ខ្វះស្រះចិញ្ចឹមត្រី<br>[illegible] | -ពូជសត្វចិញ្ចឹមគ្រប់ប្រភេទ<br>-បច្ចេកទេសចិញ្ចឹមត្រី<br>-ស្រះចិញ្ចឹមត្រី<br>- ពូជត្រី | -ផ្តល់ពូជសត្វល្អៗសម្រាប់ចិញ្ចឹម<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>-ជីកស្រះចិញ្ចឹមត្រី<br>-ផ្តល់ពូជត្រី | |

| | | | | |
|---|---|---|---|---|
| | | -ខ្វះជំនាញវិជ្ជាជីវៈសម្រាប់ជនពិការ<br>-ខ្វះការយល់ដឹងពីច្បាប់ចរាចរផ្លូវគោក<br>-ចាស់ជរាកុមារកំព្រាគ្មានទីពឹង<br>-ខ្វះការយល់ដឹងពីចំណាកស្រុកប្រកបដោយសុវត្ថិភាព<br>-ខ្វះការយល់ដឹងពីការជួញដូរមនុស្ស | -ជំនាញវិជ្ជាជីវៈសម្រាប់ជនពិការ<br>-ការយល់ដឹងពីច្បាប់ចរាចរផ្លូវគោក<br>-មណ្ឌល<br>-យល់ដឹងពីចំណាកស្រុកប្រកបដោយសុវត្ថិភាព<br>-ការយល់ដឹងពីការជួញដូរមនុស្ស | -ផ្សព្វផ្សាយពីច្បាប់ចរាចរផ្លូវគោក<br>-បញ្ជូនកុមារកំព្រាទៅមណ្ឌល<br>-ផ្សព្វផ្សាយពីចំណាកស្រុកប្រកបដោយសុវត្ថិភាព<br>-ផ្សព្វផ្សាយពីការជួញដូរមនុស្ស<br>-ផ្តល់ការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ |
| កុមារបោះបង់សាលាដោយមិនបានឆ្លងកាត់ការសិក្សាកម្រិតថ្នាក់មូលដ្ឋាន | គ្រប់ភូមិ | -ឪពុកម្តាយចំណាកស្រុក<br>-ចេញទៅប្រកបមុខរបរជាមួយឪពុកម្តាយ<br>-រៀនមិនចេះ | -រៀនយ៉ាងតិចដល់កម្រិតមូលដ្ឋាន<br>-បញ្ឈប់ពលកម្មកុមារ<br>-បំប៉នបន្ថែមដល់កុមារ | -ផ្សព្វផ្សាយដល់ឪពុកម្តាយកុមារឱ្យទុកលទ្ធភាពដល់កុមាររៀនយ៉ាងទាបចប់កម្រិតមូលដ្ឋាន<br>-ផ្សព្វផ្សាយពីផលប៉ះពាល់នៃពលកម្មកុមារ<br>-បើកថ្នាក់បំប៉នបន្ថែមដល់កុមារដែលរៀនខ្សោយ |
| ពលរដ្ឋឈឺច្រើន | គ្រប់ភូមិ | -ខ្វះការយល់ដឹងពីសុខភាពអនាម័យ<br>- មិនបានចាក់វ៉ាក់សាំងការពារជម្ងឺ<br>-ខ្វះការយល់ដឹងពីបម្រែបម្រួលអាកាសធាតុ<br>-ហូបអាហារនិងបន្លែមានសារធាតុគីមី | - យល់ដឹងពីសុខភាពនិងអនាម័យ<br>-ចាក់វ៉ាក់សាំងបានគ្រប់និងទៀងទាត់<br>-យល់ដឹងពីបម្រែបម្រួលនៃអាកាសធាតុ<br>-អាហារដែលមិនប៉ះពាល់ដល់សុខភាព | - ផ្សព្វផ្សាយពីសុខភាពនិងអនាម័យ<br>-ផ្សព្វផ្សាយនិងជម្រុញពីការចាក់វ៉ាក់សាំងការពារជម្ងឺកុមារ<br>-ផ្តល់ធុងចម្រោះទឹកស្អាត<br>-សង់បង្គន់អនាម័យតាមខ្នងផ្ទះ<br>-គាំទ្រផ្តល់ឱសថដល់មណ្ឌលសុខភាព<br>- ផ្តល់សម្ភារៈពិនិត្យជម្ងឺទូទៅដល់មណ្ឌលសុខភាព<br>- ផ្សព្វផ្សាយជម្រុញស្ត្រីមានផ្ទៃពោះឱ្យទៅពិនិត្យ និងសម្រាលនៅ |